# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Universite Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាព ក្រុងបាត់ដំបង

ស្រាវជ្រាវចាប់ផ្ដើមពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ៖ **ក. គី គឹមហ៊ួង** | **បណ្ឌិត ឌី ពុទ្ធារ៉ា** |
| **ក. ប្រាជ្ញប្រកប សុទ្ធពេជ្របរមី** | |


| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | ឆ្នាំសិក្សា ២០១៨ |
| ជំនាន់ទី១៥ | ឆ្នាំបញ្ចប់សិក្សា ២០២២ |

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Universite Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាព ក្រុងបាត់ដំបង

ស្រាវជ្រាវចាប់ផ្តើមពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ៖ **ក. គី គឹមហ៊ួង** | **បណ្ឌិត ឌី ពុទ្ធារ៉ា** |
| **ក. ប្រាជ្ញប្រកប សុទ្ធពេជ្របរមី** | |

| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | ឆ្នាំសិក្សា ២០១៨ |
| ជំនាន់ទី១៥ | ឆ្នាំបញ្ចប់សិក្សា ២០២២ |

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំទាំងពីរនាក់ឈ្មោះ **គី គឹមហ៊្វង** និង **ប្រាជ្ញប្រកប សុទ្ធពេជ្របរមី** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈឆ្នាំទី៤ ជំនាន់ទី១៥ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា ២០១៨-២០២២។

នាងខ្ញុំសូមធ្វើការសម្ដែងការដឹងគុណយ៉ាងខ្ពង់ខ្ពស់ព្រមទាំងកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះ

- **លោកឪពុក អ្នកម្ដាយ** ដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់មើលថែរក្សារូបនាងខ្ញុំឱ្យធំដឹងក្ដី ផ្ដល់ដំបូន្មានល្អៗព្រមទាំងទំនុកបំរុងការសិក្សារហូតមកដល់សព្វថ្ងៃនេះ។ បន្ថែមពីនេះទៀតក៏សូមថ្លែងអំណរគុណដល់លោកតា លោកយាយ និងសមាជិកគ្រួសារដែលបានផ្ដល់ជាកម្លាំងចិត្តដល់នាងខ្ញុំទាំងពីរ។
- **ឯកឧត្ដម បណ្ឌិត លុយ ចន្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងគណៈគ្រប់គ្រងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្ដល់ឱកាសឱ្យនាងខ្ញុំទាំងពីរបានសិក្សារៀនសូត្រនៅទីនេះ។
- លោកគ្រូសាស្ត្រាចារ្យណែនាំ **បណ្ឌិត ឌី ពុទ្ធារ៉ា** ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការណែនាំ និងផ្ដល់ជាគំនិតក្នុងការតាក់តែង ព្រមទាំងការស្រាវជ្រាវដោយមិនខ្លាចការនឿយហត់ ជួយបំពេញនូវចំណុចខ្វះខាត ដាស់តឿនស្មារតី និងជំរុញទឹកចិត្តក្នុងការស្រាវជ្រាវឯកសារនេះឡើង។
- លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបង្រៀន អប់រំ និងណែនាំដល់នាងខ្ញុំ ដើម្បីជាស្ពានក្នុងការត្រិះរិះ ពិចារណា អភិវឌ្ឍខ្លួនឯង និងវិភាគនូវចំណុចល្អ អាក្រក់ និងជាពិសេសចំណេះដឹង និងជំនាញខ្លះៗដែលជាដើមទុនក្នុងការអនុវត្តក្នុងសង្គមការងារ។
- **ឯកឧត្ដម សុខ លូ** ជាអភិបាលខេត្តបាត់ដំបង
- **លោក ផេង សិទ្ធី** ជាអភិបាលនៃគណៈអភិបាលក្រុងបាត់ដំបង
- **លោក ឯម ឆរិទ្ធ** ជាប្រធានការិយាល័យប្រជាពលរដ្ឋ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

ជាទីបញ្ចប់នាងខ្ញុំទាំងពីរ សូមប្រសិទ្ធិពរជ័យដល់លោកអ្នកដែលមានគុណខាងលើទាំងអស់ឱ្យជួបតែប្រសិទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

អស់រយៈពេលបួនឆ្នាំ ដែលនាងខ្ញុំទាំងពីរនាក់បានចូលមកសិក្សាស្វែងយល់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលជាគ្រឹះស្ថានអប់រំសាធារណៈរបស់រដ្ឋ។ ជាក់ស្តែងនៅក្នុងសាកលវិទ្យាល័យនេះ គឺពិតជាសាកលវិទ្យាល័យមួយដែលគួរឱ្យចាប់អារម្មណ៍ ព្រោះសម្បូរទៅដោយសាស្ត្រាចារ្យល្បីៗ ដែលមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបង្ហាត់បង្រៀន និងណែនាំនិស្សិតឱ្យយល់ច្បាស់ពីជំនាញដែលនិស្សិតបានជ្រើសរើសយកមកសិក្សា ក្នុងនោះដែរចំពោះជំនាញដែលនាងខ្ញុំទាំងពីរបានជ្រើសរើសយកមកសិក្សានោះ គឺជំនាញរដ្ឋបាលសាធារណៈ។

ជាក់ស្តែងក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នាងខ្ញុំទាំងពីរពិតជាមានក្តីសោមនស្សរីករាយជាខ្លាំង ដោយនាងខ្ញុំទាំងពីរនាក់ទទួលបាននូវចំណេះដឹងជាច្រើន ទាំងផ្នែកទ្រឹស្តី និងការអនុវត្តនៅក្នុងផ្នែកនេះ។ ដោយចំណេះដឹងដែលទទួលបាននេះហើយក៏បានជំរុញឱ្យនាងខ្ញុំទាំងពីរនាក់ បានធ្វើការសម្រេចចិត្តជ្រើសរើសការសរសេរសារណាបញ្ចប់ការសិក្សានេះឡើងដោយជ្រើសរើសយកប្រធានបទការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពក្រុងបាត់ដំបងនេះមកធ្វើជាប្រធានក្នុងការស្រាវជ្រាវ និងស្វែងយល់ដើម្បីជាជំនួយស្មារតីក៏ដូចជាឯកសារសិក្សាបន្ថែមសម្រាប់និស្សិតជំនាន់ក្រោយ អ្នកស្រាវជ្រាវ ឬអ្នកចង់ស្វែងយល់ពីការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពក្រុងបាត់ដំបងផងដែរ។

យ៉ាងណាមិញនៅក្នុងការស្រាវជ្រាវលើប្រធានបទនេះ គឺនៅពេលមានចំណុចខ្វះចន្លោះទាំងពាក្យពេចន៍ និងអត្ថន័យខ្លឹមសារ អាស្រ័យដូចនេះសូមលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់ មេត្តាខន្តីអធ្យាស្រ័យដល់ការស្រាវជ្រាវរបស់ក្រុមនាងខ្ញុំផង ហើយក្រុមនាងខ្ញុំមានសេចក្តីរីករាយក្រៃលែងក្នុងការទទួលនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីរួមចំណែកក្នុងការកែលម្អកិច្ចការស្រាវជ្រាវមួយនេះឱ្យមានភាពល្អប្រសើរ។

# មាតិកា


ទំព័រ

បញ្ជីតារាង ..................................................... iii

**សេចក្តីផ្តើម** ..................................................... ១

**ជំពូកទី១**

**ការរៀបចំសណ្តាប់ធ្នាប់ក្នុងក្រុងបាត់ដំបង**

**១.១. ទិដ្ឋភាពទូទៅរបស់ក្រុងបាត់ដំបង** ..................................................... ៥

**១.១.១. បុព្វហេតុដែលនាំឱ្យមានការរៀបចំសណ្តាប់ធ្នាប់** ..................................................... ៧

១.១.១.១. កំណើនប្រជាជន ..................................................... ៧

១.១.១.២. ភាពក្រីក្រ ..................................................... ៨

១.១.១.៣. ចរាចរណ៍ ..................................................... ៩

១.១.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ..................................................... ១០

**១.១.២. រចនាសម្ព័ន្ធក្រុងបាត់ដំបង** ..................................................... ១១

១.១.២.១. ក្រុមប្រឹក្សាក្រុង ..................................................... ១២

១.១.២.២. គណៈអភិបាលក្រុង ..................................................... ១៩

**១.២. បច្ចុប្បន្នភាព និងទិសដៅអនាគតនៃការរៀបចំក្រុងបាត់ដំបង** ..................................................... ២១

**១.២.១. បច្ចុប្បន្នភាពនៃការរៀបចំសណ្តាប់ធ្នាប់** ..................................................... ២១

១.២.១.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ..................................................... ២២

១.២.១.២. ការអភិវឌ្ឍសំណង់លំនៅដ្ឋាន ..................................................... ២៧

១.២.១.៣. ការរៀបចំរបៀបរៀបរយ ..................................................... ២៩

**១.២.២. ទិសដៅអនាគតនៃការរៀបចំសណ្តាប់ធ្នាប់** ..................................................... ៣០

១.២.២.១. ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន ..................................................... ៣២

១.២.២.២. ការអភិវឌ្ឍលើវិស័យទឹកស្អាត និងអនាម័យ ..................................................... ៣៣

១.២.២.៣. ការអភិវឌ្ឍលើវិស័យដីធ្លី ..................................................... ៣៣

១.២.២.៤. ការអភិវឌ្ឍលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ..................................................... ៣៣

## ជំពូកទី២
## ការរៀបចំសោភ័ណភាពក្រុងបាត់ដំបង

**២.១. ការរៀបចំសោភ័ណភាពពេលថ្ងៃ និងពេលយប់** ........ ៣៥
**២.១.១. ការរៀបចំសោភ័ណភាពពេលថ្ងៃ** ........ ៣៥
២.១.១.១. ការដាំដើមឈើតាមដងផ្លូវ ........ ៣៦
២.១.១.២. ការរៀបចំសំណង់អគារ និងតាមដងផ្លូវ ........ ៣៨
**២.១.២. ការរៀបចំសោភ័ណភាពនាពេលយប់** ........ ៣៩
២.១.២.១. ការដាំបង្គោលភ្លើងអគ្គិសនី ........ ៣៩
២.១.២.២. ការបំពាក់លើចម្រុះពណ៌តាមសួនច្បារ និងទីកន្លែងសាធារណៈ ........ ៤០
**២.១.៣. វិស័យទេសចរណ៍** ........ ៤១
២.១.៣.១. ចលនាប្រឡងប្រណាំងទីក្រុងស្អាតរបស់កម្ពុជា ........ ៤៣
២.១.៣.២. ជ័យលាភីជាទីក្រុងទេសចរណ៍ស្អាតអាស៊ាន ........ ៤៥
**២.២. បញ្ហាបរិស្ថាន និងដំណោះស្រាយ** ........ ៤៦
**២.២.១. ការបំពុលទឹក** ........ ៤៧
**២.២.២. ការបំពុលដី** ........ ៤៨
**២.២.៣. ការបំពុលខ្យល់** ........ ៥០
**២.២.៤. ការបំពុលដោយសំណល់រឹង រាវ** ........ ៥១
**២.២.៥. ការបំពុលដោយសំឡេង** ........ ៥៥
**សេចក្ដីសន្និដ្ឋាន** ........ ៥៧
**អនុសាសន៍** ........ ៥៩
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# បញ្ជីតារាង

ទំព័រ

តារាងទី១៖ ឈ្មោះសង្កាត់ទាំង១០នៅក្នុងក្រុងបាត់ដំបង....................................................................៥
តារាងទី២៖ រចនាសម្ព័ន្ធក្រុមប្រឹក្សាក្រុងបាត់ដំបង..............................................................................១២
តារាងទី៣៖ រចនាសម្ព័ន្ធគណៈអភិបាលក្រុង.......................................................................................១៩

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រោយពីប្រទេសកម្ពុជាបានឆ្លងកាត់នូវសង្គ្រាមអស់ជាច្រើនទសវត្សរ៍មកនេះ ព្រះរាជាណាចក្រកម្ពុជាក៏កំពុងតែធ្វើដំណើរយ៉ាងខិតខំប្រឹងប្រែងនៅក្នុងការរៀបចំសណ្តាប់ធ្នាប់ និងការធ្វើការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ដើម្បីប្រទេសជាតិរបស់ខ្លួនឱ្យមានភាពជឿនលឿនទៅមុខឱ្យដូចប្រទេសដទៃទៀតដែលកំពុងអភិវឌ្ឍនៅក្នុងសកលលោកយើងនេះផងដែរ។ នៅក្នុងការអភិវឌ្ឍនេះផងដែរ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅប្រទេសកម្ពុជាមានការអភិវឌ្ឍគ្រប់កន្លែងមានដូចជា ទីក្រុង ស្រុក ខណ្ឌនានាដែលជាតម្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់នីមួយៗ។

ប្រទេសកម្ពុជារបស់យើងសព្វថ្ងៃត្រូវធ្វើការរៀបចំ ផ្លាស់ប្តូរ និងអភិវឌ្ឍប្រទេសឱ្យសមស្របទៅតាមការកំណត់នៃប្លង់គោលដែលបានរៀបចំដោយគណៈកម្មការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុគណៈកម្មការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្តនីមួយៗត្រូវគូសប្លង់គោលដើម្បីធ្វើជាការរៀបចំ និងអភិវឌ្ឍរាជធានី ខេត្ត ក្រុងរបស់ខ្លួន។ ប្លង់គោលនេះផងដែរត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងកំណត់ដោយអនុក្រឹត្យ។ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពគឺជាកត្តាដ៏សំខាន់មួយ ដើម្បីកែលម្អឱ្យមានភាពល្អឱ្យប្រសើរឡើងជាងមុនបន្ថែមដោយស្របទៅតាមប្លង់គោល និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីធ្វើយ៉ាងណាឱ្យរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់មានសណ្តាប់ធ្នាប់ និងសោភ័ណភាពល្អប្រកបដោយភាពជឿនលឿនទៅមុខជាបន្តបន្ទាប់។ សណ្តាប់ធ្នាប់ គឺជាការសំដៅដល់ធាតុ៣មានដូចជា សន្តិសុខ ភាពស្ងប់ស្ងៀម និងមានអនាម័យ។ សោភ័ណភាព គឺល្អហ្មត់ហ្មង។ ដោយឡែកខេត្ត ក្រុងនីមួយៗនៃព្រះរាជាណាចក្រកម្ពុជាក៏នៅតែមានភាពខ្វះចន្លោះ និងបញ្ហាប្រឈមផងដែរ ដោយបច្ចុប្បន្ន គណៈអភិបាលខេត្តនីមួយៗកំពុងតែខិតខំប្រឹងប្រែងដោះស្រាយចំពោះបញ្ហាប្រឈមដែលកំពុងកើតឡើង និងខិតខំកសាងអភិវឌ្ឍជាបន្តបន្ទាប់។ ហេតុនេះក្រុមយើងមានការជ្រើសរើសប្រធានបទ **ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពក្រុងបាត់ដំបង** នេះឡើងដើម្បីធ្វើការសិក្សាស្វែងយល់ឱ្យមានភាពស៊ីជម្រៅ និងទទួលបានចំណេះដឹងថ្មីបន្ថែមទៀត។

ដោយមើលឃើញពីបញ្ហាប្រឈមនានាដែលកើតឡើង រាជរដ្ឋាភិបាល ព្រមទាំងគណៈអភិបាលខេត្តបាត់ដំបងបានធ្វើការស្តារ និងជួសជុសទៅលើប្រព័ន្ធលូ ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ រៀបចំបន្ថែមទៅលើសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅក្នុងក្រុងដែលកត្តាទាំងអស់នេះហើយជាមូលហេតុនាំឱ្យមានការអភិវឌ្ឍនៅក្នុងក្រុងបាត់ដំបង។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងជាក់ស្តែងក្រុងបាត់ដំបង គឺមានគណៈអភិបាលខេត្ត និងអភិបាលរងខេត្ត គណៈអភិបាលក្រុង គណៈអភិបាលរងក្រុង ព្រមជាមួយមន្ត្រីទាំងអស់ដែលមានតួនាទីក្នុងការអភិវឌ្ឍ និងរៀបចំក្នុងក្រុងនេះឱ្យបានទទួលលទ្ធផលល្អ។

ទោះជាយ៉ាងណាក្តីដើម្បីឱ្យនិស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ និងសាធារណៈជនទាំងអស់បានយល់កាន់តែច្បាស់អំពីក្រុងបាត់ដំបង គឺចោទជាសំណួរថា៖

- **តើក្រុងបាត់ដំបងមានវិធានការណ៍អ្វីខ្លះ ចំពោះការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពឱ្យបានល្អ?**
- **តើក្រុងបាត់ដំបងមានដំណោះស្រាយអ្វីខ្លះ ចំពោះបញ្ហាបរិស្ថានឱ្យមានភាពល្អប្រសើរ?**
- **តើក្រុងបាត់ដំបងមានទិសដៅអភិវឌ្ឍអ្វីខ្លះនាពេលអនាគត?**

ដូចនេះនិស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ និងសាធារណជនទាំងអស់ប្រាកដជាយល់ដឹងអំពីការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពក្រុងបាត់ដំបង ថែមទាំងនាំមកនូវស្នាដៃស្រាវជ្រាវនេះមកធ្វើជាឯកសារពិគ្រោះ និងជំនួយស្មារតីបានទៀតផង។

## ៣. គោលបំណងនៃការស្រាវជ្រាវ

រាល់ការស្រាវជ្រាវទាំងអស់ គឺតែងតែមានគោលបំណងនៅក្នុងការស្រាវជ្រាវ។ ដោយឡែកនៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធាននេះគឺមែងតែងចង់ឱ្យនិស្សិតគ្រប់រូប និងសាធារណជនបានយល់ដឹងពីការអភិវឌ្ឍ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៃក្រុងនៅក្នុងប្រទេសកម្ពុជា។ ជាពិសេសទៅទៀតចង់ឱ្យនិស្សិតជំនាន់ក្រោយបានយល់ដឹង និងជ្រាបច្បាស់ពីការអភិវឌ្ឍព្រមទាំងអាចយកឯកសារនេះសម្រាប់ជាជំនួយស្មារតីបន្ថែមលើការស្រាវជ្រាវរបស់ខ្លួន។

## ៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវទាំងអស់តែងតែមាននូវដែនកំណត់របស់ខ្លួន។ ដូច្នេះអ្វីដែលទាក់ទងទៅនឹងប្រធានបទការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពក្រុងបាត់ដំបង គឺនាងខ្ញុំនឹងធ្វើការបកស្រាយ និងសិក្សាស្រាវជ្រាវទៅលើអ្វីដែលពាក់ព័ន្ធនឹងសណ្តាប់ធ្នាប់ និងសោភ័ណភាពក្នុងក្រុងបាត់ដំបង។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើនេះ គឺពិតជាមានសារៈសំខាន់ដល់និស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ និងសាធារណជនទាំងអស់អាចជួយសម្រួលដល់ការអភិវឌ្ឍ ឬរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពក្នុងក្រុងបាត់ដំបងដើម្បីយកទៅអភិវឌ្ឍក្នុងក្រុងណាមួយថែមទៀត។

## ៦. វិធីសាស្រ្តស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះ គឺធ្វើបកស្រាយ និងបំភ្លឺទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានាដែលមានបញ្ហាប្រឈម និងដំណោះស្រាយរបស់ខេត្តក្រុងព្រមទាំងឯកសារដែលទទួលបានពីសាលាក្រុងបាត់ដំបង និងបណ្តាផ្សព្វផ្សាយដែលបានសិក្សាស្រាវជ្រាវជាមួយទិដ្ឋភាពទូទៅផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទនេះដែរ គឺបានធ្វើការបែងចែកជា២ជំពូកក្នុងនោះមាន៖

- **ជំពូកទី១ ការរៀបចំសណ្តាប់ធ្នាប់ក្នុងក្រុងបាត់ដំបង៖** នៅក្នុងជំពូកនេះនាងខ្ញុំបែងចែកជាពីរផ្នែកដោយផ្នែកទី១បកស្រាយអំពីទិដ្ឋភាពទូទៅ រីឯផ្នែកទី២បកស្រាយអំពីបច្ចុប្បន្នភាព និងទិសដៅអនាគតនៃការរៀបចំសណ្តាប់ធ្នាប់។
- **ជំពូកទី២ ការរៀបចំសោភ័ណភាពក្រុងបាត់ដំបង៖** នៅក្នុងជំពូកនេះនាងខ្ញុំបែងចែកជាពីរផ្នែកដោយផ្នែកទី១បកស្រាយអំពីការរៀបចំសោភ័ណភាពពេលថ្ងៃ និងពេលយប់ និងវិស័យទេសចរណ៍ រីឯផ្នែកទី២បកស្រាយអំពីបញ្ហាបរិស្ថាន និងដំណោះស្រាយ។

# ជំពូកទី១
# ការរៀបចំសណ្ដាប់ធ្នាប់
# ក្រុងបាត់ដំបង

# ជំពូកទី១
# ការរៀបចំសណ្តាប់ធ្នាប់ក្នុងក្រុងបាត់ដំបង

យោងតាមការវិភាគពីស្ថានភាពក៏ដូចជាបញ្ហាទាក់ទងនឹងសណ្តាប់ធ្នាប់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ផ្សារភ្ជាប់ជាមួយនឹងបញ្ហាប្រឈមជាមួយជំងឺរីករាលដាលកូវីដ-១៩ដែលកើតនាពេលបច្ចុប្បន្ននេះ។ យើងនឹងសរបញ្ជាក់ឱ្យឃើញថា ការរៀបចំសណ្តាប់ធ្នាប់នៅក្នុងក្រុងបាត់ដំបងនៅតាមទីសាធារណៈត្រូវបានសាលាក្រុងធ្វើការយកចិត្តទុកដាក់យ៉ាងខ្លាំង ប៉ុន្តែដោយសារសាលាក្រុងបានធ្វើការទៅលើការថែរក្សាសន្តិសុខ សុវត្ថិភាព ព្រមទាំងការរៀបចំសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋក្នុងការរស់នៅប្រកបដោយភាពត្រឹមត្រូវផងដែរ។ ប៉ុន្តែបញ្ហាសណ្តាប់ធ្នាប់ក្នុងក្រុងបាត់ដំបងក៏ចោទជាបញ្ហាសម្រាប់សាលាក្រុងបាត់ដំបងនៅឡើយ និងប្រជាពលរដ្ឋមួយចំនួនបំពានច្បាប់ដែលជាហេតុធ្វើឱ្យសណ្តាប់ធ្នាប់ក្រុងបាត់ដំបងមិនទាន់មានភាពប្រសើរ។ បញ្ហាទាំងអស់នេះហើយជាបញ្ហាដ៏សំខាន់មួយដែលអាជ្ញាធរក្រុងគួរគប្បីដោះស្រាយបញ្ហាដែលនឹងកើតមានឱ្យទាន់សភាពការណ៍ និងត្រូវព្យាយាមផ្សព្វផ្សាយច្បាប់ផ្សេងៗ ដែលពាក់ព័ន្ធនឹងការរៀបចំសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋឱ្យបានយល់បង្ហាញដោយភាពទន់ភ្លន់ ដើម្បីជាភាពងាយស្រួលឱ្យពួកគាត់បានយល់ពីច្បាប់ និងគោលដៅដែលសាលាក្រុងមានផែនការយុទ្ធសាស្ត្រនាពេលអនាគត។ ម៉្យាងវិញទៀតមុននឹងឈានដល់ការរៀបចំ ឬការអភិវឌ្ឍត្រូវពិនិត្យមើលទៅតាមប្លង់គោលដែលកំណត់ជាមុនសិនដើម្បីឱ្យការរៀបចំសណ្តាប់ធ្នាប់ទាំងអស់ឱ្យមានរបៀបរៀបរយ។ ប្លង់គោលជាឯកសារ ឬជាគម្រោងដែលមានលក្ខណៈជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍរាជធានីភ្នំពេញ។ ប្លង់គោលជាប្លង់គ្រឹះ និងជាប្លង់តម្រង់ទិសក្នុងការបែងចែកកំណត់ដីធ្លីសម្រាប់តំបន់សាងសង់ តំបន់ចាក់សំរាម តំបន់សាលារៀន តំបន់ដែលត្រូវរក្សាការពារ និងតំបន់ដែលត្រូវអភិវឌ្ឍ។[1] ក្នុងនោះក៏បានកំណត់ក្នុងច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដែលបានចែងក្នុងមាត្រា៧បានចែងថាដីអាចសាងសង់បាន ឬសាងសង់មិនបានមានដូចតទៅៈ

- តំបន់សម្រាប់ការពារជាតិ
- តំបន់សម្រាប់ពាណិជ្ជកម្ម
- តំបន់កសិកម្ម ឧស្សាហកម្ម
- តំបន់សិប្បកម្ម
- តំបន់ទេសចរណ៍
- តំបន់វប្បធម៌ សាសនា និងតំបន់សម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខាសាធារណៈ។[2]

[1] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ (២០១៩-២០២០) ទំព័រទី១៤៤

[2] មាត្រា៧ នៃច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤

## ១.១. ទិដ្ឋភាពទូទៅរបស់ក្រុងបាត់ដំបង

ខេត្តបាត់ដំបង គឺជាខេត្តមួយនៅភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា តាមបណ្តោយផ្លូវជាតិលេខ៥ ដែលមានចំងាយ២៩១គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ដែលមានព្រំប្រទល់ខាងជើងជាប់នឹងខេត្តបន្ទាយមានជ័យ ខាងកើតជាប់នឹងខេត្តសៀមរាប និងបឹងទន្លេសាប ខាងត្បូងជាប់នឹងខេត្តពោធិ៍សាត់ និងខាងលិចជាប់នឹងប្រទេសថៃ។ ក្រុងបាត់ដំបង គឺជាក្រុងក្នុងចំណោមស្រុកសរុប១៤ នៃខេត្តបាត់ដំបង និងជាទីប្រជុំជនរបស់ខេត្តបាត់ដំបង។ ក្រុងបាត់ដំបងមានសង្កាត់ចំនួន១០ និង ភូមិចំនួន៦២។

| ល.រ | ឈ្មោះសង្កាត់ជាអក្សរខ្មែរ | ឈ្មោះសង្កាត់ជាអក្សរឡាតាំង |
|---|---|---|
| ១ | ទួលតាឯក | Toul Ta Aek |
| ២ | ព្រែកព្រះស្តេច | Preaek Preah Sdech |
| ៣ | រតនៈ | Rotanak |
| ៤ | ចំការសំរោង | Chamkar Samraong |
| ៥ | ស្លាកែត | Sla Kaet |
| ៦ | ក្តុលដូនទាវ | Kdoul Doun Teav |
| ៧ | អូរម៉ាល់ | Ou Mal |
| ៨ | វត្តគរ | Voat Kor |
| ៩ | អូរចារ | Ou Char |
| ១០ | ស្វាយប៉ោ | Svay Pao |

តារាងទី១៖ ឈ្មោះសង្កាត់ទាំង១០នៅក្នុងក្រុងបាត់ដំបង

- **ស្ថានភាពភូមិសាស្ត្រ៖** ទីក្រុងបាត់ដំបងមានទីតាំងស្ថិតនៅតាមបណ្តាយស្ទឹងសង្កែ និងចំណុចប្រសព្វផ្លូវជាតិលេខ៥ និង៥៧ សព្វថ្ងៃក្រុងបាត់ដំបងមានផ្ទៃដី១១៥៤៨គីឡូម៉ែត្រការេដែលមានព្រំប្រទល់ខាងលិចជាប់ស្រុកថ្មគោល ខាងកើតជាប់ស្រុកសង្កែ ខាងជើងជាប់ស្រុកឯកភ្នំ ខាងត្បូងជាប់ស្រុកបាណន់។ ក្រុងបាត់ដំបងមានស្ទឹង១ គឺស្ទឹងសង្កែដែលជាប្រភពផ្គត់ផ្គង់ទឹកដ៏សំខាន់។[3] ក្រុងបាត់ដំបងគឺជាមជ្ឈមណ្ឌលចម្រុះផ្នែកនយោបាយ ពាណិជ្ជកម្ម វប្បធម៌។ល។ សម្រាប់ការងារដែលពាក់ព័ន្ធអភិវឌ្ឍក្រុងបាត់ដំបងនាពេលអនាគតដូចជា មានលទ្ធភាពជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានទៅលើ

[3] គេហទំព័រ http://phumsas.blogspot.com/2020/05/blog-post_23.html ដកស្រង់ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២

វិស័យទេសចរណ៍ កសិកម្ម ពាណិជ្ជកម្ម សិប្បកម្ម អប់រំ សុខាភិបាល និងការអភិវឌ្ឍវិស័យរដ្ឋបាលសាធារណៈ សន្តិសុខ បរិស្ថាន និងលើកកម្ពស់កិច្ចការយេនឌ័រ។

- **ស្ថានភាពប្រជាសាស្ត្រ៖** ប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុងបាត់ដំបងមានចំនួន៣១.៩២៣គ្រួសារស្មើនឹងប្រជាពលរដ្ឋសរុបចំនួន១៥២.០៧៦នាក់ ដែលក្នុងនោះមានស្ត្រីចំនួន៧៨.០៧៩នាក់។ ប្រជាពលរដ្ឋមានអាយុ១៨ឆ្នាំឡើងចំនួន១២១.៦០៦នាក់ និងចំនួនប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ៨២.៨៤៣នាក់។[4]
- **ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច៖** មុខរបរប្រជាពលរដ្ឋក្នុងក្រុងបាត់ដំបងមានដូចជា៖ ១៧.៥0% ប្រកបរបរកសិកម្មក្នុងនោះកសិករធ្វើស្រែ១១.៨0% កសិករដាំដំណាំរយៈវែងដូចជាមៀន ក្រូច ស្វាយ ២%។ កសិករដាំដំណាំរយៈពេលខ្លីរួមមាន៖ អំពៅ ពោត សណ្តែក និងល្ង ១.៧0% និងដាំបន្លែមាន ១.៧0% និងនេសាទមាន0.១0% ចិញ្ចឹមសត្វមាន0.៥0%។ ចំពោះផ្នែកសិប្បកម្មមានចំនួន១% សិប្បកម្មមានចំនួន២០៤ទីតាំង។ ចំណែកឯផ្នែកសេវាកម្មមាន៨១.៥0% ភោជនីយដ្ឋានមានចំនួន៤0 ទីតាំង ផ្សារមានចំនួន០៩ទីតាំង (ផ្សាររដ្ឋមាន៧ទីតាំង ផ្សារឯកជនមាន២ទីតាំង) ធនាគារមីក្រូហិរញ្ញវត្ថុមានចំនួន៣១ទីតាំង (ធនាគារមាន១៣ទីតាំង មីក្រូហិរញ្ញវត្ថុមាន១៨ទីតាំង) ក្លឹបកម្សាន្តមានចំនួន១១ ទីតាំង សណ្ឋាគារ ផ្ទះសំណាក់មានចំនួន១១0ទីតាំង (សណ្ឋាគារមាន៤២ទីតាំង ផ្ទះសំណាក់មាន៦៨ ទីតាំង) រោងចក្រផលិតទឹកស្អាតមានចំនួន២ទីតាំង។[5]
- **វិស័យអប់រំ៖** គ្រឹះស្ថានអប់រំរដ្ឋវិទ្យាល័យ០៥, អនុវិទ្យាល័យ០៩, សាលាបឋមសិក្សា៣៦,សាលាមត្តេយ្យសិក្សា៣0 និងគ្រឹះស្ថានអប់រំឯកជន០៨។[6]
- **វិស័យសុខាភិបាល៖** មន្ទីរពេទ្យបង្អែក០១កន្លែង មណ្ឌលសុខភាព០៨កន្លែង ផ្នែកប្រយុទ្ធនឹងជំងឺឆ្លង ០១កន្លែង មជ្ឈមណ្ឌលផ្តល់ឈាម០១កន្លែង មន្ទីរពេទ្យឯកជន១៥កន្លែង ទីតាំងឱសថស្ថាន ឱសថស្ថានរងទីតាំង៥៨កន្លែង។[7]
- **វិស័យធម្មការ និងសាសនា៖** មានវត្តសរុបចំនួន៣១វត្ត, វិហារសាសនាឥស្លាមចំនួន០៤ទីតាំង, វិហារគ្រឹស្តសាសនាចំនួន៦ទីតាំង។[8]

[4] សៀវភៅរបាយការណ៍ប្រចាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងប្រចាំឆ្នាំ២០២១ ទំព័រទី០១

[5] តារាងសូចនាករតាមឃុំ-សង្កាត់ក្នុងក្រុងបាត់ដំបងឆ្នាំ២០២១

[6] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទំព័រទី១៤

[7] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទំព័រទី១៦

[8] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទំព័រទី២១

### ១.១.១. មូលហេតុដែលនាំឱ្យមានការរៀបចំសណ្តាប់ធ្នាប់

កត្តានាំឱ្យមានការរៀបចំក្រុងមួយចាំបាច់ត្រូវធ្វើឡើងប្រកបដោយសន្និទានកម្ម ពោលគឺមានការគិតគូរហ្មត់ចត់សព្វគ្រប់ជ្រុងជ្រោយ។[៦] ទន្ទឹមនឹងនេះ មុននឹងឈានដល់ការរៀបចំ ឬអភិវឌ្ឍអ្វីមួយ គឺវាបណ្តាលមកពីភាពខ្វះចន្លោះដែលជាហេតុនាំកើតមានឡើងនូវបញ្ហាផ្សេងៗផងដែរ។ យ៉ាងណាមិញយើងក្រឡេកមើលទៅតាមបណ្តាតំបន់នានាដូចជា៖ ភូមិ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/ក្រុង ក្នុងប្រទេសនានាក៏ដូចជាប្រទេសកម្ពុជារបស់យើងតែងមានការរៀបចំនូវគម្រោង ឬដាក់ផែនការសកម្មភាពអភិវឌ្ឍនៅតាមតំបន់នានាដែលកំពុងជួបនូវបញ្ហាខ្វះខាតដែលត្រូវមានការរៀបចំឱ្យកាន់តែប្រសើរឡើងជាងមុន។ ជារួមការរៀបចំទីក្រុងដើម្បីឱ្យមានសណ្តាប់ធ្នាប់សំដៅដល់ការរៀបចំក្រុងឱ្យមានសកម្មភាពល្អ សន្តិសុខភាពស្ងប់ស្ងាត់ និងអនាម័យ។ ដូច្នេះក្រុងកើតឡើងពុំមែនដោយសារកត្តាចៃដន្យនោះទេ គឺកើតឡើងដោយសារមូលហេតុជំរុញពីក្រោយជាច្រើន។

#### ១.១.១.១. កំណើនប្រជាជន

ជាទូទៅមាននូវសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុង៣សំខាន់ៗ៖ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនដោយសារចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មី។ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ គឺមួយឆ្នាំទៅមួយឆ្នាំមនុស្សចេះតែកើនឡើងដូច្នេះអត្រាកើតប្រជាពលរដ្ឋថ្មីនេះហើយ ក៏ដូចជាចំនួនកំណើនប្រជាជននៅក្នុងទីក្រុងស្ថិតនៅតាមកាលៈទេសៈពេលវេលាចេះតែរំកិលទៅមុខអត្រាមរណភាពភាគតិច ហើយអត្រាកើតក៏ច្រើនផងដែរ។ កំណើនដោយសារចំណាកស្រុកពីជនបទ គឺដោយសារក្រុងបាត់ដំបងសម្បូរហាងលក់ទំនិញ កន្លែងកំសាន្ត ហាងតូចធំជាច្រើន ហេតុនេះក្រុងបាត់ដំបង គឺជាទីផ្សារការងារដ៏ធំទូលាយដែលធ្វើឱ្យប្រជាពលរដ្ឋនៅតាមស្រុកជនបទដែលមានការខ្វះខាតនូវការងារជាហេតុនាំឱ្យពួកគេសម្រេចចិត្តចាកចេញពីលំនៅដ្ឋានរបស់ពួកគេរៀងៗខ្លួនមកកាន់ទីក្រុងដើម្បីស្វែងរកការងារធ្វើ និងដើម្បីផ្គត់ផ្គង់ជីវភាពផងដែរ។ កំណើនដោយសារការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មីដែលពីមុនមកតំបន់នេះជាទីជនបទ គឺកើតឡើងដោយសារសណ្ឋានដីទីក្រុងថ្មីដែលពីមុនជាខេត្ត ឬជនបទ។

**កំណើនប្រជាជននៅថ្ងៃអនាគត៖** ចំនួនប្រជាជនពិភពលោកបានកើនឡើងដល់លើសចំនួន៦១ពាន់លាននាក់ក្នុងពាក់កណ្តាលឆ្នាំ២០០០ទៅហើយ ដោយឡែកបច្ចុប្បន្នកំពុងតែកើនជាមធ្យមចំនួន៧៧លាននាក់ក្នុងមួយឆ្នាំ។ នៅឆ្នាំ២០២៥ខាងមុខ ចំនួនប្រជាជនពិភពលោកនឹងមានការកើនឡើងខ្លាំងនៅចន្លោះពីចំនួន៧៩ទៅ១០៩លានពាន់នាក់។ ទោះបីជាប្រទេសមួយចំនួនលេចចេញនូវអត្ថិភាពនៃអត្រាមរណភាពខ្ពស់ដោយសារតែជំងឺអេដស៍ក៏ដោយ ក៏ចំនួនប្រជាជននៅតែខ្ពស់ដដែល។ យ៉ាងណាមិញចំនួនប្រជាជននៅក្នុងប្រទេសអភិវឌ្ឍនាពេលបច្ចុប្បន្ននេះ គឺមិនត្រូវបានគេរំពឹងថានឹងកើតឡើងក្នុងរយៈពេល៥០ឆ្នាំខាងមុខឡើយដោយសារកម្រិត

[៦] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ (២០១៩-២០២០) ទំព័រទី៥

នៃការមានកូនត្រូវបានគេដាក់ស្ថិតក្រោមកម្រិតកំណត់។ ផ្ទុយទៅវិញចំនួនប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍត្រូវបានព្យាករណ៍ថានឹងកើនឡើងពី៤៩ពាន់លាននាក់នៅក្នុងឆ្នាំ២០០០ និងកើនឡើងដល់៨២ពាន់លាននាក់នៅឆ្នាំ២០៥០។ កំណើនយ៉ាងឆាប់រហ័សនេះត្រូវគេរំពឹងថានឹងកើតឡើងក្នុងចំណោមក្រុមប្រទេសអភិវឌ្ឍចំនួន៤៨ប្រទេស ដែលចំនួនប្រជាជនរបស់ពួកគេត្រូវរំពឹងថានឹងកើនឡើងជិតបីដងក្នុង៥០ឆ្នាំខាងមុខ។ ចំណែកឯអន្តោប្រវេសន៍អន្តរជាតិបានព្យាករណ៍ថានឹងមានកំណើនដង់ស៊ីតេប្រជាជនខ្ពស់នៅក្នុងសតវត្សទី២១នេះ។[10]

**១.១.១.២. ភាពក្រីក្រ**

ការកំណត់អំពីស្ថានភាពក្រីក្រមានការលំបាកនៅក្នុងការកំណត់ណាស់តែជាទូទៅភាពក្រីក្រសំដៅដល់ការដែលជាតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួមប្រទេសភាគច្រើនបានកំណត់ពីភាពក្រីក្រតាមរយៈប្រាក់ចំណូលទាប និងមិនអាចចាយវាយគ្រប់គ្រាន់ក្នុងជីវភាពប្រចាំថ្ងៃឡើយ។ តម្រូវការរូបកាយ ចំណីអាហារលំនៅដ្ឋានការងារធនធានទឹក អគ្គិសនី អនាម័យសុខភាពសង្គមមានការខ្វះខាត។ លើសពីនេះសិទ្ធិសេរីភាពផ្នែកស្មារតី និយាយរួមសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏នៅមានកម្រិតដែរ។ ការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់លើចំណូលទាបបុគ្គលមួយរូបៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជា៖ ចំនួននៃករណីឧក្រិដ្ឋកម្ម អំពើហិង្សាឬអាយុសង្ឃឹមរស់ជាមធ្យមគឺមិនអាចយកមកជំនួសដោយការវាស់ស្ទង់តាមរយៈប្រាក់ចំណូលនេះឡើងដែលជាធម្មតាអ្នកដែលទទួលប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសម្មតថាជនក្រីក្រ។ យ៉ាងហោចណាស់ជាង២០%នៃចំនួនប្រជាជនពិភពលោករស់នៅក្នុងបន្ទាត់នៃក្រីក្រ៩០%ក្នុងចំនួននេះស្ថិតក្នុងប្រទេសអភិវឌ្ឍ។[11]

- **ភាពក្រីក្រនៅជនបទ**

ស្ថិតនៅក្នុងបរិការណ៍នៃបច្ចុប្បន្នភាពនេះ ស្ថានភាពក្រីក្រនៃប្រទេសអភិវឌ្ឍមានការកើនឡើងជាលំដាប់កំណើននេះអាស្រ័យទៅតាមដោយស្ថានភាពសេដ្ឋកិច្ចសង្គម ប្រជារាស្ត្រ ភូមិសាស្ត្រនយោបាយ គ្រោះធម្មជាតិការប្រែប្រួលអាកាសធាតុ និងកង្វះដីបង្កបង្កើនផលជាដើម។ ភាពក្រីក្រនៅជនបទនាំឱ្យមានចំណាកស្រុកទៅទីក្រុង ហើយវានឹងកើនឡើងនៅពេលដែលស្ថានភាពនៅតំបន់កាន់តែលំបាក។ ដូច្នេះការបង្កើនសកម្មភាពសេដ្ឋកិច្ចនៅជនបទ ជាវិធីសាស្ត្រមួយមានប្រសិទ្ធិភាពដើម្បីគ្រប់គ្រងការធ្វើចំណាកស្រុកនេះ។

- **ភាពក្រីក្រនៅទីក្រុង**

កាលណាមានភាពក្រីក្រនៅទីក្រុង គឺពិតជាបង្កផលពិបាកយ៉ាងខ្លាំង។ ជាទូទៅយើងពុំមាននូវលក្ខណៈសមភាពទេ កាលណាប្រសិនជាយើងធ្វើការប្រៀបធៀបពីភាពក្រីក្រដោយការដាក់បន្ទាត់មួយក្រិតស្មើគ្នានោះ។ ឧទាហរណ៍៖ ការប្រើប្រាស់នូវថវិកា៣លានដុល្លារសហរដ្ឋអាមេរិកដូចគ្នាតែបុគ្គលម្នាក់នោះនៅជនបទ ចំណែក

[10] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ (២០១៩-២០២០) ទំព័រទី៥
[11] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ (២០១៩-២០២០) ទំព័រទី៦

បុគ្គលម្នាក់ទៀតនៅទីក្រុងមិនអាចស្មើគ្នាទេនៅក្នុងការចំណាយលុយ។ មូលហេតុដោយសារនៅក្នុងទីក្រុងមានការចំណាយខ្ពស់ជាងជនបទដាច់ឆ្ងាយណាស់។ ស្របពេលជាមួយគ្នានេះអ្នករស់នៅតាមជនបទមានឱកាសស្វែងរកការចិញ្ចឹមជីវិតតាមរយៈទទួលអំណោយភោគផលធម្មជាតិច្រើនជាងអ្នកនៅក្នុងទីក្រុង។[12]

ជារួមប្រសិនបើមានភាពក្រីក្រនៅក្នុងទីក្រុង ហើយអាជ្ញាធរគ្រប់ជាន់ថ្នាក់ត្រូវតែបង្កើតឱ្យមានសេវាកម្មគ្រប់វិស័យ ដើម្បីទាក់ទាញឱ្យអ្នកវិនិយោគនានា បង្កើតគ្រឹះស្ថាន រោងចក្រ សហគ្រាស ឬសេវាកម្មផ្សេងៗនៅក្នុងទីក្រុងដើម្បីឱ្យប្រជាពលរដ្ឋនៅក្នុងទីក្រុងមានការងារធ្វើ ហើយបានជួយប្រជាជនដែលរស់នៅទីជនបទកំពុងជួបនូវភាពក្រីក្រខ្វះខាតការងារធ្វើផងដែរ។ ដូច្នេះភាពក្រីក្រនេះក៏ជាមូលហេតុមួយដែលនាំឱ្យមានការរៀបចំក្រុង។

**១.១.១.៣. ចរាចរណ៍**

បញ្ហាចរាចរណ៍ គឺជាកត្តាមួយដែលនាំឱ្យមានការរៀបចំក្រុង និងនាំឱ្យប្រទេសជាតិមានការអភិវឌ្ឍជឿនលឿនទៅមុខជាលំដាប់ផងដែរ។ កាលណាប្រទេសមួយមានបញ្ហាកកស្ទះចរាចរណ៍នៅក្នុងទីក្រុង ហើយពិតណាស់វានាំឱ្យមានគុណវិបត្តិសម្រាប់ប្រជាពលរដ្ឋដូចជា ខាតបង់សេដ្ឋកិច្ច ប៉ះពាល់សុខភាព មិនគោរពច្បាប់ចរាចរណ៍ ថែមទាំងមានផលប៉ះពាល់ទៅដល់បរិស្ថានតាមរយៈផ្សែងបំពង់ស៊ីម៉ាំងរថយន្ត រថយន្តក្រុង រថយន្តដឹកទំនិញផ្សេងៗ។ មិនតែប៉ុណ្ណោះនៅពេលដែលមានការកកស្ទះចរាចរណ៍នោះម៉ូតូ និងរថយន្ត គឺម៉ាស៊ីនមានការបញ្ចេះរហូតដោយមិនអាចពន្លត់បាន។ ជាក់ស្តែងបញ្ហាកកស្ទះចរាចរណ៍ នៅក្នុងទីក្រុងកើតចេញមកពីកត្តាបីយ៉ាង៖

- **កត្តាមនុស្ស៖** មនុស្សកើនឡើងច្រើន មនុស្សប្រើប្រាស់មធ្យោបាយធ្វើដំណើរតាមដងផ្លូវរៀងៗខ្លួនដែលបណ្តាលឱ្យមានបញ្ហាដូចជាការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ ហើយគ្រោះថ្នាក់ចរាចរណ៍របស់មនុស្សទៀតសោតកើតចេញពីការមិនគោរពច្បាប់ មិនគោរពភ្លើងសញ្ញា ស្លាកសញ្ញា បើកបរមិនយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមកជាដើម។
- **កត្តាយានយន្ត៖** នៅក្នុងប្រទេសកម្ពុជាសម្បូរដោយយានយន្តមួយទឹកៗមកពីក្រៅប្រទេសលក់សម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ជាមធ្យោបាយធ្វើដំណើរក៏ជាហេតុនាំឱ្យមានផលប៉ះពាល់ដល់បរិស្ថានយ៉ាងខ្លាំងផងដែរ។
- **កត្តាផ្លូវ៖** មិនទាន់ឆ្លើយតបទៅតាមតម្រូវការ (ទីរួមខេត្ត និងក្រុង) ផ្លូវពុំមានស្តង់ដា (មានលក្ខណៈតូចផ្លូវជួសជុលច្រើនដង មិនមានផ្លូវអាកាស មិនមានស្ថានសម្រាប់អ្នកថ្មើរជើង) ។

ជាក់ស្តែងនៅក្នុងឆ្នាំ២០១៧ មានរថយន្តគ្រប់ប្រភេទសរុបចំនួន៤៤២៩៧១គ្រឿង និងទោចក្រយានយន្តគ្រប់ប្រភេទមានចំនួន១៦០១៤៥១គ្រឿង និងប្រជាពលរដ្ឋមានរហូតដល់ចំនួន១៧លាននាក់។ ក្រៅពីបញ្ហា

[12] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ (២០១៩-២០២០) ទំព័រទី៧

ការកើនឡើងនៃយានយន្ត ហេដ្ឋារចនាសម្ព័ន្ធផ្លូវក៏មានបញ្ហាចោទដែលនាំឱ្យមានការកកស្ទះចរាចរណ៍ផងដែរ ដោយសារផ្លូវក្នុងក្រុងមានភាពទ្រុឌទ្រោម និងតូចចង្អៀតពិបាកធ្វើដំណើរ មានការប្រេះស្រាំ ខ្វះការថែទាំ រថយន្តដឹកទំនិញលើសទម្ងន់ យកផ្លូវថ្នល់ជាចំណត ប្រជាពលរដ្ឋខ្វះការយល់ដឹងពីការអនុវត្តច្បាប់ចរាចរណ៍ និងមានការខ្វះខាតនូវផ្លូវបំភ្លឺគ្រប់ផ្លូវ និងច្រកផ្លូវជាច្រើន។ ដូច្នេះហើយកត្តាទាំងអស់នេះជាហេតុនាំឱ្យមានការរៀបចំក្រុងដើម្បីជាភាពងាយស្រួលដល់ប្រជាពលរដ្ឋ ជាពិសេសភ្ញៀវទេសចរជាតិ និងអន្តរជាតិផងដែរ។

**១.១.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

ដើម្បីធានាដល់ការរស់នៅឱ្យមានការការពារសុវត្ថិភាព ដល់ប្រជាពលរដ្ឋអាជ្ញាធរគ្រប់ជាន់ថ្នាក់នៅក្នុងខេត្តក្រុងត្រូវយកចិត្តទុកដាក់ជាខ្លាំងនូវការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈជូនដល់ប្រជាពលរដ្ឋដែលអនុវត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងផែនការណែនាំស្តីពីការចាត់តាំងនូវការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដែលមានលក្ខណៈសម្បត្តិរហូតដល់ទៅ៥យ៉ាង។

នៅក្នុងឆ្នាំ២០២១នាពេលបច្ចុប្បន្នរាជរដ្ឋាភិបាលបានធ្វើការរៀបចំនូវការកែលម្អលក្ខណៈសម្បត្តិគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពបន្ថែមរហូតដល់៦ចំណុចមានដូចជា៖

- គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- ផ្តល់សេវាសាធារណៈជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត
- គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី កុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង
- មានសណ្តាប់ធ្នាប់ល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍
- ដោះស្រាយវិវាទការនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាពមានអនាម័យ
- មានសោភ័ណភាពល្អ និងមានបរិស្ថានល្អឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងជំងឺឆ្លងរាលត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព។[13]

ចំពោះការអនុវត្តនូវគោលនយោបាយភូមិ-ឃុំ-សង្កាត់ក្នុងគោលបំណងបន្តកសាង និងពង្រឹងការពារនូវសន្តិសុខ សណ្តាប់ធ្នាប់សង្គម ទាំងផ្លូវកាយ ផ្លូវចិត្ត លើកកម្ពស់អនាម័យ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ និងគ្រប់គ្រង ទប់ស្កាត់ កាត់បន្ថយគ្រោះមហន្តរាយ និងជំងឺរាលត្បាតនៅគ្រប់កាលៈទេសៈព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅតុលាការនៅក្នុងភូមិ-ឃុំ-សង្កាត់។ ដើម្បីបង្កភាពអនុគ្រោះទៅដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើតល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

[13] គេហទំព័រ http://www.interior.gov.kh/news/detail/2225 ដកស្រង់ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២

បន្ថែមពីនេះទៅទៀតនោះ កសាងកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ព្រមទាំងឱ្យមានកិច្ចសហការដោយមានការចូលរួមជាមួយសមត្ថកិច្ចពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទាំងប្រទេស។

### ១.១.២. រចនាសម្ព័ន្ធក្រុងបាត់ដំបង

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុម័តកាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ មាត្រា១៤០ បានចែងថាគណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូបទៅប្រាំ(០៥)រូប ចំនួនជាក់ស្តែងនៃគណៈអភិបាលសម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[14] ប៉ុន្តែដោយសារតម្រូវការចាំបាច់ក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋមូលដ្ឋានឱ្យកាន់តែប្រសើរថែមទៀតនោះការពង្រឹងស្ថាប័ន និងធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិពិតជាមានសារៈសំខាន់ ដើម្បីធានារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗកាន់តែមានថាមពល និងសក្តានុពលក្នុងការរួមចំណែកសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងគោលបំណងប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យម និងខ្ពស់នៅឆ្នាំ២០៣០ខាងមុខ។ មាត្រា១៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖ មាត្រា១៤០ថ្មីបានចែងថា គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនដប់មួយ(១១)រូប។ គណៈអភិបាលខេត្តមានចំនួនពីប្រាំពីរ(០៧)រូបទៅដប់មួយ(១១)រូប។ គណៈអភិបាលក្រុង ស្រុក ខណ្ឌ មានចំនួនពីប្រាំ(៥)រូបទៅប្រាំពីរ(៧)រូប។ ចំនួនជាក់ស្តែងនៃគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[15]

ដោយឡែកនៅក្នុងក្រុងបាត់ដំបង គឺមាននូវអភិបាលក្រុង០១រូបអមដោយអភិបាលរងចំនួន០៤រូបដែលជាជំនួយការ។[16] អភិបាល និងអភិបាលរងក្រុង ត្រូវរួមគ្នាដឹកនាំ គ្រប់គ្រងកិច្ចការរដ្ឋបាលដែនដី ការពារសន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ នៅក្នុងក្របខ័ណ្ឌនៃភូមិសាស្ត្រក្រុងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានដែលមានតម្លៃជាធរមាន និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

---

[14] មាត្រា១៤០ នៃព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[15] ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨

[16] ប្រកាសលេខ៣៤៨ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០០ ស្តីពីតួនាទីភារកិច្ច របៀបរបបការងាររបស់ក្រសួងមហាផ្ទៃ

### ១.១.២.១. ក្រុមប្រឹក្សាក្រុង




តារាងទី២៖ រចនាសម្ព័ន្ធក្រុមប្រឹក្សាក្រុងបាត់ដំបង

➢ **ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ទំនាក់ទំនងសាធារណៈ និងការងារពិធីការគ្រប់គ្រង និងថែរក្សារដ្ឋបាលក្រុងតាមការកំណត់
- ការងារស្ថិតិប្រជាពលរដ្ឋ និងការងារអគ្រានុកូលដ្ឋាន
- ការងារបុគ្គលិក ក្របខណ្ឌ បៀវត្សរ៍ និងកម្រៃផ្សេងៗរបស់មន្ត្រីបុគ្គលិកសាលាក្រុង
- សហការរៀបចំនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងលក្ខខណ្ឌការងារមន្ត្រី បុគ្គលិកសាលាក្រុង
- ការងារហិរញ្ញវត្ថុ និងគ្រប់គ្រងទ្រព្យសម្បត្តិសាលាក្រុង
- សិក្សា លើកយោបល់លើការបង្កើត កែសម្រួល និងការរំសាយការិយាល័យចំណុះសាលាក្រុង
- ការបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រីបុគ្គលិកសាលាក្រុង
- រៀបចំសេចក្តីព្រាង របៀបវារៈ ខ្លឹមសារសម្រាប់របៀបវារៈនីមួយៗ និងឯកសារកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាសាលាក្រុង
- រៀបចំ និងបែងចែកលិខិតប្រជុំ ការរៀបចំទីកន្លែងប្រជុំ កំណត់គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្រុង
- ទទួល និងការបែងចែកលិខិតស្នាមឯកសារនានាឱ្យបានត្រឹមត្រូវទៅដល់សមាជិកក្រុមប្រឹក្សាក្រុង អភិបាលក្រុង អភិបាលរងក្រុង និងរដ្ឋបាលក្រុងព្រមទាំងក្រសួងស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធ
- រក្សាទុកដាក់ឱ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារលិខិតបទដ្ឋានគតិយុត្តទាំងអស់របស់ក្រុមប្រឹក្សាក្រុង គណៈអភិបាល និងរដ្ឋបាលក្រុង
- រៀបចំ និងបិទផ្សាយព័ត៌មានលើក្តារព័ត៌មាន ស្វះស្វែងរកមធ្យបាយ ស្វែងមធ្យោបាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងក្រុង
- សហការក្នុងការត្រៀមរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់តាមសង្កាត់នានាក្នុងក្រុង
- ជំរុញ និងអនុវត្តកិច្ចការពាក់ព័ន្ធ ការបញ្ច្រៀបយេនឌ័រ និងបង្កើនសិទ្ធអំណាចស្ត្រីអនុវត្តនូវ កិច្ចការផ្សេងៗទៀតតាមការប្រគល់របស់នាយករដ្ឋបាលរបស់សាលាក្រុង និងតាមការកែតម្រូវរបស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។[17]

[17] មាត្រា១៥ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

➢ **អង្គភាពលទ្ធកម្ម**

- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ការផ្ដល់ឯកសារដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើដេញថ្លៃ ការរៀបចំទីកន្លែង និងការរៀបចំបើកសំណើដេញថ្លៃ
- ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្ដីពីការបើកសំណើដេញថ្លៃ
- ការរៀបចំ និងការសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា
- ការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
- ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្ដីពីការអនុវត្តកិច្ចលទ្ធកម្ម
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[18]

➢ **ការិយាល័យគ្រប់គ្រងធនធានមនុស្ស**

- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់រដ្ឋបាលក្រុង
- ការបណ្ដុះបណ្ដាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលក្រុង
- ការគ្រប់គ្រងបុគ្គលិកផ្សេងទៀតតាមការផ្ទេរសិទ្ធិអំណាចពីរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[19]

➢ **ការិយាល័យផែនការ និងគាំទ្រសង្កាត់**

- ការរៀបចំ និងការអនុវត្តនូវផែនការអភិវឌ្ឍប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍនានារបស់រដ្ឋបាលក្រុង
- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍនានារបស់រដ្ឋបាលក្រុង
- ការងារស្ថិតិប្រជាជន
- ការគាំទ្រ ការសម្របសម្រួល និងការតាមដាន ត្រួតពិនិត្យ វាយតម្លៃរដ្ឋបាលសង្កាត់ក្នុងក្រុង
- លើការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល និងគម្រោងនានារបស់រដ្ឋបាលសង្កាត់ក្នុងក្រុង

[18] មាត្រា១៦ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
[19] មាត្រា១៧ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

- ការណែនាំ និងការជំរុញការប្រមូលទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ក្រុងតាមការកំណត់
- ការគ្រប់គ្រង និងការស្វែងរកការគាំទ្រការកែច្នៃទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ក្រុង
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងក្រុមប្រឹក្សាសង្កាត់តាមតម្រូវការចាំបាច់
- ការគាំទ្របច្ចេកទេសលើការងាររដ្ឋបាល និងហិរញ្ញវត្ថុដល់រដ្ឋបាលសង្កាត់
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់រដ្ឋបាលសង្កាត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[20]

➢ **ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង**

- ការត្រួតពិនិត្យលើការអនុវត្តតាមច្បាប់ ដីកា លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវានានាដែលបានកំណត់ជាធរមាន
- ការត្រួតពិនិត្យទៅលើការងារផ្សេងៗដូចជា ការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង
- ការត្រួតពិនិត្យការអនុវត្តវិន័យ បទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ និងម៉ោងបំពេញការងាររបស់បុគ្គលិករដ្ឋបាលក្រុង
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[21]

➢ **ការិយាល័យលេខាធិការក្រុមប្រឹក្សា**

- ការរៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា
- ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា
- ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នានារបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង ការថែរក្សា និងការទុកដាក់ឯកសារនានារបស់ក្រុមប្រឹក្សា
- ការបិទផ្សាយ និងការផ្សព្វផ្សាយនូវសេចក្តីសម្រេច និងឯកសារនានារបស់ក្រុមប្រឹក្សា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង។[22]

➢ **ការិយាល័យអប់រំ យុវជន និងកីឡា**

- ការអប់រំកុមារតូច
- ការអប់រំបឋមសិក្សា

[20] មាត្រា១៨ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

[21] មាត្រា១៩ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

[22] មាត្រា២០ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

- ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ការអប់រំក្រៅប្រព័ន្ធ
- ការអភិវឌ្ឍយុវជន
- ការអប់រំកាយ និងកីឡា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[23]

➢ **ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល**

- ការងាររៀបចំដែនដី និងនគរូបនីយកម្ម
- ការងារភូមិបាល
- ការងារសំណង់
- ការងារលំនៅដ្ឋាន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[24]

➢ **ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន**

- ការសិក្សាស្រាវជ្រាវ ការរៀបចំ និងការផ្តល់យោបល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលក្រុង
- ការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដល់មន្ត្រី បុគ្គលិក និងប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង
- ការផ្តល់ប្រឹក្សាយោបល់ផ្លូវច្បាប់ដល់ប្រជាពលរដ្ឋ
- ការរៀបចំការបណ្តុះបណ្តាលជំនាញសម្រុះសម្រួល និងច្បាប់ដល់រដ្ឋបាលសង្កាត់ក្នុងក្រុង
- ការទទួលពាក្យបណ្តឹង និងការសម្រុះសម្រួលវិវាទនៅមូលដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ច របស់រដ្ឋបាលក្រុងស្របតាមច្បាប់កំណត់
- ការពិនិត្យនីត្យានុកូលភាពទៅលើដីកា និងសេចក្តីសម្រេចនានារបស់រដ្ឋបាលសង្កាត់ក្នុងក្រុងតាមគោលការណ៍កំណត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[25]

---

[23] មាត្រា២១ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

[24] មាត្រា២២ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

[25] មាត្រា២៣ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

- **ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្ដាប់ធ្នាប់សាធារណៈ**
  - ការងារសាធារណការ និងដឹកជញ្ជូន
  - ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
  - ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
  - ការគ្រប់គ្រងផ្សែង សំឡេង ក្លិន និងការបំពុលបរិយាកាស
  - ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ
  - ការដាំ ការគ្រប់គ្រង និងការថែទាំដើមឈើ និងសួនច្បារសាធារណៈ
  - ការគ្រប់គ្រងភ្លើងបំភ្លឺទីសាធារណៈ
  - ការគ្រប់គ្រងចំណតយានយន្តសាធារណៈ
  - ការងារសណ្ដាប់ធ្នាប់សាធារណៈ
  - ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[26]
- **ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍសហគមន៍**
  - ការងារឧស្សាហកម្ម និងសិប្បកម្ម
  - ការងាររ៉ែ និងថាមពល
  - ការងារទេសចរណ៍
  - ការងារធនធានទឹក
  - ការងារអភិវឌ្ឍជនបទ
  - ការងារពាណិជ្ជកម្ម
  - ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  - ការងារប្រៃសណីយ៍ និងទូរគមនាគមន៍
  - ការងារអភិវឌ្ឍសហគមន៍
  - ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[27]
- **ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម**
  - ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  - ការងារសុខាភិបាល

[26] មាត្រា២៤ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
[27] មាត្រា២៥ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

- ការងារកិច្ចការនារី
- ការងារធម្មការ និងសាសនា
- ការងារ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ការងារវប្បធម៌ និងវិចិត្រសិល្បៈ
- ការងារគ្រោះមហន្តរាយ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[28]

➢ **ការិយាល័យច្រកចេញចូលតែមួយ**

- ការទទួលនិងការផ្ដល់សេវារដ្ឋបាលនានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង
- ការប្រមូល និងការបង់កម្រៃសេវារដ្ឋបាលតាមគោលការណ៍ និងនីតិវិធីកំណត់
- ការផ្ដល់ព័ត៌មាននានា និងការផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនឹងការផ្ដល់សេវារដ្ឋបាល
- ការទុកដាក់ ការថែរក្សា និងការគ្រប់គ្រងឯកសារនានា ពាក់ព័ន្ធនឹងការផ្ដល់សេវារដ្ឋបាល
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[29]

➢ **គ្រឹះស្ថានបឋមសិក្សាសាធារណៈ**

- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន
- គ្រប់គ្រង និងប្រើប្រាស់បុគ្គលិកអប់រំបឋមសិក្សា
- គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលារៀន
- គ្រប់គ្រង ចាត់ចែង និងថែទាំសៀវភៅសិក្សាគោល
- គ្រប់គ្រងសំណង់អគារ សាងសង់ និងជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀន
- គ្រប់គ្រងសិស្សសាលាបឋមសិក្សា
- គ្រប់គ្រងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការអភិវឌ្ឍកម្រងសាលារៀន
- គ្រប់គ្រងកម្មវិធីគាំទ្រការអប់រំបឋមសិក្សា
- ការងារអប់រំកាយ និងកីឡា
- អភិវឌ្ឍវិស័យអប់រំដោយសហការជាមួយក្រសួងអប់រំ យុវជននិងកីឡា និងដៃគូរអភិវឌ្ឍនានា
- បំពេញការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[30]

---

[28] មាត្រា២៦ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

[29] មាត្រា២៧ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

[30] មាត្រា៦៥ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

- **គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ**
  - រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន
  - គ្រប់គ្រង និងប្រើប្រាស់បុគ្គលិកអប់រំមត្តេយ្យសិក្សា
  - គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលាមត្តេយសិក្សា
  - គ្រប់គ្រងសំណង់អគារ សាងសង់ និងជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀន
  - គ្រប់គ្រងសិស្សមត្តេយ្យសិក្សា
  - គ្រប់គ្រងកម្មវិធីគាំទ្រការអប់រំកុមារតូច
  - អភិវឌ្ឍវិស័យអប់រំដោយសហការជាមួយក្រសួងអប់រំ យុវជននិងកីឡា និងដៃគូរអភិវឌ្ឍនានា
  - បំពេញការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[31]

### ១.១.២.២. គណៈអភិបាលក្រុង




តារាងទី៣៖ រចនាសម្ព័ន្ធគណៈអភិបាលក្រុង

សាលាក្រុងបាត់ដំបង គឺត្រូវបានដឹកនាំដោយអភិបាលក្រុងចំនួន០១រូប និងអមដោយអភិបាលរងចំនួន ០៤រូប។ នៅក្នុងសាលាក្រុងគណៈអភិបាល និងអភិបាលរងចំនួន០៤រូបត្រូវទទួលបន្ទុកដូចជា៖

- **គណៈអភិបាលក្រុងបាត់ដំបង**
  - ដឹកនាំការងាររួម
  - ដឹកនាំផ្ទាល់លើកិច្ចការទូទៅ

[31] មាត្រា៦៥ នៃអនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

- ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ
- កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ។

ចំណែកឯអភិបាលរងក្រុង០៤រូបទៀតទទួលបន្ទុកការងារមួយចំនួនមានដូចខាងក្រោម៖

➢ **អភិបាលរងក្រុង០១រូប៖** ទទួលបន្ទុកលើការងារការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

- កិច្ចការអប់រំយុវជន និងកីឡា
- កិច្ចការព័ត៌មាន
- កិច្ចការស្ថិតិ និងអត្រានុកូលដ្ឋាន
- កិច្ចការនារី កុមារ និងសុខាភិបាល
- ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ
- កិច្ចការវេទិកាសាធារណៈហិរញ្ញវត្ថុ
- កិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កិច្ចការធនាគារ និងរតនាគារ រដ្ឋបាល ពន្ធដារ សាខាកាំកុងត្រូល
- កិច្ចការសាខាគយរដ្ឋាករក្រុង
- កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍
- កិច្ចការអង្គការក្រៅរដ្ឋាភិបាល។[32]

➢ **អភិបាលរងក្រុង០១រូប៖** ទទួលបន្ទុកលើការងារការិយាល័យផែនការ និងអភិវឌ្ឍ

- កិច្ចការច្បាប់ និងសិទ្ធិមនុស្ស
- កិច្ចការវិនិយោគ និងពាណិជ្ជកម្ម
- កិច្ចការអភិវឌ្ឍជនបទ និងអង្គភាពអគ្គិសនី
- កិច្ចការលទ្ធកម្ម
- កិច្ចការសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ សហគមន៍ សមាគមន៍
- កិច្ចការកម្មវិធីផែនការអភិវឌ្ឍ០៣ឆ្នាំរំកិលក្រុង
- កិច្ចការគ្រប់គ្រងផ្សាររដ្ឋ និងផ្សារឯកជន
- កិច្ចការធនធានទឹក ឧតុនិយម និងធារាសាស្ត្រ

[32] សេចក្តីសម្រេចលេខ២២សសរ ស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលក្រុងបាត់ដំបង

- កិច្ចការរ៉ែ ថាមពល
- កិច្ចការបរិស្ថាន និងគ្រប់គ្រង សំណល់រឹង និងរាវ
- កិច្ចការសាធារណការ និងដឹកជញ្ជូន។

➢ **អភិបាលរងក្រុង០១រូប៖** ទទួលបន្ទុកលើការងារការិយាល័យអន្តរវិស័យ

- កិច្ចការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងភូមិបាលក្រុង
- កិច្ចការសហការអនុវត្តសេចក្តីសម្រេចរបស់តុលាការ
- កិច្ចការពាណិជ្ជកម្ម និងទទួលជួយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- កិច្ចការគ្រោះមហន្តរាយ
- កិច្ចការការិយាល័យច្រកចេញចូលតែមួយ
- កិច្ចការការិយាល័យអនុសាខាកាកបាទក្រហម
- កិច្ចការធម្មការ និងសាសនា។

➢ **អភិបាលរងក្រុង០១រូប៖** ទទួលបន្ទុកលើការងារការិយាល័យ

- កិច្ចការទេសចរណ៍
- កិច្ចការវប្បធម៌ និងវិចិត្រសិល្បៈ
- កិច្ចការសង្គមកិច្ច អតីតយុទ្ធជន និងយុទ្ធនីតិសម្បទា
- កិច្ចការឧស្សាហកម្ម និងសិប្បកម្ម
- កិច្ចការគ្រប់គ្រងទីតាំងយានយន្តជួសជុលរថយន្ត
- ការដោះស្រាយបាតុកម្ម កូដកម្ម និងការងារគ្រប់គ្រងផ្ទះជួល។[33]

## ១.២. បច្ចុប្បន្នភាព និងទិសដៅអនាគតនៃការរៀបចំក្រុងបាត់ដំបង

### ១.២.១. បច្ចុប្បន្នភាពនៃការរៀបចំសណ្តាប់ធ្នាប់

បច្ចុប្បន្នក្រុងបាត់ដំបងមានការរៀបចំ និងការអភិវឌ្ឍទៅលើវិស័យជាច្រើន ប៉ុន្តែនៅក្នុងខណៈនេះនាងខ្ញុំសូមលើកយកតែមួយចំនួនប៉ុណ្ណោះ ដើម្បីបកស្រាយដែលក្នុងនោះរួមមានការអភិវឌ្ឍទៅលើហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍសំណង់នានា និងការរៀបចំសណ្តាប់ធ្នាប់របៀបរៀបរយក្នុងក្រុង។

ក្រុងបាត់ដំបង គឺជាក្រុងមួយក្នុងចំណោមក្រុងស្រុកទាំង១៨របស់ខេត្តបាត់ដំបង ដែលជាទីប្រជុំជនផងនោះ ជាហេតុនាំឱ្យមានប្រជាពលរដ្ឋរស់នៅប្រកបរបរច្រើនប្រភេទ។ ជាងនេះទៅទៀតក្នុងក្រុងបាត់ដំបងក៏ឃើញថាបច្ចុប្បន្នសម្បូរទៅដោយសំណង់អគារខ្ពស់ៗ លំនៅស្ថាន សណ្ឋាគារ ផ្ទះសំណាក់ រមណីយដ្ឋាន សួនច្បារ

[33] សេចក្តីសម្រេចលេខ២២សសរ ស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលក្រុងបាត់ដំបង

តាមដងផ្លូវ ផ្សារទំនើប ហាងទំនិញ សង់អមសងខាងផ្លូវដងវិថីតូចធំខ្វាត់ខ្វែងអាចទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលមកទស្សនា និងទិញទំនិញគ្រប់ប្រភេទ។ ក្រៅពីនេះទៅទៀតក្រុងបាត់ដំបងហាក់បីជាទីក្រុងមួយដែលសម្បូរទៅដោយកន្លែងកំសាន្ត លំហែកាយ របស់ប្រជាពលរដ្ឋព្រមទាំងមានការដាក់តាំងលក់នូវទំនិញប្រើប្រាស់ទំនើបៗ និងភោជនីយដ្ឋានដ៏សម្បូរបែបទៀតផង។ មិនតែប៉ុណ្ណោះនៅមានសំណង់អគារតូចធំរបស់ស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានឯកជន អង្គការក្រៅរដ្ឋាភិបាលជាច្រើនដែលបោះទីតាំងនៅក្នុងសង្កាត់ទាំង១០របស់ក្រុងបាត់ដំបង និងបង្កឱ្យមានលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍមូលដ្ឋានដើម្បីឆ្លើយតបនូវតម្រូវការជាក់ស្តែងរបស់មូលដ្ឋាន និងសំណូមពររបស់ប្រជាពលរដ្ឋ។

### ១.២.១.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

បណ្តាហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងបាត់ដំបងដូចជា កសាងផ្លូវ ប្រព័ន្ធលូបង្ហូរទឹក ការដាក់បង្គោលភ្លើងសាធារណៈ និងការកសាងនូវស្ពានពិតជាមានសារៈប្រយោជន៍ដល់ប្រជាពលរដ្ឋនៅក្នុងប្រជាពលរដ្ឋនៅក្នុងក្រុងនោះមានភាពងាយស្រួលក្នុងការធ្វើដំណើរ និងងាយស្រួលប្រកបអាជីវកម្ម បន្ថែមពីនេះធ្វើឱ្យក្រុងបាត់ដំបងមានសណ្តាប់ធ្នាប់ និងជួយកាត់បន្ថយការកកស្ទះលូ និងកកស្ទះចរាចរណ៍នៅតាមដងផ្លូវបានមួយចំណែកធំ។

➢ **ការកសាងផ្លូវ**

ការអនុវត្តគម្រោងកសាងផ្លូវនាពេលបច្ចុប្បន្ននេះ បាននាំមកនូវការអភិវឌ្ឍជាច្រើនដោយមានការកាត់បន្ថយការរាំងស្ទះចរាចរណ៍ដល់ប្រជាពលរដ្ឋបានមួយកម្រិតបន្ថែមទៀតពីព្រោះនាពេលបច្ចុប្បន្ននេះនៅក្នុងក្រុងមានការកើនឡើងនូវកំណើនប្រជាជន និងកំណើនការសាងសង់លំនៅដ្ឋានជាច្រើន។ បន្ថែមពីនេះមានការកើនឡើងនូវមធ្យោបាយធ្វើដំណើរដូចជាយានយន្ត និងយានជំនិះផ្សេងៗនៅក្នុងក្រុងបាត់ដំបងនេះ។

– **ស្ថាបនាផ្លូវក្រាលកៅស៊ូ**

- ស្ថាបនាផ្លូវក្រាលកៅស៊ូ១ខ្សែ ស្ថិតក្នុងភូមិវត្តគរ សង្កាត់វត្តគរ ប្រវែង៩០០ម៉ែត្រ
- ស្ថាបនាផ្លូវក្រាលកៅស៊ូ១ខ្សែ ស្ថិតក្នុងភូមិច្រាបក្រសាំង សង្កាត់វត្តគរ ប្រវែង៣០០០ម៉ែត្រ
- ស្ថាបនាផ្លូវក្រាលកៅស៊ូ១ខ្សែ ដែលស្ថិតក្នុងភូមិ១៣មករានិងភូមិអូរខ្ចាយ សង្កាត់ព្រែកព្រះស្តេច ប្រវែង៨៣០ម៉ែត្រ
- ស្ថាបនាផ្លូវក្រាលកៅស៊ូ១ ស្ថិតក្នុងភូមិអង់ សង្កាត់អូចារប្រវែង៥០០ម៉ែត្រ។[34]
- ជួសជុលផ្លូវក្រាលកៅស៊ូ ផ្លូវលេខ១២១ ក្នុងសង្កាត់ស្វាយប៉ោ
- ស្ថាបនាផ្លូវក្រាលកៅស៊ូ១ខ្សែពីផ្លូវស្ពានសម្តេចហ៊ុនសែនទល់នឹងផ្លូវលេខ១ក្នុងសង្កាត់ស្វាយប៉ោ

[34] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទំព័រទី១១

- ស្ពានផ្លូវក្រាលកៅស៊ូ១ខ្សែពីផ្លូវលេខ១៣៣ទល់នឹងផ្លូវលេខ១ក្នុងសង្កាត់ស្វាយប៉ោ មួយខ្សែទៀតក្នុងសាលាខេត្ត
- ជួសជុលផ្លូវក្រាលកៅស៊ូ ផ្លូវប្រឡាយខាំសន ខាងលិចប្រឡាយផ្លូវលេខ១៧៣៤ ពីភូមិអូរតានប់ សង្កាត់ក្ដុលដូនទាវ កាត់ភូមិដាំស្ពៃ សង្កាត់ស្លាកែតដល់រង្វង់មូលពោធិ៍ហ្មស្រី ក្រុងបាត់ដំបង ទំហំ១៨១៩៦ម៉ែត្រការ៉េ
- ជួសជុលផ្លូវក្រាលកៅស៊ូ ផ្លូវលេខ៥៤០ ពីផ្លូវលេខ៥១៥១៧០១ សង្កាត់ចំការសំរោង និងផ្លូវលេខ១៧០១ពីផ្លូវលេខ៥៤០១៧៣៤សង្កាត់ក្ដុលដូនទាវ ប្រវែង១៩៣៩ម៉ែត្រ ទទឹង៥ម៉ែត្រ។[35]

## – ស្ពានផ្លូវបេតុង

- ស្ពានផ្លូវបេតុង១ខ្សែ ស្ថិតនៅភូមិទួលតាឯក សង្កាត់ទួលតាឯក ប្រវែង៥០០ម៉ែត្រ
- ស្ពានផ្លូវបេតុង១ខ្សែ ស្ថិតក្នុងក្រុមទី២ភូមិអូតាគាំ១ សង្កាត់ទួលតាឯក ប្រវែង១៥០ម៉ែត្រ
- ស្ពានផ្លូវបេតុង៣ខ្សែ ស្ថិតនៅក្នុងភូមិចំការសំរោង២ សង្កាត់ចំការសំរោង ប្រវែង១៦០០ម៉ែត្រ ៣កន្លែង
- ស្ពានផ្លូវបេតុងអាមេ១ខ្សែ ស្ថិតនៅក្នុងភូមិអូរតានប់ សង្កាត់ក្ដុលដូនទាវ ប្រវែង៦២០ម៉ែត្រ
- ស្ពានផ្លូវបេតុងអាមេ ស្ថិតនៅក្នុងភូមិកាប់គោថ្មី សង្កាត់អូចារ ប្រវែង៧២៦ម៉ែត្រ
- ស្ពានផ្លូវបេតុងអាមេ ស្ថិតនៅក្នុងភូមិអង់ សង្កាត់អូចារ ប្រវែង១០០០ម៉ែត្រ។[36]
- ជួសជុលផ្លូវក្រាលបេតុង ផ្លូវលេខ៦១០ និងផ្លូវ៦១១ នៅផ្សារកង្កែបយំ សង្កាត់រតនៈ
- ជួសជុលផ្លូវក្រាលបេតុង ផ្លូវលេខ៦០៩.០៧ ស្ថិតនៅប៉ុស្តិ៍វិទ្យុរតនៈ សង្កាត់រតនៈ
- ជួសជុលផ្លូវក្រាលបេតុង ផ្លូវលេខ៦១១ ស្ថិតនៅសង្កាត់រតនៈ
- ជួសជុលផ្លូវក្រាលបេតុងផ្លូវលេខ៣០១ ស្ថិតនៅក្រោយវិទ្យាល័យនេតយ៉ង់ សង្កាត់ព្រែកព្រះស្ដេច
- ជួសជុលផ្លូវក្រាលបេតុង ផ្លូវលេខ៤០១.១៧ ស្ថិតនៅ សង្កាត់អូចារ
- ជួសជុលផ្លូវក្រាលបេតុង៤ខ្សែ ផ្លូវលេខ៥០៣.០១ ផ្លូវលេខ៥៣២ ផ្លូវលេខ៥៣៤.០៩ និងផ្លូវ៥៣៤.១៩ ស្ថិតនៅសង្កាត់អូចារ
- ជួសជុលផ្លូវក្រាលបេតុង ផ្លូវលេខ៥១៨ ពីកែងផ្លូវលេខ៥០៧ដល់មុខពេទ្យហង់ឌីកាប់ ស្ថិតនៅសង្កាត់ចំការសំរោង
- ស្ពានផ្លូវក្រាលបេតុងអាមេ១ខ្សែ ស្ថិតនៅក្នុងសង្កាត់ទួលតាឯក ប្រវែង៣៨២ម៉ែត្រ

[35] សៀវភៅផែនការអភិវឌ្ឍក្រុង៥ឆ្នាំ ក្រុងបាត់ដំបង (២០២០-២០២៤) ទំព័រទី២០

[36] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទំព័រទី១១

- ស្ពានផ្លូវក្រាលបេតុង២ខ្សែ ស្ថិតនៅក្នុងសង្កាត់ព្រែកព្រះស្ដេច ប្រវែង៣៦២ម៉ែត្រ
- ស្ពានផ្លូវក្រាលបេតុង១ខ្សែ ស្ថិតនៅក្នុងសង្កាត់រតនៈ ប្រវែង១៩៣ម៉ែត្រ
- ស្ពានផ្លូវក្រាលបេតុង១ខ្សែ ស្ថិតនៅក្នុងសង្កាត់ចំការសំរោង ប្រវែង១៦៥ម៉ែត្រ
- ស្ពានផ្លូវក្រាលបេតុង១ខ្សែ ស្ថិតនៅក្នុងសង្កាត់ចំការសំរោង ប្រវែង១១០ម៉ែត្រ
- ស្ពានផ្លូវក្រាលបេតុង២ខ្សែ ស្ថិតនៅក្នុងសង្កាត់ក្ដុលដូនទាវ ប្រវែង៥៧៣ម៉ែត្រ
- ស្ពានផ្លូវក្រាលបេតុង១ខ្សែ ស្ថិតនៅក្នុងសង្កាត់អូចារ ប្រវែង២៨១ម៉ែត្រ
- ស្ពានផ្លូវក្រាលបេតុង១ខ្សែ ស្ថិតនៅក្នុងសង្កាត់អូចារ ប្រវែង១១០ម៉ែត្រ។[37]

– **ស្ពានផ្លូវក្រាលក្រួសក្រហម**

- ស្ពានផ្លូវក្រាលក្រួសក្រហម១ខ្សែ ស្ថិតនៅក្នុងសហគមន៍សុខសាន្តត្បូង សង្កាត់ទួលតាឯក ប្រវែង២០០ម៉ែត្រ
- ជួសជុលផ្លូវក្រាលក្រួសក្រហម១ខ្សែ ស្ថិតក្នុងភូមិតាកុយ សង្កាត់ក្ដុលដូនទាវ ប្រវែង១១០០ម៉ែត្រ
- ជួសជុលផ្លូវក្រាលក្រួសក្រហម១ខ្សែ ស្ថិតក្នុងភូមិវត្តគរ សង្កាត់វត្តគរ ប្រវែង៨០០ម៉ែត្រ
- ជួសជុលផ្លូវក្រាលក្រួសក្រហម៣ខ្សែ ស្ថិតក្នុងភូមិវត្តរកា ភូមិបឹងរាំង និងស្ថិតក្នុងភូមិកូនសេក សង្កាត់អូរម៉ាល់ ប្រវែង២០០០ម៉ែត្រ
- ជួសជុលផ្លូវក្រាលថ្មមិចក្រហម៣ខ្សែ ស្ថិតនៅក្នុងភូមិអូរខ្ចាយនិងភូមិចំការឬស្សី សង្កាត់ព្រែកព្រះស្ដេច ប្រវែង៦១០ម៉ែត្រ។[38]

ជាងនេះទៅទៀតដើម្បីចូលរួមរក្សាសណ្ដាប់ធ្នាប់របៀបរៀបរយសុវត្ថិភាពសាធារណៈ និងការពារថែរក្សាផ្លូវថ្នល់ឱ្យបានយូរអង្វែង រដ្ឋបាលខេត្តស្នើឱ្យប្ដូរទីតាំងឃ្លាំងស្ដុកទំនិញដែលមាននៅក្នុងក្រុងបាត់ដំបងទៅផ្លូវវាងក្រុងឱ្យរួចរាល់យ៉ាងយូររយៈពេល០១ឆ្នាំ។ កន្លងមកមានអាជីវករ ពាណិជ្ជករ និងអ្នកប្រកបអាជីវកម្មផ្សេងៗបានធ្វើការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ចូលទៅក្រុងបាត់ដំបងដែលបណ្ដាលឱ្យខូចខាតផ្លូវថ្នល់ និងរងមតិរិះគន់លើអាជ្ញាធរមានសមត្ថកិច្ចពុំធ្វើការទប់ស្កាត់ ឬធ្វើការហាមឃាត់លើការដឹកជញ្ជូនរថយន្តធុនធ្ងន់ទាំងនេះ។ ហេតុនេះរដ្ឋបាលខេត្តបាត់ដំបងនឹងមានវិធានការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់រាល់ការដឹកជញ្ជូនរថយន្តធុនធ្ងន់ចូលមកក្រុងបាត់ដំបង។[39]

---

37 សៀវភៅផែនការអភិវឌ្ឍក្រុង៥ឆ្នាំ ក្រុងបាត់ដំបង (២០២០-២០២៤) ទំព័រទី២០

38 សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទំព័រទី១១

39 សេចក្ដីជូនដំណឹងលេខ១៣៧២/២២ សជណ

- **ការកសាងប្រព័ន្ធលូបង្ហូរទឹក**

ក្រុងបាត់ដំបងមានការស្ថាបនាប្រព័ន្ធបង្ហូរទឹក ដើម្បីកាត់បន្ថយនូវការជន់លិចដែលបណ្តាលមកពីការស្ទះលូមានផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋផងដែរ ដូច្នេះសាលាក្រុងបានយកចិត្តទុកដាក់ដោយធ្វើការស្ថាបនាប្រព័ន្ធថ្មីៗនៅតាមសង្កាត់នីមួយៗនៅក្នុងក្រុង និងជួសជុលនូវលូចាស់ៗដើម្បីជាភាពងាយស្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់មួយចំនួន ដោយគ្មានការបារម្ភភ័យខ្លាចនូវការកកស្ទះប្រព័ន្ធលូ និងជន់លិចទឹកបន្តទៀត ចំពោះការស្ថាបនាប្រព័ន្ធប្រឡាយទាំងនោះមានដូចខាងក្រោម៖

- ដាក់លូមូលរំដោះទឹក១ខ្សែ ប្រវែង៨៣០ម៉ែត្រ ស្ថិតក្នុងភូមិ១៣មករា និងអូរខ្ចាយ សង្កាត់ព្រែកព្រះស្តេច
- ដាក់លូកាត់ផ្លូវ ប្រវែង៨ម៉ែត្រ នៅភូមិវត្តរកា សង្កាត់អូរម៉ាល់
- ដាក់លូរំដោះទឹកចេញពីផ្លូវ ប្រវែង៥៣០ម៉ែត្រ ស្ថិតក្នុងភូមិអង់ សង្កាត់អូចារ
- ស្តារប្រឡាយរំដោះទឹកចេញពីភូមិ ប្រវែង១៣០០ម៉ែត្រ ស្ថិតក្នុងភូមិអង់ សង្កាត់អូចារ
- ស្តារប្រឡាយមេ និងដាក់លូ ប្រវែង១៣១១ម៉ែត្រ ស្ថិតក្នុងភូមិចំការសំរោង១ សង្កាត់ចំការសំរោង
- កាយប្រឡាយស្ទះប្រវែង៥០០ម៉ែត្រ ស្ថិតក្នុងភូមិទួលតាឯក និងភូមិដង្កោទាបសង្កាត់ទួលតាឯក។[40]
- ជួសជុលប្រព័ន្ធលូរំដោះទឹកមុខកាត់១០០ ប្រវែង៣០០ម៉ែត្រ ស្ថិតក្នុងសង្កាត់ស្វាយប៉ោ
- ដាក់លូរំដោះទឹកមុខកាត់១០០ចំនួន១៩០កង់ និងរ៉ឺហ្គាចំនួន៨កន្លែង ស្ថិតនៅក្នុងភូមិកំពង់ក្របីសង្កាត់ស្វាយប៉ោ
- ដាក់លូមុខកាត់៨០ចំនួន៦កង់ និងមុខកាត់៦០ ចំនួន១៣៨កង់ ស្ថិតក្នុងសង្កាត់អូចារ
- ដាក់លូមុខកាត់៨០ និងរ៉ឺហ្គាចំនួន៥១កន្លែងចំនួន៤ខ្សែ ស្ថិតក្នុងសង្កាត់អូចារ
- ស្តារប្រឡាយរំដោះទឹកផ្លូវលេខ៥០៧ ប្រឡាយវត្តលៀប ដោយដាក់លូឆ្លោះនៅតាមផ្លូវចូលទៅផ្ទះប្រជាពលរដ្ឋស្ថិតក្នុងសង្កាត់ចំការសំរោង
- ស្តារប្រឡាយរំដោះទឹកផ្លូវលេខ១៦១២ និងដាក់លូ១០២កង់ រ៉ឺហ្គា៣កន្លែង ខាងលិចផ្សារភ្នំពុយស្ថិតក្នុងសង្កាត់អូចារ
- ស្តារប្រឡាយរំដោះទឹកផ្លូវលេខ៤០៣ ដោយដាក់លូកាត់ផ្លូវចំនួន៦៤កង់ ស្ថិតក្នុងសង្កាត់ទួលតាឯក
- ស្ថាបនាលូរំដោះទឹក២កន្លែង ប្រវែង១២ម៉ែត្រ ស្ថិតក្នុងសង្កាត់ទួលតាឯក
- ស្ថាបនាលូរំដោះទឹក១ខ្សែ ប្រវែង២៨៥ម៉ែត្រ ស្ថិតក្នុងសង្កាត់ទួលតាឯក

[40] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទំព័រទី១០

- សាងសង់លូ១ខ្សែ ប្រវែង៤០០ម៉ែត្រ ស្ថិតក្នុងសង្កាត់រតនៈ
- ដាក់លូរំដោះទឹក ប្រវែង៣២៧ម៉ែត្រ ស្ថិតក្នុងសង្កាត់ស្លាកែត
- ដាក់លូមុខកាត់១០០ មាន១គម្រោង ប្រវែង៦៧៨ម៉ែត្រ ស្ថិតនៅក្នុងសង្កាត់ស្វាយប៉ោ។[41]

➢ **ការកសាងស្ពាន**

ស្ពាន គឺជាមធ្យោបាយយ៉ាងសំខាន់មួយសម្រាប់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរព្រមទាំងជាមធ្យោបាយដ៏សំខាន់ក្នុងការដឹកជញ្ជូនដែលបម្រើវិស័យសេដ្ឋកិច្ចបានមួយផ្នែកធំ។ ក្នុងនោះផងដែរក្រុងបាត់ដំបងក៏មានស្ពានចំនួន៥ដែលសម្រាប់ឱ្យប្រជាពលរដ្ឋឆ្លងកាត់គឺ ស្ពានស្ទឹងសង្កែ ស្ពានថ្មចាស់ ស្ពានសម្ដេចតេជោហ៊ុនសែន ស្ពានសម្ដេចក្រឡាហោមសខេង និងស្ពាន១៣មករា។

ក្នុងនោះផងដែរស្ពានថ្មថ្មី១៣មករា ដែលបានកសាងទន្ទឹមគ្នាជាមួយស្ពានថ្មចាស់អាយុជាង១០០ឆ្នាំក្នុងក្រុងបាត់ដំបងកំពុងត្រៀមដាក់សម្ពោធឱ្យពលរដ្ឋធ្វើដំណើរឆ្លងកាត់។ សមិទ្ធផលស្ពានថ្មថ្មីដតភ្ជាប់ដងស្ទឹងសង្កែ រវាងត្រើយខាងកើត និងខាងលិចកសាងទន្ទឹមគ្នាជាមួយស្ពានបុរាណអាយុកាល១០៣ឆ្នាំដែលចាប់ផ្ដើមដំណើរការសាងសង់តាំងពីដើមខែមករា ឆ្នាំ២០២០ ហើយមកទល់ពេលបច្ចុប្បន្ននេះបានបញ្ចប់គម្រោងស្ទើរតែទាំងស្រុងហើយ នៅសេសសល់ផ្នែកតូចៗមួយចំនួនប៉ុណ្ណោះដូចជាការកែលម្អត្រង់ក្បាលស្ពាន ត្រើយខាងកើត និងខាងលិចខ្លះៗ ដោយចំពោះមុខនេះក្រុមជាងកំពុងពន្លឿន ការរៀបចំខឿនផ្លូវ ដាំស្មៅ ដាំផ្កា ក្នុងសួនកំណាត់ផ្លូវភ្លោះ និងបំពាក់អំពូលភ្លើងជាដើមមុននឹងបើកសម្ពោធដាក់ឱ្យប្រជាពលរដ្ឋប្រើប្រាស់ឆ្លងកាត់ទៅមក។

ស្ពានថ្ម ទើបសាងសង់ថ្មីនេះត្រូវបានសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃដាក់ឈ្មោះថា "ស្ពាន១៣មករា" ឱ្យស្របទៅតាមអត្ថន័យជាថ្ងៃរំដោះទីក្រុងបាត់ដំបងពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ឆ្នាំ១៩៧៩។

ស្ពានថ្មថ្មីនេះដែរ មានទីតាំងស្ថិតនៅប៉ែកខាងត្បូងនៃស្ពានបុរាណដែលមានចន្លោះពីគ្នាចំនួន៦ម៉ែត្រ ប្រវែងបណ្ដោយចំនួន១០០ម៉ែត្រ ទទឹង៨ម៉ែត្រ ប្រើប្រាស់ថវិកាចំនួនជាងកន្លះលានដុល្លារអាមេរិករបស់សប្បុរសជនខ្មែរនៅប្រទេសស្វីសមានស្រុកកំណើតនៅស្រុកបាណន់តាមរយៈការកៀរគរពីសម្ដេចក្រឡាហោម ស ខេង។

ស្ពាន១៣មករានេះ នៅពីក្រោយថ្ងៃដាក់ឱ្យដំណើរជាស្ថាពរ ហើយមិនត្រឹមតែបានផ្ដល់ជាប្រយោជន៍សម្រាប់បងប្អូនប្រជាពលរដ្ឋបានឆ្លងកាត់ទៅមក ដឹកជញ្ជូនកសិផល ទំនិញផ្សេងៗ និងបញ្ជៀសចរាចរណ៍កកស្ទះនៅថ្ងៃបុណ្យទានម្ដងៗនោះទេ ក្រៅពីនេះស្ពានដ៏ស្រស់ស្អាតថ្មីនេះក៏បានផ្ដល់ជាសារៈប្រយោជន៍យ៉ាងសំខាន់ផងដែរក្នុងការទាក់ទាញភ្ញៀវជាតិ អន្តរជាតិ ឱ្យផ្ដោតការចាប់អារម្មណ៍ឡើងលេងគយគន់ទឹកស្ទឹងសង្កែ

[41] សៀវភៅផែនការអភិវឌ្ឍក្រុង៥ឆ្នាំ ក្រុងបាត់ដំបង (២០២០-២០២៤) ទំព័រទី១៩

ចតុរូបអនុស្សាវរីយ៍ និងជាផ្នែកមួយពង្រីកនូវសក្ដានុពលទេសចរណ៍ចម្រុះជាតិសាសន៍ឱ្យមកទស្សនាក្នុងទឹកដីចំណាស់ខេត្តបាត់ដំបងកាន់តែច្រើនឡើង។[42]

### ១.២.១.២. ការអភិវឌ្ឍសំណង់លំនៅដ្ឋាន

ដី គឺជាប្រភពធនធានដ៏មានតម្លៃរបស់ប្រជាពលរដ្ឋកម្ពុជាសម្រាប់ការអភិវឌ្ឍ។ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា គឺធានាថាដីទាំងអស់ត្រូវបានរៀបចំ ប្រើប្រាស់ និងបែងចែកប្រកបដោយសមធម៌ តម្លាភាព ប្រសិទ្ធិភាព និងចីរភាព ដើម្បីចូលរួមចំណែកធ្វើឱ្យសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ ការធានាស្បៀង ការការពារបរិស្ថាន និងធនធានធម្មជាតិ និងការអភិវឌ្ឍសង្គមកិច្ច សេដ្ឋកិច្ច ការកាន់កាប់ដីកម្មសិទ្ធ ការវិនិយោគ និងការសាងសង់នៅលើកម្មសិទ្ធិដីឯកជន ដីសាធារណៈ និងកម្មសិទ្ធិផ្សេងទៀតត្រូវបានរៀបចំ និងគ្រប់គ្រងស្របតាមលក្ខណៈបច្ចេកទេសកាន់តែប្រសើរឡើង។ ក្រុងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងទីប្រជុំជនក្រុង និងមុខងារជាមជ្ឈមណ្ឌលសេដ្ឋកិច្ចកណ្ដាល និងបណ្ដាទីប្រជុំជន។ ជាមួយគ្នានេះដែរក្រុមការងារប្លង់គោលបានរៀបចំជាឯកសារផែនការគ្រប់គ្រងដីធ្លីទូទាំងក្រុងដើម្បីធានានូវការប្រើប្រាស់ដីធ្លីឱ្យចំទិសដៅ និងប្រកបដោយការការពារធនធានធម្មជាតិ។ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធក្នុងនោះយើងអនុវត្តបាន និងកំពុងបន្តសកម្មភាពយ៉ាងសកម្ម ឬឯការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំបានអនុវត្តជាប្រចាំផងដែរ។

នាពេលបច្ចុប្បន្ននេះនៅក្នុងក្រុងបាត់ដំបងមានការអភិវឌ្ឍខ្លាំង ទៅលើវិស័យសំណង់លំនៅដ្ឋាននៅក្នុងនោះមានបុរី លំនៅដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ ក្លឹបកំសាន្ត ភោជនីយដ្ឋាន ផ្សារទំនើបៗ សួនច្បារ មជ្ឈមណ្ឌលកំសាន្តពាណិជ្ជកម្ម មិនតែប៉ុណ្ណោះមានសំណង់ស្ថាប័នរដ្ឋជាច្រើន ដែលបានសាងសង់នៅក្នុងក្រុងបាត់ដំបង។ នៅក្នុងនោះលំនៅដ្ឋានខ្លះកំពុងសាងសង់ដោយគ្មានលិខិតអនុញ្ញាតពីអាជ្ញាធរត្រឹមត្រូវតាមច្បាប់ និងលំនៅដ្ឋានខ្លះទៀតសាងសង់ដោយមានការរំលោភបំពានទៅលើដីសាធារណៈរបស់រដ្ឋផងដែរ។

- **ការងារសំណង់ និងដីធ្លី**

ការងាររដ្ឋបាលដីធ្លីក្នុងឆ្នាំ២០២១អនុវត្តបាន៖

- ការចុះបញ្ជីបំពេញបន្ថែម៖ សរុប៤៨ក្បាលដី
- ការងារចុះបន្តទិញលក់អំណោយផ្ដាច់៖ មានចំនួន៣៤៦៦ ក្បាលដី
- បំបែកក្បាលដី៖ មានចំនួន៣០៦ក្បាលដី
- ទុតិយតា៖ ចំនួន១២ក្បាលដី
- ការផ្ទេរសិទ្ធដីមិនទាន់ចុះបញ្ជី៖ ចំនួន២០ក្បាលដី

[42] គេហទំព័រ https://www.rasmeinews.com/archives/405553 ដកស្រង់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២

- ចុះបញ្ជីគោលៈ នៅសង្កាត់ទួលតាឯកចំនួន៦៨៧ក្បាលដី និង៤៨៦ក្បាលដី និងសង្កាត់ស្វាយប៉ោ ចំនួន៨៧៧ក្បាលដី

ការងារអភិវឌ្ឍដីៈ

- បង្រួមក្បាលដីៈ មានចំនួន២៩ ក្បាលដី
- ប្តូរប្រភេទដីៈ មានចំនួន ៥១ ក្បាលដី
- ឡូត៍រៀបរយៈ មានចំនួន ៤៥ ក្បាលដី

ការងារដោះស្រាយវិវាទដីធ្លី (គណៈកម្មការសុរិយោដី)ៈ

- ទទួលបណ្តឹងសរុប២៥បណ្តឹងៈ ការសម្រុះសម្រួលដោះស្រាយ
- បញ្ចប់ទំនាស់សះជាបានចំនួន១៥បណ្តឹង
- បញ្ជូនទៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីខេត្ត០១បណ្តឹង
- សហការជាមួយមន្ត្រីរដ្ឋបាលក្រុងសង្កាត់ពាក់ព័ន្ធ ចំនួន៤៥លើកគឺៈ ចុះអនុវត្តទៅលើករណីដូចជា (សុំគ្រប់គ្រងដី, អនុវត្តសាលក្រម, ចុះសិក្សាផ្លូវ, រថភ្លើង, បើកផ្លូវសាធារណៈ, ពិនិត្យអ័ក្សផ្លូវ, ប្រឡាយ, ការសាងសង់សំណង់ផ្សេងៗ, រំព្រំដីទំនាស់ និងពិនិត្យទីតាំងស្ថានភាពជាក់ស្តែងនៅសហគមន៍បណ្តោះអាសន្ន)
- សហការជាមួយមន្ត្រីជំនាញចុះពិនិត្យទីតាំងដែលបានស្នើសុំអនុញ្ញាតជួសជុលផ្ទះល្វែងស្ថិតនៅក្នុងភូមិ២០ឧសភា សង្កាត់ស្វាយប៉ោ
- ចុះពិនិត្យទីតាំងស្នើសុំអនុញ្ញាតបើកការដ្ឋាននៅភូមិប្រាបក្រសាំង សង្កាត់វត្តគរ
- សហការជាមួយមន្ត្រីមន្ទីរទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច អាជ្ញាធរមូលដ្ឋានទាក់ទង និងផ្លូវទំហំ៤ម៉ែត្រ និង៨ម៉ែត្រក្បាលដីជាកម្មសិទ្ធរបស់ប្រជាពលរដ្ឋនៅភូមិអញ្ចាញ សង្កាត់អូរចារ
- ចុះត្រួតពិនិត្យទីតាំងសំណង់កំពុងសាងសង់អគារផ្ទះល្វែងរបស់ប្រជាពលរដ្ឋ ស្ថិតនៅភូមិកំពង់ក្របី សង្កាត់ស្វាយប៉ោ
- ដោះស្រាយវិវាទព្រំដីការធ្វើរបងឈ្មោះសាន វណ្ណារី និងព្រំដីឡូ អៀកគីម នៅភូមិសាលាបាឡាត់ សង្កាត់អូរម៉ាល់។[43]

[43] សៀវភៅរបាយការណ៍ប្រចាំឆ្នាំ២០២១របស់រដ្ឋបាលក្រុងបាត់ដំបង ទំព័រទី៣៩

➢ **ការអភិវឌ្ឍបុរីក្នុងក្រុងបាត់ដំបង**

ជាការពិតណាស់ការបង្កើតបុរីពិតជាបង្កនូវលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង ព្រោះបុរីត្រូវបានសាងសង់ដោយមានលក្ខណៈស្តង់ដានៃការសាងសង់ត្រឹមត្រូវ។ មិនតែប៉ុណ្ណោះ ការអភិវឌ្ឍបុរីអាចជួយសម្រួលដល់ការតាំងទីលំនៅផងដែរ កាលណាបុរីអភិវឌ្ឍរួចម្ចាស់បុរីអាចផ្តល់លិទ្ធភាពដល់ប្រជាពលរដ្ឋតាមរយៈបង់រំលោះបន្តិចម្តងៗក្នុងការទទួលបានសំណង់គេហដ្ឋានតាមលក្ខណៈស្តង់ដា និងសមរម្យ។ ម្យ៉ាងវិញទៀតការអភិវឌ្ឍបុរីអាចកាត់បន្ថយបញ្ហាសំណង់អនាធិបតេយ្យ និងការកាន់កាប់ដីរដ្ឋខុសច្បាប់។ ការអភិវឌ្ឍបុរីនៅក្រុងបាត់ដំបងមានដូចជា៖

- បុរីរំចេក ស្ថិតនៅភូមិរំចេក សង្កាត់រតនៈ ក្រុងបាត់ដំបង
- បុរីភូពុយ ស្ថិតនៅភូមិអង់ សង្កាត់អូរចារ ក្រុងបាត់ដំបង
- បុរីរតនៈ ស្ថិតនៅភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង
- បុរីរស្មីបាត់ដំបង ស្ថិតនៅផ្លូវអាស៊ាន៦០ម៉ែត្រ សង្កាត់អូរម៉ាល់ ក្រុងបាត់ដំបង
- បុរីរោងចក្រ ស្ថិតនៅភូមិអូរតាគាំង១ សង្កាត់ទួលតាឯក ក្រុងបាត់ដំបង។[44]

### ១.២.១.៣. ការរៀបចំរបៀបរៀបរយ

ការរៀបចំរបៀបរៀបរយ គឺធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការរក្សាការពារ សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈដល់ប្រជាពលរដ្ឋ។ ការរៀបចំរបៀបរៀបរយ គឺជាការរៀបចំទៅលើបញ្ហាដែលអាជីវករ ឬប្រជាពលរដ្ឋណាមួយ បានធ្វើអាជីវកម្ម ឬសាងសង់សំណង់ ដោយមានការរំលោភយកផ្លូវសាធារណៈ និងការរៀបចំផ្សាររដ្ឋ និងផ្សារឯកជនឱ្យមានភាពត្រឹមត្រូវប្រកបទៅដោយសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។ ដោយកន្លងមករដ្ឋបាលសាលាក្រុងបាត់ដំបង បានរៀបចំការងារ ដោះស្រាយបញ្ហាជាច្រើន។ មួយវិញទៀតដោយសារមានការឆ្លងរីករាលដាលជំងឺកូវីដ១៩ នាពេលបច្ចុប្បន្ននេះផងដែររដ្ឋបាលក្រុងត្រូវមានការរៀបចំគោលដៅបន្ថែមទៀតទៅតាមសេចក្តីណែនាំរបស់រដ្ឋបាលខេត្ត នៅតាមសង្កាត់នីមួយៗនៅក្នុងក្រុង ដើម្បីជាភាពងាយស្រួល និងឱ្យមានភាពសមស្របទៅតាមស្ថានភាពនាពេលបច្ចុប្បន្ននេះផងដែរ។ ដើម្បីពង្រឹងទៅលើការគោរព និងអនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាពក៏ដូចជាការលើកកម្ពស់សោភ័ណភាពក្រុងបាត់ដំបងឱ្យសមជាទីក្រុងស្អាត រដ្ឋបាលក្រុងបាត់ដំបងបានធ្វើការចាត់វិធានការដូចខាងក្រោម៖

➢ ការចតយានយន្តគ្រប់ប្រភេទ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមគំនូសសញ្ញាចរាចរណ៍លើផ្លូវរួមទាំងស្លាកសញ្ញាចរាចរណ៍ និងការចង្អុលបង្ហាញរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធបានកំណត់។

[44] គេហទំព័រ https://vymaps.com/KH/-170207/ ដកស្រង់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២

- ម្ចាស់អាជីវកម្ម និងបុគ្គលិកត្រូវដាក់តាំងរបស់របរលក់ និងចតយានយន្តផ្ទាល់ខ្លួនក្នុងទីតាំងកម្មសិទ្ធិរបស់ខ្លួន មិនត្រូវចតរំលោភ ឬ ប្រើប្រាស់ដីចំណីផ្លូវសាធារណៈជាដាច់ខាត។
- កម្លាំងសមត្ថកិច្ចសណ្តាប់ធ្នាប់ និងចរាចរណ៍ក្រុងសមត្ថកិច្ចពាក់ព័ន្ធត្រូវឈរជើងប្រចាំការ និងសម្របសម្រួលចរាចរណ៍ រៀបចំផ្លូវថ្មើរជើង សន្តិសុខ របៀបរៀបរយការដាក់តាំងលក់ និងអ្នកលក់ដូរចល័ត។
- អង្គភាពអគ្គីសនីក្រុងចាត់មន្ត្រីបច្ចេកទេសចុះត្រួតពិនិត្យ និងរៀបចំប្រព័ន្ធបណ្តាញខ្សែភ្លើងឡើងវិញ។
- ចុះពិនិត្យរៀបចំកន្លែងស្តង់លក់ដូរ គឺដើម្បីឱ្យបងប្អូនជាអាជីវករត្រូវមានគម្លាតសុវត្ថិភាព សោភ័ណភាព និងអនាម័យនៅសួនសម្តេចក្រឡាហោមសខេង។[45]
- មានការរៀបចំសណ្តាប់ធ្នាប់ជុំវិញផ្សារក្នុងក្រុងបាត់ដំបងទៅលើបញ្ហាការយកចំណីផ្លូវធ្វើអាជីវកម្មជុំវិញផ្សារមានភាពរញ៉េរញ៉ៃយានយន្តដែលចតគ្មានសណ្តាប់ធ្នាប់។[46]
- មានការរៀបចំទីតាំងលក់ដូរថ្មីដែលមានទីតាំងនៅមុខផ្សារភូពុយ ស្ថិតក្នុងភូមិអញ្ចាញ សង្កាត់អូរចារ ដោយការរៀបចំមានរបៀបរៀបរយបានយ៉ាងល្អក្នុងការរក្សាគម្លាតសុវត្ថិភាព សណ្តាប់ធ្នាប់ អនាម័យ អនុវត្តវិធានការរបស់ក្រសួងសុខាភិបាលមានអាជ្ញាធរសម្រួលចរាចរណ៍ និងកំណត់ចំនួនចេញ-ចូលផងដែរ។[47]
- រដ្ឋបាលខេត្តបាត់ដំបងបានធ្វើការផ្សព្វផ្សាយជូនប្រជាពលរដ្ឋឱ្យមានការយល់ដឹងជាមុនសិន អំពីការរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់ ការរៀបចំសំយ៉ាបផ្ទះ ចំណតរថយន្តក្រុងបាត់ដំបង និងដោះស្រាយសំណង់អនាធិបតេយ្យដែលមាននៅក្នុងក្រុងបាត់ដំបងទាំងអស់ ដើម្បីធ្វើការរៀបចំប្រជាពលរដ្ឋដែលរស់នៅសំណង់អនាធិបតេយ្យទៅកន្លែងផ្សេងដែលមានការរៀបចំឱ្យមានរបៀបរៀបរយ ដើម្បីកុំឱ្យទីក្រុងសម្បូរទៅដោយសំណង់អនាធិបតេយ្យ និងបង្កភាពរញ៉េរញ៉ៃគ្មានសណ្តាប់ធ្នាប់ពេញទីក្រុង។[48]

### ១.២.២. ទិសដៅអនាគតនៃការរៀបចំសណ្តាប់ធ្នាប់

ជាទូទៅរាល់ការអភិវឌ្ឍតែងតែមានគោលដៅទុកជាមុន ដើម្បីត្រៀមនឹងក្នុងការអភិវឌ្ឍការរៀបចំផែនការ ឬគម្រោងទុកជាមុន ដើម្បីជាភាពងាយស្រួលឱ្យមានដំណើរការល្អ ហើយគម្រោងនេះត្រូវបានគេសរសេរទុកនៅក្នុងសៀវភៅផែនការអភិវឌ្ឍ៥ឆ្នាំនៃក្រុងបាត់ដំបង។ ដោយឡែកទិសដៅនាពេលអនាគត គឺមានគោលបំណងអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ដើម្បីជាគោលដៅអភិវឌ្ឍនៅក្នុងក្រុង។

[45] គេហទំព័រ https://www.battambang.gov.kh/detail/11246 ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២
[46] គេហទំព័រ https://www.pdibattambang.info/mall-in-city/ ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២
[47] គេហទំព័រ https://www.popular.com.kh/social/356941.html/ ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២
[48] គេហទំព័រ https://www.khmertimeskh.com//501113540/ឧតតបតដបងនងរបចស/ ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២

- **ចក្ខុវិស័យ**

ក្រុងបាត់ដំបងមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព សមភាព សមធម៌លើគ្រប់វិស័យ និងមានសន្តិសុខ សុវត្ថិភាពសណ្តាប់ធ្នាប់ល្អ ធានាបាននូវការទាក់ទាញពីវិនិយោគគិន និងអ្នកទេសចរជាច្រើនមកកាន់ក្រុងបាត់ដំបង។ រដ្ឋបាលក្រុងបាត់ដំបងយកចិត្តទុកដាក់អភិវឌ្ឍតាមរយៈការលើកស្ទួយវិស័យកសិកម្មបង្កើនទិន្នផលនិងគុណភាព បង្កើតប្លង់គោលសម្រាប់ប្រើប្រាស់ដីធ្លីបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្ម និងឧស្សាហកម្មកែច្នៃផលិតផល ជំរុញ និងលើកស្ទួយវិស័យទេសចរណ៍ ជំរុញឱ្យមានការគោរពច្បាប់ គោរពសិទ្ធិមនុស្ស បំបាត់អំពើហិង្សា អភិបាលកិច្ចល្អ និងអភិវឌ្ឍធនធានមនុស្ស ការពារវប្បធម៌ និងធនធានធម្មជាតិ។

- **គោលបំណងនៃការអភិវឌ្ឍ**

- សេដ្ឋកិច្ចខេត្តបាត់ដំបងមានកម្រិតរីកចំរើន និងកាត់បន្ថយអត្រាភាពក្រីក្រ
- លើកកម្ពស់ផលិតភាពពិតភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម
- សេវាកម្មទេសចរណ៍ក្រុងបាត់ដំបងមានការកែលម្អ និងអភិវឌ្ឍសំដៅជំរុញកំណើនភ្ញៀវទេសចរ
- អង្គភាពវិនិយោគលើវិស័យឧស្សាហកម្ម សហគ្រាសខ្នាតតូច មធ្យម សិប្បកម្ម និងទឹកស្អាតមានការកើនឡើង
- ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ មានការជួសជុល កែលម្អ និងកសាងថ្មីប្រកបដោយគុណភាពធានាសម្រួលការធ្វើដំណើរ និងការដឹកជញ្ជូនទាន់ពេលវេលា
- អង្គភាពអាជីវកម្មនៅក្នុងក្រុងមានការគ្រប់គ្រងបានម៉ង់ចត់ និងបង្កើនសកម្មភាពអាជីវកម្មកាន់តែប្រសើរឡើង
- ចំណូលចំណាយថវិកា និងទ្រព្យសម្បត្តិរដ្ឋមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព
- ក្រុងមានផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រកបទៅដោយសុក្រឹត្យដែលជាវិស័យក្នុងការអភិវឌ្ឍក្រុង
- ប្រជាជនក្រុងបាត់ដំបងរស់នៅប្រកបដោយសុខុមាលភាព មានចំណេះដឹងជ្រៅជ្រះ ព្រមទាំងរក្សាបាននូវអត្តសញ្ញាណជាតិ និងមានសាមគ្គីភាពរឹងមាំ
- សុខុមាលភាពរបស់ប្រជាជននៅទូទាំងក្រុងមានការយកចិត្តទុកដាក់ខ្ពស់
- ការអប់រំចំណេះដឹងទូទៅ ព្រមទាំងការអប់រំកាយ និងកីឡាមានការលើកកម្ពស់
- ប្រជាជនមានចំណេះដឹង វិជ្ជាជីវៈរបស់ប្រជាជននៅទូទាំងក្រុង មានការកើនឡើង ជនងាយរងគ្រោះទទួលបានអន្តរាគមន៍ទាន់ពេលវេលា

- សិល្បៈ វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីជាតិបានទទួលបានការអភិរក្ស និងអភិវឌ្ឍឱ្យមានភាពប្រសើរឡើង និងគង់វង្សជានិរន្តរ៍
- ក្រុងបាត់ដំបងមានការគ្រប់គ្រងដីធ្លី និងសំណង់នានាបានត្រឹមត្រូវ រក្សាបាននូវបរិស្ថានល្អប្រសើរ និងកាត់បន្ថយបាននូវជម្លោះដីធ្លី និងគ្រោះមហន្តរាយផ្សេងៗ
- ដីធ្លី ការប្រើប្រាស់ដីធ្លី និងការសាងសង់សំណង់នានានៅទូទាំងក្រុងមានការគ្រប់គ្រងដោយម៉ត់ចត់
- ធនធានធម្មជាតិ បរិស្ថាន មានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ហើយសកម្មភាពធ្វើឱ្យមានភាពស៊ាំនឹងការប្រែប្រួលត្រូវបានលើកកម្ពស់
- ប្រជាជននៅទូទាំងក្រុងបាត់ដំបងទទួលបាននូវសេវាសាធារណៈកាន់តែប្រសើរឡើង និងការរស់នៅប្រកបដោយសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អប្រសើរ
- រដ្ឋបាលសាធារណៈទូទាំងក្រុងបម្រើប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងទាន់ពេលវេលា
- សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈកាន់តែមានភាពប្រសើរឡើង។

**១.២.២.១. ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន**

គម្រោងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធឆ្នាំ២០២៣ខាងមុខ មានគោលដៅគម្រោងស្ថាបនាដូចជា៖

- ការកែលម្អផ្លូវក្នុងតំបន់ផ្សារណាត់
- ការអភិវឌ្ឍសួននៅតាមបណ្តោយដងស្ទឹងសង្កែ
- ការគ្រប់គ្រងចរាចរណ៍រួម (ចំណតសាធារណៈ តំបន់សម្រាប់តែដើរ និងការត្រួតពិនិត្យផ្លូវឯកទិស)
- ការអភិវឌ្ឍបេតិកភណ្ឌក្រុង និងដើមឈើចាស់ៗនៅតាមផ្លូវ
- ការកែលម្អផ្ទាំងព័ត៌មានបេតិកភណ្ឌក្រុង
- ពង្រឹងយន្តការសម្របសម្រួល និងសហប្រតិបត្តិការក្នុងចំណោមអាជ្ញាធរអភិវឌ្ឍក្រុង
- ពង្រីកផ្លូវដែលតូចចង្អៀត
- ស្ថាបនាផ្លូវជាតិលេខ១០ តភ្ជាប់ពីខេត្តបាត់ដំបងដល់ខេត្តកោះកុង
- ស្ថាបនាផ្លូវក្រុងសៀមរាប-ក្រុងបាត់ដំបង ដែលចំណេញការធ្វើដំណើរបានដល់ទៅ៦៩គីឡូម៉ែត្រ
- គម្រោងស្តារឡើងវិញ នៃព្រលានយន្តហោះបាត់ដំបង ទៅជាអាកាសយានដ្ឋានកម្រិត4Cផងដែរ
- លើកកំពស់ផ្លូវជាតិលេខ៥ ជាផ្លូវអាស៊ានហាយវ៉េលេខ១។[49]

[49] គេហទំព័រ http://www.cambodiapropertyreport.com/article/6504 ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២

**១.២.២.២. ការអភិវឌ្ឍលើវិស័យទឹកស្អាត និងអនាម័យ**

ក្រោមជំនួយឥតសំណងរបស់ប្រទេសជប៉ុន (JICA) ក្រុងបាត់ដំបងទទួលបាននូវរោងចក្រផលិតទឹកស្អាតថ្មីមួយកន្លែងទីតាំងស្ថិតក្នុងភូមិវត្តលៀប សង្កាត់ចំការសំរោងមានសមត្ថភាពផលិតទឹកបាន ២២.០០០ ម៉ែត្រគីបក្នុងមួយថ្ងៃអាចផ្គត់ផ្គង់បាន១.៤៨៨.៣៥៩នាក់។

ចំពោះការរំពឹងទុកនាឆ្នាំ២០២៣ខាងមុខនេះ ប្រជាពលរដ្ឋប្រមាណ៧០ភាគរយមានទឹកស្អាតប្រើប្រាស់ដោយរដ្ឋបាលក្រុងបានរៀបចំប្រព័ន្ធបណ្តាញទឹកស្អាតសម្រាប់ប្រជាពលរដ្ឋ។ ការអភិវឌ្ឍសំដៅទៅលើទឹកស្អាត និងអនាម័យនេះក្នុងគោលបំណងជំរុញឱ្យមានការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋឱ្យបានគ្រប់គ្រាន់ និងមានអនាម័យដល់ប្រជាពលរដ្ឋ។ មួយវិញទៀតដើម្បីសម្រេចនូវគោលបំណងនេះក៏ត្រូវមានយុទ្ធសាស្ត្រសម្រេចលើការអភិវឌ្ឍវិស័យនេះដោយជំរុញឱ្យមានការតបណ្តាញទឹកស្អាត ការសង់ ជួសជុល និងការស្តារស្រះ ដើម្បីឱ្យប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់នៅគ្រប់មូលដ្ឋានទាំងអស់។

**១.២.២.៣. ការអភិវឌ្ឍលើវិស័យដីធ្លី**

ចំពោះគោលដៅអភិវឌ្ឍនៃវិស័យដីធ្លីក្នុងក្រុងបាត់ដំបងនាឆ្នាំ២០២៣ ប្រជាពលរដ្ឋ៦០ភាគរយទៅបានប័ណ្ណកម្មសិទ្ធិស្របច្បាប់ដោយមានការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ និងការផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងផ្សព្វផ្សាយពីច្បាប់ភូមិបាល។ ការអភិវឌ្ឍវិស័យដីធ្លី គឺមានយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍដោយធ្វើការផ្សព្វផ្សាយច្បាប់ភូមិបាលឱ្យទូលំទូលាយ និងមានសារៈសំខាន់នៃការប្រើប្រាសប័ណ្ណកម្មសិទ្ធិដោះស្រាយវិវាទ និងសម្របសម្រួលទំនាស់ដីធ្លី។

**១.២.២.៤. ការអភិវឌ្ឍលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

ចំពោះគោលដៅអភិវឌ្ឍក្នុងវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្រុងបាត់ដំបងទៅថ្ងៃអនាគតដោយរំពឹងថានឹងសម្រេចឱ្យបានក្នុងឆ្នាំ២០២៣ខាងមុខ ប្រជាពលរដ្ឋដែលរស់នៅប្រកបដោយសុខសុវត្ថិភាព ក្រុងមានការអភិវឌ្ឍទៅលើ៖

- ពង្រឹងសកម្មភាពរក្សាសន្តិសុខសណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន
- ទប់ស្កាត់ការចែកចាយ និងប្រើប្រាស់គ្រឿងញៀន
- បង្ក្រាបអំពើចោរកម្ម និងល្បែងស៊ីសងគ្រប់ប្រភេទ
- ពង្រឹងការប្រើប្រាស់នូវអាវុធ
- ប្រមូលក្រុមជនពាលដើម្បីអប់រំ
- សង់និងជួសជុលប៉ុស្តិ៍ប្រជាការពារ
- ពង្រឹងវិធានការការពារគ្រោះថ្នាក់ចរាចរណ៍

- ពង្រឹងសមត្ថភាព ការពារ ទប់ទល់គ្រោះអគ្គិភ័យ និងគ្រោះធម្មជាតិ
- ពង្រឹងការពារ និងទប់ស្កាត់ពីជំងឺវីរុសកូវីដ១៩។

ការអភិវឌ្ឍវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈមានគោលបំណងបង្កើនការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីឱ្យប្រជាពលរដ្ឋក្នុងក្រុងរស់នៅដោយសុខសុវត្ថិភាពបុគ្គល និងសុវត្ថិភាពសាធារណៈ គ្មានភ័យខ្លាច ស្មៀមស្ងាត់ ជាពិសេសនោះគឺ ការរស់ដោយសុវត្ថិភាពផ្លូវចិត្ត ផ្លូវកាយ បន្ថែមពីនេះ ដើម្បីការពារនូវអាយុជីវិតប្រជាជនផុតពីកូវីដ។ ដូច្នេះដើម្បីសម្រេចបាននូវគោលបំណងខាងលើ រដ្ឋបាលក្រុងបានដាក់ចេញយុទ្ធសាស្ត្រអភិវឌ្ឍវិស័យសន្តិសុខសណ្តាប់ធ្នាប់សាធារណៈមានដូចខាងក្រោម៖

- តាមដាន និងត្រួតពិនិត្យពួកក្មេងទំនើង និងអ្នកប្រើប្រាស់ថ្នាំញៀន
- ត្រួតពិនិត្យអាវុធជាតិផ្ទុះនៅពេលយប់
- ត្រួតពិនិត្យអ្នកចំណាកស្រុក អ្នកទៅធ្វើពលករ និងអ្នកចំណូលស្រុក
- សហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗដើម្បីរៀបចំកែលម្អសោភ័ណភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងក្រុងឱ្យបានល្អប្រសើរជាងមុន
- ពង្រឹងកម្លាំងសមត្ថកិច្ច និងប៉ុស្តិ៍ប្រជាការពារតាមគោលដៅ
- ចែកខ្លឹមសារលក្ខណៈសម្បត្តិ៩យ៉ាងអំពី ភូមិ ឃុំ មានសុវត្ថិភាពជាប្រចាំ
- បង្កើនការគ្រប់គ្រងរដ្ឋបាលចំហ និងបន្តផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ
- សហការជាមួយអាជ្ញាធរសង្កាត់ទាំង១០ចុះបង្ក្រាបការលេងល្បែងស៊ីសង
- សហការជាមួយមន្ទីរសង្គមកិច្ចធ្វើការប្រមូលជនអនាថាទៅដាក់មណ្ឌល
- ដោះស្រាយទំនាស់ជូនប្រជាពលរដ្ឋ និងជំរុញការចុះធ្វើរដ្ឋបាល
- តាមដាន និងទប់ស្កាត់ការសាងសង់សំណង់ខុសច្បាប់ និងរៀបចំសណ្តាប់ធ្នាប់សាធារណៈ
- រៀបចំស្ថិតិអំពីការតាំងទីលំនៅបណ្តោះអាសន្នក្នុងក្រុង
- ផ្សព្វផ្សាយច្បាប់ស្តីពីការជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន
- ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន
- អនុវត្តគោលនយោបាយឃុំ-សង្កាត់មានសុវត្ថិភាព
- ផ្សព្វផ្សាយច្បាប់អនុវត្តវិធានការការពារតាមការណែនាំរបស់ក្រសួងសុខាភិបាល ទប់ស្កាត់ការឆ្លងវីរុសកូវីដ១៩ ដល់គ្រប់ភូមិ និងសង្កាត់ទាំងអស់នៅក្រុងបាត់ដំបង។

# ជំពូកទី២

# ការរៀបចំសោភ័ណភាព

# ក្រុងបាត់ដំបង

# ជំពូកទី២

# ការរៀបចំសោភ័ណភាពក្រុងបាត់ដំបង

កាលណាតំបន់មួយ ឬទីកន្លែងមួយមានភាពស្រស់ស្អាតវានឹងក្លាយទៅជាតំបន់មួយដែលពោរពេញទៅដោយភាពទាក់ទាញ ភាពល្អប្រសើរ និងភាពស្រស់បំព្រងដោយសារតែបរិស្ថាន និងអនាម័យនៅក្នុងតំបន់នោះ។ សោភ័ណភាព គឺជាអ្វីៗដែលធ្វើឱ្យកាន់តែប្រសើរឡើងជាងមុន ធ្វើឱ្យល្អហូត់ហ្មង និងជាអ្វីៗទាំងអស់ដែលអាចមើលឃើញនឹងភ្នែកបាន ហើយធ្វើឱ្យមានការចាប់អារម្មណ៍។

សព្វថ្ងៃនេះបើយើងធ្វើការមើល និងប្រៀបធៀបក្រុងបាត់ដំបងក្នុងរយៈពេល១០ឆ្នាំមុន និងពេលបច្ចុប្បន្ន យើងនឹងឃើញថាសន្ទុះនៃការអភិវឌ្ឍនៅក្នុងក្រុងមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ជាពិសេសទៅទៀតនោះគឺទៅលើបញ្ហាសោភ័ណភាពនេះឯង។ ក្នុងការរៀបចំនូវសោភ័ណភាពក្រុង គឺអាស្រ័យទៅលើហេតុផលជាច្រើនដែលតម្រូវឱ្យអាជ្ញាធរត្រូវយកចិត្តទុកដាក់ជាទីបំផុត ចំណែកឯផលដែលទទួលបានពីការរៀបចំនោះមានដូចជាធ្វើឱ្យក្រុងមានភាពស្រស់ស្អាត មានជាសុខភាព ជាពិសេសមានការកែលម្អពីភាពអនាធិបតេយ្យប្រែក្លាយមកជាភាពស្រស់ស្អាត មានសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយត្រឹមត្រូវតាមស្តង់ដា ដែលធ្វើឱ្យប្រជាជននៅក្នុងក្រុងផ្ទាល់ មានការរស់នៅប្រកបដោយសុខដុមរមនា សុខសុវត្ថិភាពទាំងផ្លូវកាយ ផ្លូវចិត្ត សន្តិសុខ សណ្តាប់ធ្នាប់ មានជាសុខភាព អនាម័យល្អ និងមានអារម្មណ៍ស្រស់ស្រាយជាមួយនឹងសោភ័ណភាព ល្អប្រសើររបស់ក្រុង។ ហេតុដូចនេះហើយទើបរដ្ឋបាលក្រុងបានខិតខំ ស្វះស្វែង រិះរក គ្រប់មធ្យោបាយ កែកុន និងស្ថាបនា ដើម្បីឱ្យក្រុងបាត់ដំបងមានភាពរីកចម្រើនសុះសាយ និងមានភាពលេចធ្លោ ជាពិសេសដើម្បីប្រកួតប្រជែងខាងផ្នែកសោភ័ណភាពស្អាត ទីក្រុងស្អាតជាមួយក្រុងដទៃៗទៀតនៅប្រទេសកម្ពុជា។

## ២.១. ការរៀបចំសោភ័ណភាពពេលថ្ងៃ និងពេលយប់

ជាទូទៅ រាល់ក្រុងនីមួយៗនៅក្នុងប្រទេសកម្ពុជាតែងតែមានភាពអភិវឌ្ឍរបស់ខ្លួន និងចង់ឱ្យក្រុងរបស់ខ្លួនក្លាយជាទីចាប់អារម្មណ៍ពីសំណាក់មហាជន និងមជ្ឈដ្ឋាននានា។ ការរៀបចំសោភ័ណភាពនៅក្នុងភាគច្រើនគឺផ្តោតសំខាន់ទៅលើសោភ័ណភាពទាំងពេលថ្ងៃ និងទាំងសោភ័ណភាពពេលយប់។

### ២.១.១. ការរៀបចំសោភ័ណភាពពេលថ្ងៃ

ការរៀបចំសោភ័ណភាពពេលថ្ងៃ គឺសំដៅទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធរួមមាន ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធលូ ចិញ្ចើមផ្លូវ សំណង់អគារតូចធំទាំងអស់របស់រដ្ឋ និងឯកជន សួនច្បារសាធារណៈ និងប្រព័ន្ធសុវត្ថិភាពចរាចរណ៍រួមមាន ភ្លើងសញ្ញា ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍ រួមទាំងការធ្វើដំណើរតាមដងផ្លូវនៃយានយន្តគ្រប់ប្រភេទ និងទាំងថ្មើរជើងផង ប្រកបដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយថែមទៀត។ ក្នុងនោះដែរយើងសង្កេតឃើញថា នៅក្នុងក្រុងបាត់ដំបងមានភាពអភិវឌ្ឍខ្លាំង និងមានភាពលេចធ្លោទៅលើការដាំដើមឈើ

តាមដងផ្លូវ ដាំស្មៅលម្អតាមសួនច្បារ ចិញ្ចើមផ្លូវ ការបំពាក់ភ្លើងសញ្ញា ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍តាមដងផ្លូវ ព្រមទាំងបានរៀបចំសំណង់អគារតូចធំតាមដងផ្លូវឱ្យមានសណ្តាប់ធ្នាប់ប្រកបទៅតាមស្តង់ដាដែលបានកំណត់។

### ២.១.១.១. ការដាំដើមឈើតាមដងផ្លូវ

ជាក់ស្តែងនាពេលថ្មីៗនេះ អាជ្ញាធរក្រុងបានដាំស្មៅ និងដើមឈើតូច ធំជាច្រើន ជាពិសេសដាំដើមប្រភេទឈើផ្កាសម្រាប់លម្អ ដូចជាដើមក្រោក និងដើមលឿងរាជ ដែលត្រូវបានយកមកដាំនៅតាមដងផ្លូវ គឺដើម្បីធ្វើការកែលម្អសោភ័ណភាពដងផ្លូវ ដែលជាផ្លូវទេសចរណ៍មួយយ៉ាងសំខាន់សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិដែលកំពុងតែមានការចាប់អារម្មណ៍ទៅលេងតំបន់រមណីយដ្ឋាននានា។[50]

➢ **ចំពោះបញ្ហាចិញ្ចើមផ្លូវ**

ការរំលោភចំណីផ្លូវនៅតែជាបញ្ហាក្នុងក្រុងបាត់ដំបង បើទោះបីជាអាជ្ញាធរក្រុង និងអ្នកជំនាញពាក់ព័ន្ធចុះទៅដោះស្រាយយ៉ាងណាក៏ដោយ ព្រោះពលរដ្ឋ ឬអាជីវករដែលនោះទីនោះមានការខ្លាចរអែងបានតែមួយភ្លែតប៉ុណ្ណោះ ទើបនេះជាកត្តាដែលញុំាងឱ្យរដ្ឋបាលខេត្តធ្វើការដោះស្រាយ និងរៀបចំចំពោះបញ្ហានេះឱ្យបានលឿនបំផុត។ ដើម្បីពង្រីកវិសាលភាពនៃការអនុវត្ត ស្របតាមមាត្រា ៥ និងមាត្រា២៩ នៃច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តជាធរមានឈានទៅរក្សាបានសណ្តាប់ធ្នាប់មានរបៀបរៀបរយតាមដងផ្លូវ សម្រួលលំហូរចរាចរណ៍ លើកកម្ពស់សោភ័ណភាពទីក្រុង និងដើម្បីតម្រង់ទិសក្នុងការប្រើប្រាស់ចិញ្ចើមផ្លូវឱ្យចំទិសដៅប្រយោជន៍សាធារណៈជារួម រដ្ឋបាលខេត្តសម្រេចដាក់ចេញនូវសេចក្តីជូនដំណឹងការកែលម្អ និងរៀបចំសណ្តាប់ធ្នាប់ សោភ័ណភាពនៅក្នុងតំបន់អគារអភិរក្ស ក្រុងបាត់ដំបង រដ្ឋបាលខេត្តបាត់ដំបងបានជម្រាបជូនជាដំណឹងទៅដល់ម្ចាស់លំនៅឋាន និងអាជីវកម្មទាំងអស់ថា ដើម្បីលើកកម្ពស់ សោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយ និងគុណតម្លៃនៃសំណង់អគារអភិរក្សក្នុងទីប្រជុំជនក្រុងបាត់ដំបង រដ្ឋបាលខេត្តនឹងត្រូវរៀបចំសណ្តាប់ធ្នាប់ក្នុងតំបន់អគារអភិរក្ស ចាប់ពីផ្លូវលេខ១ ដល់ផ្លូវលេខ៣ (ពីចំណុចវត្តដំរីស ដល់ វត្តពិភិទ្យារាម) និងលំនៅដ្ឋានជុំវិញផ្សារធំបាត់ដំបង (ផ្សារណាត់) ដោយតម្រូវឱ្យម្ចាស់លំនៅឋាន និងអាជីវកម្មទាំងអស់នៅក្នុងទីតាំងខាងលើនេះ ចូលរួមអនុវត្តតាមការកំណត់របស់រដ្ឋបាលខេត្ត ដូចខាងក្រោមៈ

- ត្រូវដកបង្គោលផ្សព្វផ្សាយពាណិជ្ជកម្មទាំងអស់ចេញពីលើចិញ្ចើមផ្លូវ
- កាត់តម្រឹមសំយ៉ាបផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្ម និងស្លាកយីហោគ្រប់ប្រភេទឱ្យសមស្របតាមបទប្បញ្ញត្តិស្តីពីការដាក់តាំងស្លាកផ្សព្វផ្សាយពាណិជ្ជកម្ម និងស្លាកយីហោតាមមុខផ្ទះក្នុងតំបន់អភិរក្ស

[50] គេហទំព័រ https://www.pdibattambang.info/plant-flowers/ ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២

- មិនអនុញ្ញាតឱ្យអាជីវករយកទំនិញគ្រប់ប្រភេទដាក់តាំងលក់លើចិញ្ចើមផ្លូវមុខផ្ទះ។[51]

➢ **ការបំពាក់ភ្លើងសញ្ញាចរាចរណ៍**

ចំពោះការបំពាក់ភ្លើងសញ្ញា គំនូសសញ្ញា និងផ្លាកសញ្ញាចរាចរណ៍តាមដងផ្លូវបានចែងក្នុងជំពូកទី២ មាត្រា៥ នៃច្បាប់ចរាចរណ៍ផ្លូវគោកដែលចែងថា៖ សញ្ញាចរាចរណ៍ផ្លូវគោករួមមាន ផ្លាកសញ្ញាចរាចរណ៍តាមផ្លូវ ភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍លើផ្លូវ សញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ និងសញ្ញាផ្សេងៗទៀត។ ផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍នៅលើផ្លូវត្រូវរៀបចំជាប្រព័ន្ធទាក់ទងស៊ីចង្វាក់គ្នាជាហូរហែនៅតាមកន្លែងមានសារៈប្រយោជន៍ ដែលធ្វើឱ្យអ្នកប្រើប្រាស់ផ្លូវងាយស្រួលមើលឃើញ។ សញ្ញាគ្រោះថ្នាក់នៅតាមដងផ្លូវដែលមានលក្ខណៈមិនអចិន្ត្រៃយ៍ ត្រូវដាក់ក្នុងចម្ងាយឱ្យសមស្របល្មមគ្រប់គ្រាន់តាមប្រភេទផ្លូវ ចំណាត់ថ្នាក់ផ្លូវ និងស្ថានភាពផ្លូវ ដែលអាចធ្វើឱ្យអ្នកបើកបរមានស្មារតីប្រុងប្រយ័ត្នជាមុនបាន។ ចំណែកនៅក្នុងក្រុងបាត់ដំបងវិញ ការរៀបចំដំឡើងភ្លើងសញ្ញាចរាចរណ៍ ត្រូវបានអាជ្ញាធរក្រុងបាត់ដំបងដំឡើងភ្លើងស្តុបចំនួន៩កន្លែង ក្នុងមួយកន្លែងមាន០៤ភ្លើងស្តុប៖ ភ្លើងស្តុបបាណន់ ភ្លើងស្តុបដំណាក់ហ្លួង ភ្លើងស្តុបមុនីវង្ស ភ្លើងស្តុបរំចេក ភ្លើងស្តុបផ្សារ១៣មករា ភ្លើងស្តុបផ្សារលើ ភ្លើងស្តុប២ធ្នូ ភ្លើងស្តុបផ្លាស្លា និងភ្លើងស្តុបឃុំវ័ន្ត[52]។ ការដាក់ភ្លើងស្តុបនេះ គឺអាចជួយដល់យើងបានច្រើន អាចជួយដល់ការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងអាចជួយសម្រួលដល់ការកកស្ទះផងដែរ។

➢ **ការដាក់គំនូសសញ្ញាចរាចរណ៍**

ការដាក់គំនូសសញ្ញាចរាចរណ៍មានសារៈសំខាន់ណាស់សម្រាប់អ្នកធ្វើដំណើរលើដងផ្លូវ ដែលបានបង្កលក្ខណៈងាយស្រួលសម្រាប់អ្នកបើកបរ និងអ្នកថ្មើរជើងដែលបានធ្វើការបែងចែកសិទ្ធិអាទិភាពនៃការបើកបរលើដងផ្លូវ ដូចជាគំនូសសញ្ញាពណ៌សកាត់ទទឹងផ្លូវ គំនូសសញ្ញាតាមបណ្តោយទ្រូងផ្លូវ គំនូសសញ្ញាព្រួញលើទ្រូងផ្លូវ គំនូសសញ្ញាផ្សេងៗលើទ្រូងផ្លូវ។

➢ **ការដាក់ស្លាកសញ្ញាចរាចរណ៍**

ដោយសារតែការកើនឡើងនៃចំនួនយានយន្តគ្រប់ប្រភេទ ជាពិសេសរថយន្ត ដែលជាកត្តាធ្វើឱ្យមានការកកស្ទះចរាចរណ៍បណ្តាលមកពីការចតរថយន្តគ្មានសណ្តាប់ធ្នាប់នោះ រដ្ឋបាលខេត្តបាត់ដំបងសហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត បានរៀបចំដាក់បង្គោលស្លាកសញ្ញាចរាចរណ៍ ហាមចតថ្ងៃសេស និងថ្ងៃគូនៅតាមបណ្តោយផ្លូវលេខ១ នៃក្រុងបាត់ដំបង។ មន្ត្រីជំនាញរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តបានបញ្ជាក់ថា ស្លាកសញ្ញាហាមចតថ្ងៃសេស និងថ្ងៃគូ ដែលត្រូវបានដាក់នេះមានចំនួន១៦ស្លាកត្រូវបាននាំយក

[51] សេចក្តីជូនដំណឹង ស្តីពីការកែលម្អ និងការរៀបចំសណ្តាប់ធ្នាប់ សោភ័ណភាពនៅក្នុងតំបន់អគារអភិរក្ស ក្រុងបាត់ដំបង

[52] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទំព័រទី១៣

ដាក់ដាំអមសងខាងតាមដងផ្លូវលេខ១ និងមួយចំនួនទៀតយកទៅដាក់នៅត្រង់ចំណុចចំណតរថយន្តតូចផ្សារធំបាត់ដំបង ហើយតាមគ្រោងទុករបស់មន្ទីរ និងមានការដាក់ស្លាកសញ្ញានេះជាបន្តបន្ទាប់ទៀតនៅតាមទីប្រជុំជនផ្សេងៗទៀតផងដែរ។[53]

### ២.១.១.២. ការរៀបចំសំណង់អគារ និងតាមដងផ្លូវ

ប្រទេសកម្ពុជា ជាប្រទេសដែលស្ថិតនៅក្រោមដំបូលសន្តិភាព អរគុណសន្តិភាព និងស្ថិតក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ទើបធ្វើឱ្យប្រទេសកម្ពុជាមានការអភិវឌ្ឍគ្រប់វិស័យទាំងអស់។ ជាក់ស្តែងដូចជាវិស័យស្ថាបត្យកម្ម និងសំណង់ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ជាពិសេសសន្ទុះនៃការកើនឡើងនូវចំនួនសំណង់អគារតូច ធំ ខ្ពស់ ទាប ច្រើនម៉ូត ច្រើនសណ្ឋាននៅតាមបណ្តាខេត្តក្រុង។ ក្រុងបាត់ដំបងត្រូវបានចាត់ទុកថាជាទីក្រុងមួយរបស់ខេត្តបាត់ដំបងដែលមានសំណង់អគារផ្ទះល្វែងបានបន្សល់ទុកតាំងពីសម័យអាណានិគមបារាំង។ បច្ចុប្បន្នសំណង់ទាំងនេះកំពុងត្រូវបានធ្វើការអភិរក្សឱ្យក្លាយជាតំបន់ការពារបេតិកភណ្ឌជាតិដ៏មានតម្លៃ ក្នុងកិច្ចការថែរក្សាការពារនូវវប្បធម៌ដ៏សម្បូរបែបព្រមទាំងតម្លៃប្រវត្តិសាស្ត្ររបស់ក្រុងបាត់ដំបងក៏ដូចជាប្រទេសកម្ពុជា។ ការងារអភិរក្សតំបន់បេតិកភណ្ឌនេះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់មនុស្សជំនាន់ក្រោយបានសិក្សាស្វែងយល់ និងបានរៀនសូត្រយ៉ាងច្រើនអំពីប្រវត្តិសាស្ត្រ ដើមកំណើត និងវប្បធម៌របស់ទីក្រុងបាត់ដំបង។

ដើម្បីចូលរួមលើកកម្ពស់សោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយ និងគុណតម្លៃនៃសំណង់អគារអភិរក្សក្នុងទីប្រជុំជនក្រុងបាត់ដំបង ខណៈដែលភ្ញៀវទេសចរកំពុងតែត្រូវការទីតាំងសម្រាប់ការដើរលំហែកាយ និងការទស្សនាអគារបុរាណក្នុងក្រុងបាត់ដំបងនេះ រដ្ឋបាលខេត្តនឹងត្រៀមរៀបចំបន្តទៀតអំពីសណ្តាប់ធ្នាប់ក្នុងតំបន់អគារអភិរក្សចាប់ពីផ្លូវលេខ១ ដល់ផ្លូវលេខ៣ ចាប់ពីចំណុចវត្តដំរីស ដល់វត្តពិភិធធារាម និងលំនៅដ្ឋានជុំវិញផ្សារធំបាត់ដំបង ឬផ្សារណាត់ ដោយតម្រូវឱ្យម្ចាស់លំនៅឋាន និងអាជីវកម្មទាំងអស់នៅក្នុងទីតាំងទាំងនេះចូលរួមអនុវត្តតាមការកំណត់របស់រដ្ឋបាលខេត្ត។[54]

បើយោងទៅតាមសេចក្តីជូនដំណឹងរដ្ឋបាលខេត្តបាត់ដំបងស្តីពីការកែលម្អ និងការរៀបចំ សណ្តាប់ធ្នាប់សោភ័ណភាពនៅក្នុងតំបន់អគារអភិរក្សក្រុងបាត់ដំបងដែលក្នុងនោះគឺ តម្រូវឱ្យមានការដកបង្គោលផ្សព្វផ្សាយពាណិជ្ជកម្មទាំងអស់ចេញពីលើចិញ្ចើមផ្លូវ ការកាត់តម្រឹមសំយ៉ាប និងផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្មព្រមទាំងស្លាកយីហោគ្រប់ប្រភេទ ដើម្បីឱ្យសមស្របតាមបទប្បញ្ញត្តិដែលស្តីពីការដាក់តាំងស្លាកផ្សព្វផ្សាយពាណិជ្ជកម្ម និងស្លាកយីហោតាមមុខផ្ទះក្នុងតំបន់អភិរក្ស ដោយមិនអនុញ្ញាតឱ្យអាជីវករយកទំនិញគ្រប់ប្រភេទដាក់តាំងលក់

[53] គេហទំព័រ https://sbm.news/articles/622757d2e0e4eed3032078e3 ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២

[54] គេហទំព័រ https://www.battambang.gov.kh/detail/17557 ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២

លើចិញ្ចើមផ្លូវមុខផ្ទះឡើយ។[55] នេះបើតាមប្លង់គោលរបស់រដ្ឋបាលក្រុងបាត់ដំបងបានបញ្ជាក់ថាសំណង់អគារផ្ទះល្វែងដែលជាសំណង់អភិរក្សមានក្នុងក្រុងបាត់ដំបងចំនួនប្រហែល៨០០អគារ ដែលបានសាងសង់ក្នុងដំណាក់កាលបីផ្សេងគ្នា ហើយវាបានឆ្លុះបញ្ចាំងពីប្រវត្តិនៃការអភិវឌ្ឍក្រុងបាត់ដំបង។ ការថែរក្សាតម្លៃបេតិកភណ្ឌវប្បធម៌ និងស្នាដៃស្ថាបត្យកម្មដែលជាមរតកដ៏កម្រនេះ សម្រាប់ទាក់ទាញកំណើនភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យមកទស្សនា និងធ្វើការស្រាវជ្រាវ ដើម្បីលើកកម្ពស់ដល់ការអភិវឌ្ឍវិស័យទេសចរណ៍ ដែលជាផ្នែកមួយដ៏សំខាន់នៃប្រភពចំណូលសម្រាប់សេដ្ឋកិច្ចមូលដ្ឋាន និងការថែរក្សានូវផលប្រយោជន៍ម្ចាស់ផ្ទះបច្ចុប្បន្ន និងផលប្រយោជន៍របស់សហគមន៍ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់អភិរក្សនេះ ព្រោះភ្ញៀវទេសចរនឹងមានការចាប់អារម្មណ៍ខ្លាំងក្នុងការស្វែងរកទីតាំងប្រវត្តិសាស្រ្តដែលត្រូវបានទាក់ទាញដោយសំណង់បេតិកភណ្ឌដែលនៅល្អៗជាច្រើនក្នុងក្រុងបាត់ដំបង។[56]

### ២.១.២. ការរៀបចំសោភ័ណភាពនាពេលយប់

សោភ័ណភាពពេលយប់ គឺសំដៅទៅលើការបំពាក់ភ្លើងបំភ្លឺតាមអគារនានា និងតាមដងមហាវិថីនានាក្នុងទីក្រុងជាពិសេសការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌ពេលរាត្រី និងនៅតាមសួនច្បារសាធារណៈផងដែរ។ ការលម្អសោភ័ណភាពនាពេលយប់មិនត្រឹមតែជាគ្រឿងលម្អតុបតែងតែប៉ុណ្ណោះទេតែជាការរៀបចំ ដែលធ្វើឱ្យទិដ្ឋភាពនៅក្នុងក្រុងមានភាពប្លែក ជួយបង្កើនសម្រស់ភាពទាក់ទាញដល់ភ្ញៀវទេសចរណ៍ឱ្យមកកំសាន្តបែបលក្ខណៈគ្រួសារ ឬបែបមិត្តភាពផ្សេងទៀត ជាពិសេសទៅទៀតអាចជួយបំភ្លឺផ្លូវដល់អ្នកដំណើរដែលនេះក៏អាចជួយឱ្យកាត់បន្ថយនូវគ្រោះថ្នាក់បានមួយកម្រិតផងដែរ។ ការរៀបចំសោភ័ណភាពនាពេលយប់រួមមាន៖ ការបំពាក់ភ្លើងតាមដងផ្លូវ និងការបំពាក់ភ្លើងចម្រុះពណ៌តាមសួនច្បារ និងទីកន្លែងសាធារណៈ។

#### ២.១.២.១. ការដាំបង្គោលភ្លើងអគ្គិសនី

ការដាំបង្គោលភ្លើងអគ្គិសនីតាមដងផ្លូវនាពេលយប់ ជាកត្តាមួយជួយលើកកម្ពស់សោភ័ណភាពនៅក្នុងក្រុងជាពិសេស គឺការបំភ្លឺផ្លូវនាពេលរាត្រីសម្រាប់អ្នកដំណើរទៅវិញទៅមកតាមដងផ្លូវ។ ដើម្បីជាការឆ្លើយតបទៅនឹងតម្រូវការ ព្រមទាំងការរក្សានូវសុខសន្តិសុខរបស់ប្រជាពលរដ្ឋដែលរស់នៅតាមស្រុកនានាក្នុងក្រុងបាត់ដំបង អាជ្ញាធរនៃរដ្ឋបាលបាត់ដំបងបានរៀបចំឱ្យដំណើរការនូវការការដាំបង្គោលភ្លើងអគ្គិសនី ដើម្បីសម្រួលដល់ការធ្វើចរាចររបស់ប្រជាពលរដ្ឋ ជាពិសេសទប់ស្កាត់មិនឱ្យមានបទល្មើសនៅក្នុងក្រុងនាពេលយប់។ ដូច្នេះហើយទើប

[55] សេចក្តីជូនដំណឹង ស្តីពីការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈតាមបណ្តោយផ្លូវលេខ២ ចាប់ពីវត្តដំរីសរហូតដល់ផ្លូវជាតិលេខ៥

[56] គេហទំព័រ http://moinews.gov.kh/news/1408 ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២

អាជ្ញាធរនៃរដ្ឋបាលខេត្តបាត់ដំបងរៀបចំមានបង្គោលភ្លើងប្រើប្រាស់សម្រាប់បំភ្លឺផ្លូវសាធារណៈក្នុងក្រុងបាត់ដំបង សរុបមានចំនួន៨៨៨ដើម។[57]

**២.១.២.២. ការបំពាក់លើចម្រុះពណ៌តាមសួនច្បារ និងទីកន្លែងសាធារណៈ**

ចំពោះការបំពាក់ភ្លើងនៅតាមសួនច្បារយើងសង្កេតឃើញថាក្រុងក៏បានយកចិត្តទុកដាក់ផងដែរដើម្បីធ្វើយ៉ាងណា ដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវឱ្យកាន់តែមានភាពស្រស់ស្អាតមួយកម្រិតទៀតដោយអាជ្ញាធររដ្ឋបាលក្រុងបានដាក់ភ្លើងចម្រុះជាច្រើនពណ៌នៅតាមបង្គោលភ្លើង៖

- បំភ្លឺផ្លូវតាមបណ្តោយសួនច្បារមានសរុបចំនួន៤៤៤ដើម
- ផ្ទាំងប៉ាណូបំភ្លឺតាមដងផ្លូវសរុបចំនួន២៤ប៉ាណូ
- អំពូលលម្អតាមស្ពានសរុបចំនួន១២កន្លែង
- ស្ពានសម្តេចហ៊ុនសែន ស្ពានថ្មចាស់ ស្ពានសម្តេចក្រឡាហោម ស្ពានស្ទឹងសង្កែ សរុបចំនួន៩៩៤អំពូល
- អំពូលភ្លើងតាមរង្វង់មូល និងអាង៦កន្លែង យាយទេព ព្រះនារាយណ៍ តាដំបងក្រញូង និងព្រាបសសរុបចំនួន៣១អំពូល
- តាមអាងបាញ់ទឹកមាន៤មាន៖ អាងនាគបាញ់ទឹក អាងខាងកើតផ្សារណាត់ អាងសម្តេចក្រឡាហោម និងអាងនាគសន្តិភាព។[58]

មិនតែប៉ុណ្ណោះរដ្ឋបាលក្រុងក៏បានបង្កើនការលម្អអគារមួយចំនួនដូចជាអគារសាធារណៈ និងឯកជន។ យើងក៏បានដឹងមកហើយថា បច្ចុប្បន្នក្រុងបាត់ដំបងគឺ ជាក្រុងមួយដែលមានសក្តានុពលខ្លាំង ដែលពោរពេញទៅដោយសំណង់អគារលក្ខណៈអភិរក្ស ដែលមានការលម្អ និងរំលេចទៅដោយភ្លើងពណ៌ចម្រុះជាច្រើនដែលធ្វើឱ្យសំណង់អគារទាំងនោះឱ្យមានភាពស្រស់ និងស្អាតលេចធ្លោទៅតាមការច្នៃប្រឌិតរបស់ម្ចាស់អគារនីមួយៗ។ ការបំពាក់ភ្លើង ចម្រុះនៅតាមអគារទាំងនោះ យើងសង្កេតឃើញថាមានភាពកាន់តែពិសេសទៅទៀត គឺនៅពេលថ្ងៃបុណ្យជាតិផ្សេងៗមានការតុបតែងយ៉ាងល្អវិចិត្រនៅតាមអគារនីមួយៗ មិនតែប៉ុណ្ណោះវាក៏ជាផ្នែកមួយដែលទាក់ទាញនូវសាធារណជនមកទស្សនាលេងកម្សាន្ត និងមានការចាប់អារម្មណ៍ទៅលើសោភ័ណភាពរបស់ទីក្រុងផងដែរ។

[57] សៀវភៅផែនការអភិវឌ្ឍក្រុង៥ឆ្នាំ ក្រុងបាត់ដំបង (២០២០-២០២៤) ទំព័រទី២២

[58] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២១-២០១៣) ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទំព័រទី១៣

### ២.១.៣. វិស័យទេសចរណ៍

កត្តាសន្តិសុខក្នុងក្រុងបាត់ដំបង ក៏មានភាពល្អប្រសើរនៅទូទាំងស្រុកនៅក្រុងបាត់ដំបងគ្រប់ពេលវេលា សម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិមកលំហែកម្សាន្ត ទស្សនា និងស្នាក់នៅក្នុងក្រុងបាត់ដំបងប្រកបដោយផាសុកភាព និងសប្បាយរីករាយ។

- **សេវាកម្មបម្រើឱ្យវិស័យទេសចរណ៍**

ដើម្បីបម្រើឱ្យវិស័យទេសចរណ៍កាន់តែមានការរីកចម្រើនក្នុងក្រុងបាត់ដំបង ក៏បានអភិវឌ្ឍនូវសកម្មភាពនានាក្នុងក្រុងឱ្យកាន់តែមានសោភ័ណភាព ផាសុកភាព រក្សាបាននូវអនាម័យល្អ និងតម្លៃថោកសមរម្យផងដែរ។ សេវាកម្មរួមមាន៖ សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន មណ្ឌលកំសាន្តជាដើម។ ក្រៅពីនេះក្រុងយកចិត្តទុកដាក់កែលម្អទីក្រុងទីប្រជុំជននានាឱ្យកាន់តែមានសោភ័ណភាពថែមទៀត ជាក់ស្តែងនៅក្នុងក្រុងបាត់ដំបងបានកែលម្អច្រាំងស្ទឹងសង្កែ ដោយចាក់បេតុងការពារភ្លៀងតាមបណ្តោយផ្លូវជាតិលេខ៥ ពីចំណុចព្រំប្រទល់ស្រុកសង្កែមករូបសំណាកតាដំបងក្រញូង បង្កើតផ្លូវភ្លោះតាមបណ្តោយផ្លូវជាតិ៥៧ ពីពេទ្យពពីទៅរង្វង់មូលនាងគង្ហីង និងកែលម្អសួនតាមបណ្តោយស្ទឹងសង្កែ សួនច្បារនាគបាញ់ទឹក សួនច្បារព្រែកមហាទេព និងយកចិត្តទុកដាក់អភិរក្សនូវសំណង់ចាស់ៗនៅក្នុងក្រុងបាត់ដំបងផងដែរសម្រាប់ប្រយោជន៍នៃវិស័យទេសចរណ៍ និងបានខិតខំដោះស្រាយបញ្ហាពាក់ព័ន្ធការស្តារប្រឡាយ ជួសជុលប្រព័ន្ធលូរំដោះទឹកតាមបណ្តាសង្កាត់មានភាពទ្រុឌទ្រោម និងកកស្ទះនាំឱ្យមានផលប៉ះពាល់បញ្ហាបរិស្ថាន ការគ្រប់គ្រងកាកសំណល់រឹងរាវ ស្តែងចេញនូវសោភ័ណភាព អនាម័យស្ថិតក្នុងគោលដៅជាយុទ្ធសាស្ត្ររបស់ជាតិ ទីក្រុងស្អាត តំបន់បៃតង បានកសាងសួនច្បារ ផ្លូវភ្លោះ ភ្លើងអគ្គិសនីបំភ្លឺផ្លូវសាធារណៈ ភ្លើងស្តុប សួនហាត់ប្រាណជាសាធារណៈ បន្ទប់ទឹកអនាម័យ ប្រកបដោយសោភ័ណភាព និងអនាម័យសម្រាប់សាធារណជនជាមូលដ្ឋានបង្កលក្ខណៈងាយស្រួលជូនភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិទស្សនាកំសាន្តមានកំណើនកើនឡើង។[59]

- **រមណីយដ្ឋានវប្បធម៌**

មាន៣កន្លែង គឺភូមិវប្បធម៌ សារមន្ទីរខេត្ត និងតំបន់បេតិកភណ្ឌ ជាពិសេសក្រុងបាត់ដំបង ជាក្រុងបេក្ខភាពប្រឡងប្រណាំងទីក្រុងស្អាត ហើយថែមទាំងទទួលបានជ័យលាភីផ្ការំដួល៣ទងទូទាំងព្រះរាជាណាចក្រកម្ពុជាពីគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតនិងត្រូវបានទទួលស្គាល់ជាទីក្រុងបេតិកភណ្ឌពិភពលោកដោយអង្គការយូណេស្កូ បានទទួលជ័យលាភីនិរន្តរបរិស្ថានអាស៊ានលើកទី៣ឆ្នាំ២០១៤ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។[60]

[59] សៀវភៅផែនការអភិវឌ្ឍក្រុង៥ឆ្នាំ ក្រុងបាត់ដំបង (២០២០-២០២៤) ទំព័រទី១៧

[60] សៀវភៅផែនការអភិវឌ្ឍក្រុង៥ឆ្នាំ ក្រុងបាត់ដំបង (២០២០-២០២៤) ទំព័រទី១៨

មូលដ្ឋានអាជីវកម្មទេសចរណ៍នៅក្នុងក្រុងបាត់ដំបងមានៈ

- សណ្ឋាគារៈ ៤២កន្លែង មានបន្ទប់សរុបចំនួន១៧៤៦បន្ទប់
  - បន្ទប់គ្រែ១ៈ ៧៣៥បន្ទប់
  - បន្ទប់គ្រែ២ៈ ១០១១បន្ទប់
  - សាលប្រជុំៈ ២២សាល។
- ផ្ទះសំណាក់ៈ ៦៨កន្លែង មានបន្ទប់សរុបចំនួន១២៣៣បន្ទប់
  - បន្ទប់គ្រែ១ៈ ៨៨៨បន្ទប់
  - បន្ទប់គ្រែ២ៈ ៣៤៥បន្ទប់

  ក្នុងនោះមានផ្ទះសំណាក់កំពុងសាងសង់ចំនួន០៤កន្លែង។[61]
- ភោជនីយដ្ឋាន-អាហារដ្ឋានៈ ចំនួន១០៩កន្លែងដែលមានតុចំនួន១៧៣០ និងកៅអីចំនួន៧៧៨៩
- ខារ៉ាអូខេៈ ១១កន្លែង ស្មើនឹង១២០បន្ទប់
- រង្គសាលៈ មាន០១កន្លែង
- ទីភ្នាក់ងារទេសចរណ៍ៈ ០២សាខា
  - ក្រុមហ៊ុនកាពីតូលទេសចរណ៍
  - ក្រុមហ៊ុនអេស៊ានត្រែល
- ក្រុមហ៊ុនដឹកជញ្ជូនតាមផ្លូវគោកៈ ១៨សាខា
  - ក្រុមហ៊ុនកាពីតូលទេសចរណ៍
  - ក្រុមហ៊ុនអេស៊ានត្រែល
  - ក្រុមហ៊ុនកាពីតូលទេសចរណ៍
  - ក្រុមហ៊ុនរិទ្ធិមុនី
  - ក្រុមហ៊ុនពន្លឺអង្គរខ្មែរ (ភ្នំពេញពេញចិត្ត)
  - ក្រុមហ៊ុនភ្នំពេញសូរិយា
  - ក្រុមហ៊ុនរស្មីភ្នំពេញ
  - ក្រុមហ៊ុនថោងស៊ីងស៊ីង
  - ក្រុមហ៊ុនបាយ័ន វីអាយភី

[61] កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទំព័រទី២០

- ក្រុមហ៊ុនខេមប៊ូត្រា វីអាយភី
- ក្រុមហ៊ុនស៊ីអេធីខេមបូឌា អ៊ិចត្រាវែល វីអាយភី
- ក្រុមហ៊ុនវុឌ្ឍន៍សុភាព
- ក្រុមហ៊ុនលាំងយូអេស
- ក្រុមហ៊ុនវិរៈប៊ុនថាំ វីអាយភី
- ក្រុមហ៊ុនត្រាវែលមានជ័យ វីអាយភី
- ក្រុមហ៊ុនថេរ៉ូអ៊ិចប្រេស វីអាយភី
- ក្រុមហ៊ុនអូឡាំពិក វីអាយភី
- ក្រុមហ៊ុនខេអេសវី វីអាយភី
- ក្រុមហ៊ុនមានជ័យ វីអាយភី
- ក្រុមហ៊ុនបូព៌ាអាស៊ី វីអាយភី

ការគ្រប់គ្រង ការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ ថ្នាក់ក្រសួង ថ្នាក់មន្ទីរ និងថ្នាក់ក្រុង

- ថ្នាក់ក្រសួងចំនួន៣៨កន្លែង
- ថ្នាក់មន្ទីរចំនួន៩៧កន្លែង
- ថ្នាក់ក្រុងចំនួន៩៥សេវា។[62]

### ២.១.៣.១. ចលនាប្រឡងប្រណាំងទីក្រុងស្អាតរបស់កម្ពុជា

ការប្រឡងប្រណាំងទីក្រុងស្អាតនេះនឹងត្រូវរៀបចំជារៀងរាល់៣ឆ្នាំម្តង ហើយទីក្រុងជ័យលាភីនឹងទទួលបានពានរង្វាន់ និងស្លាកសញ្ញាដែលមានសុពលភាពសម្រាប់រយៈពេល៣ឆ្នាំ ក្រោមការតាមដាន និងវាយតម្លៃដោយគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតក្នុងគោលបំណងធ្វើឱ្យប្រទេសកម្ពុជាស្អាត និងបៃតង សេវាកម្មប្រកបដោយគុណភាពខ្ពស់ និងជំរុញគ្រប់កន្លែងទាំងអស់មានបដិសណ្ឋារកិច្ចល្អ។ ស្លាកសញ្ញាជ័យលាភីដែលត្រូវបានចែកចេញជា៣កម្រិត។

- **ឡាបិលរូបផ្កាវិជ្ជលា៣ទង៖** នឹងត្រូវប្រគល់ជូនទីក្រុងណាដែលបានទទួលពិន្ទុចាប់ពី៥៨ដល់៧៧ពិន្ទុ (យ៉ាងហោចណាស់ ស្មើនឹង៧៥% នៃចំនួនពិន្ទុសរុប) ។
- **ឡាបិលរូបផ្កាវិជ្ជលា២ទង៖** នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបានពិន្ទុចាប់ពី៤៦ដល់៥៧ពិន្ទុ (យ៉ាងហោចណាស់ ស្មើនឹង៦០% នៃចំនួនពិន្ទុសរុប)។

[62] កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) ក្រុងបាត់ដំបង ខេត្តបាត់ដំបង ទំព័រទី២០

- **ឡាបិលរូបផ្ការំដួល១ទង៖** នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបានពិន្ទុចាប់ពី៣១ដល់៤៥ពិន្ទុ (យ៉ាងហោចណាស់ ស្មើនឹង៤០%នៃពិន្ទុសរុប)។[63]

ចលនាប្រឡងប្រណាំងទីក្រុងស្អាតបានប្រារព្ធធ្វើឡើងចំនួនពីរដងរួចមកហើយ ក្រុងបាត់ដំបងក៏ធ្លាប់បានទទួលពានរង្វាន់ជ័យលាភីចំនួនទាំងពីរលើក ដែលលើកទី១គឺ ទីក្រុងស្អាតជ័យលាភីលេខ១ ផ្ការំដួល៣ទង (២០១៥-២០១៨) ដែលពិធីទទួលធ្វើនៅរាជធានីភ្នំពេញ និងលើកទី២ គឺទីក្រុងស្អាតផ្ការំដួល៣ទងលើកទី២ (២០១៨-២០២១) ដែលពិធីទទួលធ្វើនៅរាជធានីភ្នំពេញដដែល។ សូមបញ្ជាក់ផងដែរថាកាលពីថ្ងៃទី១៨-១៩ ខែកក្កដា ឆ្នាំ២០២២នេះ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត នៃក្រសួងទេសចរណ៍បានចុះពិនិត្យផ្ទៀងផ្ទាត់ និងវាយតម្លៃចលនាប្រឡងប្រណាំងទីក្រុងស្អាតលើកទី៣ដើម្បីរក្សាឱ្យនូវបេក្ខភាពជ័យលាភីផ្ការំដួល៣ទង និងដើម្បីរក្សាកំណើនភ្ញៀវទេសចរជាតិ-អន្តរជាតិ និងអ្នកវិនិយោគនៅក្នុងបាត់ដំបង ខេត្តបាត់ដំបងកាន់តែច្រើនបន្ថែមទៀត ព្រមទាំងសំដៅបង្កើតឱកាសការងារ និងប្រាក់ចំណូលក្នុងការចូលរួមចំណែកដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងសហគមន៍ស្របតាមគោលនយោបាយចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**ហេតុអ្វីត្រូវចូលរួមការប្រឡងប្រណាំងទីក្រុងស្អាត?**

- ជួយលើកកម្ពស់ជីវភាព និងមជ្ឈដ្ឋានរស់នៅរបស់ប្រជាពលរដ្ឋនៅតាមបណ្តាទីក្រុង
- ជួយពង្រឹង និងលើកកម្ពស់រូបភាពនៅតាមបណ្តាទីក្រុងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- ជាឧបករណ៍ផ្សព្វផ្សាយសេវាកម្មបៃតង
- ចូលរួមការការពារ និងលើកកម្ពស់បរិស្ថាន
- ពង្រឹង និងអភិវឌ្ឍសេដ្ឋកិច្ចនៅតាមបណ្តាទីក្រុង
- ធ្វើឱ្យមានសមភាពក្នុងសង្គម ពិសេសការកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៍ដោយជំរុញ និងពង្រីកលំហូរភ្ញៀវទេសចរទៅគ្រប់តំបន់នៃព្រះរាជាណាចក្រកម្ពុជា។[64]

ដើម្បីឱ្យចលនានេះសកម្មរស់រវើក និងផុលផុសនោះ គឺត្រូវធ្វើឱ្យប្រាកដថាក្រុមជ័យលាភីត្រូវតែមានតម្លៃតបស្នងដ៏ស័ក្តិសមបំផុត។ តាមរយៈនេះក្រុមជ័យលាភីនៃចលនាប្រឡងប្រណាំងទីក្រុងស្អាតនេះនឹងត្រូវផ្តល់នូវផលប្រយោជន៍ដូចជា៖

- **ទី១៖** ទទួលនូវស្លាកសញ្ញាជាការលើកទឹកចិត្តក្នុងការថែរក្សា និងលើកកម្ពស់ស្តង់ដាបរិស្ថានទីក្រុងឱ្យមានសោភ័ណភាព ដែលជាកិត្តិយសមួយសម្រាប់ទីក្រុងជ័យលាភី។

[63] គេហទំព័រ https://kohsantepheapdaily.com.kh/article/36500.html ដកស្រង់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២

[64] គេហទំព័រ http://www.cambodiacleancity.gov.kh/kh ដកស្រង់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២

- **ទី២៖** ជួយលើកកម្ពស់កិត្តិនាម និងឧត្តមភាពរបស់ទីក្រុងបង្ហាញដល់អ្នកទេសចរ និងគ្រប់ភាគីពាក់ព័ន្ធ ពិសេសវិនិយោគិន អង្គការជាតិ និងអន្តរជាតិ។

លទ្ធផលដ៏ប្រណីតនេះនឹងរួមចំណែកយ៉ាងសំខាន់សម្រាប់លើកកម្ពស់លក្ខខណ្ឌរស់នៅរបស់ប្រជាជនក្នុងទីក្រុងទាំងឱ្យមានភាពកាន់តែប្រសើរ មានបរិស្ថានសង្គមល្អស្អាតក្នុងទីក្រុង និងនៅតាមទីប្រជុំជន។ ចំណុចនេះនឹងបង្កើតភាពទាក់ទាញនៃវិស័យទេសចរណ៍បន្ថែមទៀតផង ពីព្រោះថាវិស័យទេសចរណ៍នឹងមិនពឹងផ្អែកលើផលិតផលទេសចរណ៍តែមួយមុខប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាស្រ័យបានទៅលើចីរភាព និងគុណភាពនៃបរិស្ថាន និងសេវាសាធារណៈផងដែរ។[65]

### ២.១.៣.២. ជ័យលាភីជាទីក្រុងទេសចរណ៍ស្អាតអាស៊ាន

ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន (ASEAN Clean Tourist City Standard) គឺជាគំនិតផ្តួចផ្តើមរបស់កម្ពុជាដែលជាប្រទេសនាំមុខក្នុងការរៀបចំ ហើយបានដាក់ឱ្យអនុម័តដាក់ឱ្យដំណើរការដោយរដ្ឋមន្ត្រីទេសចរណ៍អាស៊ាននាឱកាសកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន (M-ATM) លើកទី១៨ កាលពីដើមខែមករា ឆ្នាំ២០១៥ នៅទីក្រុងណៃពិដោ ប្រទេសមីយ៉ាន់ម៉ា។[66] តាមរយៈការដាក់ឱ្យដំណើរការស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាននេះ បណ្តាប្រទេសជាសមាជិកអាស៊ានបានប្តេជ្ញាចិត្តក្នុងការនឹងបន្តអភិវឌ្ឍទីក្រុងទេសចរណ៍ទាំងអស់ជាទីក្រុងស្អាត ទីក្រុងបៃតង ទីក្រុងមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងជាទីក្រុងទេសចរណ៍ប្រកបដោយការទាក់ទាញ និងប្រកួតប្រជែងខ្ពស់ដែលជាកត្តាគន្លឹះ និងមូលដ្ឋានដើម្បីធានានិរន្តរភាពនៃកំណើនទេសចរណ៍ និងក៏ជាមូលដ្ឋានទ្រទ្រង់ដល់ការធ្វើសមាហរណកម្មកម្ពុជាក្នុងតំបន់អាស៊ានផងដែរ។

ចលនាប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ាន បានប្រារព្ធធ្វើឡើងចំនួនពីរដងរួចមកហើយ ក្រុងបាត់ដំបងធ្លាប់បានទទួលពានរង្វាន់ដែលមានដូចជាជ័យលាភីជាទីក្រុងទេសចរណ៍ស្អាតអាស៊ានលើកទី១ សុពលភាពឆ្នាំ (២០១៨-២០២០) និងជ័យលាភីជាទីក្រុងទេសចរណ៍ស្អាតអាស៊ានលើកទី២ សុពលភាពឆ្នាំ (២០២២-២០២៤)។ ការប្រគល់រង្វាន់នេះធ្វើឡើងដើម្បីពង្រឹងនូវភាពទាក់ទាញ និងបង្កើនភាពប្រកួតប្រជែងរបស់ទីក្រុងទេសចរណ៍អាស៊ាន ក៏ដូចជាពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍នៅតាមបណ្តាទីក្រុងរបស់អាស៊ានស្របតាមផែនការយុទ្ធសាស្ត្រទេសចរណ៍អាស៊ានឆ្នាំ (២០១៦-២០២៥) ដែលសំដៅធ្វើឱ្យអាស៊ានក្លាយជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព ភាពទាក់ទាញ និងភាពកក់ក្តៅដល់ភ្ញៀវទេសចរ។ ការប្រកួតប្រជែងនេះក៏ជំរុញដល់ការរៀបចំមជ្ឈដ្ឋាន និងការរស់នៅរបស់ប្រជាពលរដ្ឋតាមបណ្តាទីក្រុងក្នុងតំបន់អាស៊ានឱ្យកាន់តែប្រសើរឡើង និងព្រមទាំងចូលរួមយ៉ាងមានប្រសិទ្ធិភាពដល់ការអភិវឌ្ឍទីក្រុងប្រកបដោយ

[65] គេហទំព័រ https://kohsantepheapdaily.com.kh/article/36500.html ដកស្រង់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២

[66] គេហទំព័រ https://tourismcambodia.org/ ដកស្រង់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២

និរន្តរភាព សុវត្ថិភាព និងបរិយាបន្ន។ សូមបញ្ជាក់ថាស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ានត្រូវបានដឹកនាំរៀបចំឡើងដោយក្រសួងទេសចរណ៍កម្ពុជា និងគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតតាំងពីឆ្នាំ២០១១ ដោយមានការគាំទ្រពីរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន ហើយស្តង់ដានេះត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តជាផ្លូវការកាលពីវេទិកាទេសចរណ៍អាស៊ានឆ្នាំ២០១៥។[67]

## ២.២. បញ្ហាបរិស្ថាន និងដំណោះស្រាយ

ទន្ទឹមទៅនឹងការអភិវឌ្ឍឥតឈប់ឈរ និងការរីកចម្រើនស្ទើរតែគ្រប់វិស័យទាំងអស់ ក្នុងនោះដែរយើងសង្កេតឃើញថាបញ្ហាផ្សេងៗជាច្រើនបានកើតមាន ជាហេតុដែលធ្វើឱ្យមានការប៉ះពាល់ការអភិវឌ្ឍ និងប៉ះពាល់ដល់សោភ័ណភាពរបស់ប្រទេស ឬរដ្ឋ។

សព្វថ្ងៃនេះបញ្ហាបរិស្ថាន គឺជាបញ្ហាចម្បងមួយដែលបង្កនូវគ្រោះថ្នាក់ខ្លាំងក្លាជាងគេក្នុងចំណោមបញ្ហាដទៃទៀតដែលប៉ះពាល់សុខភាពប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈទាំងអស់។ ជាក់ស្តែងថ្វីត្បិតតែប្រទេសកម្ពុជាគឺជាប្រទេសដែលកំពុងអភិវឌ្ឍយ៉ាងណាក្តីក៏យើងឃើញពីសន្ទុះនៃការអភិវឌ្ឍយ៉ាងគំហុក ជាពិសេសខាងវិស័យសេដ្ឋកិច្ច និងឧស្សាហកម្មធំ តូចគ្រប់ប្រភេទ ប៉ុន្តែដោយសារកំណើនប្រជាជន និងការរីកចម្រើនផ្នែក សេដ្ឋកិច្ចយ៉ាងឆាប់រហ័សនេះហើយទើបធ្វើឱ្យមានការបង្កផលប៉ះពាល់បង្កឱ្យមានការបំពុលយ៉ាងខ្លាំងទៅដល់បរិស្ថាន។

- **បញ្ហាពាក់ព័ន្ធទៅនឹងប្រព័ន្ធទឹកស្អាត និងទឹកស្អុយ**
  - ប្រព័ន្ធបង្ហូរទឹកស្អុយ និងទឹកភ្លៀងមិនគ្រប់គ្រាន់ កន្លែងខ្លះស្ទះ
  - គ្មានលទ្ធភាពពង្រឹងសមត្ថភាពប្រើប្រាស់អាងប្រព្រឹត្តិកម្មទឹកស្អុយនៅសង្កាត់ចំការសំរោង
  - គ្មានអាងប្រព្រឹត្តិកម្មទឹកស្អុយនៅក្រុងប៉ែកខាងកើតស្ទឹងសង្កែ
  - ផ្លូវទឹកមួយចំនួនត្រូវរំលោភ និងខ្លះចាក់ដីលុប។
- **បញ្ហាពាក់ព័ន្ធទៅនឹងកាកសំណល់រឹង**
  - ទីលានចាក់សំរាមបច្ចុប្បន្ន ពុំមានស្តង់ដាបរិស្ថាន លិចទឹកក្នុងរដូវវស្សា និងឆេះនៅរដូវប្រាំង
  - ខ្វះការយល់ដឹង ការចូលរួមអនុវត្តពីសាធារណជនក្នុងការគ្រប់គ្រង និងសំអាតបរិស្ថានអនាម័យនៅទីសាធារណៈ
  - ខ្វះការយល់ដឹងអំពីកាតព្វកិច្ចអនាម័យកាកសំណល់
  - ខ្វះលទ្ធភាពកែច្នៃកាកសំណល់គ្រប់ប្រភេទ។[68]

[67] គេហទំព័រ https://www.information.gov.kh/articles/19804 ដកស្រង់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២

[68] សៀវភៅផែនការអភិវឌ្ឍក្រុង៥ឆ្នាំ ក្រុងបាត់ដំបង (២០២០-២០២៤) ទំព័រទី២១

### ២.២.១. ការបំពុលទឹក

គឺជាការធ្វើឱ្យកខ្វក់ទឹកនៅពេលសារធាតុបំពុលនានាបានហូរចូលក្នុងប្រភពទឹក។ ការបំពុលទឹក គឺជាបញ្ហាប្រឈមដ៏ធំមួយដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងស្ទើរតែគ្រប់ប្រទេសទាំងអស់ទូទាំងពិភពលោក។ សោភ័ណភាពបរិស្ថានអាចទទួលរងការជះឥទ្ធិពលផលអាក្រក់ខ្លាំងប៉ុណ្ណាពីការបំពុលទឹក គឺអាស្រ័យទៅតាមសកម្មភាពនៃការបំពុលនោះដែលភាគច្រើនកើតចេញពីទីកន្លែងមួយចំនួនដូចជា ទីក្រុង ទីប្រជុំជន ទីកន្លែងកម្សាន្តរមណីយដ្ឋាន និងទីសាធារណៈជាដើម។ កត្តាដែលអាចបង្កឱ្យមានការបំពុលទឹកមានដូចជា ៖

- ការបំពុលដោយសកម្មភាពមនុស្សដូចជា៖ ការបោះសំរាមចូលក្នុងទឹក ការបង្ហូរកាកសំណល់ផ្ទះបាយចូលក្នុងទឹក ការបន្ទោរបង់ ការបង្ហូរទឹកកង្វក់ ការបូមខ្សាច់ខុសបច្ចេកទេស។ល។
- ការបំពុលដោយសមាសធាតុគីមីដែលបង្ហូរចេញពីរោងចក្រឧស្សាហកម្ម និងសិប្បកម្មមួយចំនួនដូចជា បារត សំណ កាឌីមីញ៉ូម និងអាសេនិច ជីគីមី ថ្នាំសម្លាប់សត្វល្អិត
- ការបំពុលដោយអាកាសធាតុ តាមរយៈទឹកភ្លៀង ឬភ្លៀងអាស៊ីត
- ប្លាស្ទិក សំបកដបជ័រចូលទៅក្នុងទឹក
- កាកសំណល់វិទ្យុសកម្ម
- ជាតិពុលចេញពីកប៉ាល់ ទូក ឬនាវា៖ ការលេចធ្លាយប្រេង សាំង ការបង្ហូរប្រេងចូលក្នុងទឹក
- ការបង្ហូរកាកសំណល់ចេញពីរោងចក្រ ឧស្សាហកម្មចូលក្នុងទឹក។[69]

សកម្មភាពនៃការបំពុលទឹកជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងទៅលើបរិស្ថាន ហើយក៏ប៉ះពាល់ដោយផ្ទាល់និងប្រយោលដល់មនុស្ស សត្វ រុក្ខជាតិ ព្រមទាំងសោភ័ណភាពនៃទីក្រុង ឬតំបន់សាធារណៈផ្សេងៗផងដែរ។ តាមរយៈការប្រើប្រាស់ និងបរិភោគទឹកមិនស្អាតអាចបណ្តាលឱ្យប៉ះពាល់ដល់សុខភាពជាច្រើនដូចជា ជំងឺគ្រុនពោះវៀន គ្រុនចាញ់ អាសន្នរោគ រលាកថ្លើម គ្រុនលឿន រាគ និងជំងឺផ្សេងៗជាច្រើនទៀត។ មិនតែប៉ុណ្ណោះការបំពុលទឹកក៏ប៉ះពាល់ដល់វិស័យមួយចំនួនផងដូចជាវិស័យកសិកម្ម គឺនៅពេលដែលយើងយកទឹកដែលពោរពេញទៅដោយសារធាតុគីមីបង្កឡើងដោយកាកសំណល់រឹង ប្លាស្ទិកដែលកប់ក្នុងដី ឬត្រាំនៅក្នុងទឹក សារធាតុបារត សំណ កាឌីមីញ៉ូម អាសេនិច ជីគីមី ថ្នាំសម្លាប់សត្វល្អិត ភ្លៀងអាស៊ីតដែលបង្អុលចុះក្នុងប្រភពទឹក ហើយយើងក៏បានយកទឹកដែលមានសារធាតុគីមីនោះមកប្រើប្រាស់ ឬស្រោចស្រពលើដំណាំផល្លានុផលផ្សេងៗដែលអាចបង្កឱ្យដំណាំ ឬផលទាំងនោះរលួយ ខូចគុណភាព និងអាចបង្កហេតុអាក្រក់ដល់មនុស្ស សត្វទៀតផង។

---

[69] គេហទំព័រ https://km.warbletoncouncil.org/causas-consecuencias-contaminacion-agua-11450#menu-3 ដកស្រង់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២

➢ **ដំណោះស្រាយ**

- កម្រិតកំណត់ស្តង់ដានៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ
- ហាមឃាត់ជាដាច់ខាតរាល់ការបោះចោល ឬការបង្ហូរចេញនូវសំណល់រាវពីប្រភពបំពុលដែលផ្ទុយពីកម្រិតស្តង់ដាដែលបានកំណត់
- ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់នៅក្នុងតំបន់ទឹកសាធារណៈ ឬប្រព័ន្ធលូសាធារណៈ
- ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅដ្ឋាន ឬអគារសាធារណៈចូលទៅក្នុងតំបន់ទឹកសាធារណៈដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធចម្រោះសំអាតនានា
- អប់រំប្រជាជនឱ្យយល់ដឹងពីផលប៉ះពាល់ពីការចោលសំរាមទៅក្នុងទឹក និងផលប៉ះពាល់ដល់បញ្ហាសុខភាព
- រៀបចំឱ្យមានអាងប្រព្រឹត្តកម្ម អាងចម្រោះសំអាត មុននឹងបង្ហូរទឹកកខ្វក់ ឬទឹកស្អុយចូលទៅក្នុងប្រភពទឹកណាមួយ
- ចាត់វិធានការច្បាប់ឱ្យតឹងរឹងបំផុតដោយទទួលការផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់កំណត់។[70]

### ២.២.២. ការបំពុលដី

គឺជាដំណើរការនៃការរិចរិលគុណភាពនៃផ្ទៃផែនដីបណ្តាលមកពីសារធាតុគីមី និងដំណើរការផ្សេងទៀតនៃអន្តរាគមន៍របស់មនុស្ស។[71] កត្តាធំចំបងមួយដែលបណ្តាលឱ្យដីទទួលរងការបំពុលខ្លាំងជាងគេ គឺការបំពុលដោយសំរាម ឬកាកសំណល់។ សំរាមកើតមានឡើងគ្រប់ទិសទីមិនប្រកាន់ថានៅទីណានៅប្រទេសណាឡើយ។ ការទុកដាក់សំរាមមិនបានត្រឹមត្រូវ ឬចោលពាសវាលពាសកាលទៅលើដី គឺជាហេតុដែលបណ្តាលឱ្យមានការប៉ះពាល់ដល់ដី ជាពិសេសចំពោះប្រភេទនៃសំរាម ដែលមិនបានកែច្នៃឡើងវិញបាន ឬកាកសំណល់ផ្ទះបាយ។ ការគរសំរាមនៅទីកន្លែងណាមួយរយៈពេលយូរដូចជា ទីលានចាក់សំរាមជាដើម គឺអាចបណ្តាលឱ្យដីនៅកន្លែងនោះខូចគុណភាព ឬបាត់បង់ជីវជាតិ។ សំរាមមួយចំនួនដែលកប់ក្នុងដីត្រូវប្រើរយៈពេលយូរណាស់ទើបអាចរលាយអស់ទាំងស្រុង (ប្លាស្ទិក កំប៉ុង ឬដបជ័រ) ខណៈដែលសំរាមមួយចំនួនទៀតមានផ្ទុកសារធាតុពុលជាហេតុបណ្តាលឱ្យដីទទួលរងនូវការខូចទ្រង់ទ្រាយគុណភាពមិនអាចយកមកប្រើប្រាស់បាន។

---

[70] មាត្រា៤ មាត្រា៦ មាត្រា៨ និងមាត្រា៩ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក

[71] គេហទំព័រ https://km.warbletoncouncil.org/contaminaction-del-suelo-3188 ដកស្រង់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២

កត្តាផ្សេងៗទៀតដែលបណ្តាលឱ្យមានការបំពុលដីរួមមាន៖

- ការប្រើប្រាស់ជីគីមី ថ្នាំពុល ថ្នាំសម្លាប់សត្វល្អិត
- ការបន្ទុះភ្នំភ្លើង កំអែលភ្នំភ្លើង ផេះពីកំអែលភ្នំភ្លើង រញ្ជួយដី
- កាកសំណល់ឧស្សាហកម្ម សហគ្រាស
- ការបំពុលដោយកសិកម្ម។

ការបំពុលដី មិនត្រឹមតែអាចបង្កឡើងតាមកត្តាមួយចំនួនខាងលើប៉ុណ្ណោះទេ ការបំពុលអាចកើតតាមរូបភាពជាច្រើនទៀតដូចជា ប្រសិនបើសត្វពាហនៈដើររកចំណីនៅកន្លែងដែលគេបានចោលសំរាម ហើយមនុស្សបរិភោគ ឬចាប់សត្វទាំងនោះ ពួកយើងអាចនឹងមានជំងឺ ហើយនៅពេលដែលមានសំណល់អសរីរាង្គច្រើនត្រូវបានគេដុតនៅលើដី វាក៏អាចបង្កឱ្យមានការបំពុលដីផងដែរ។[72]

- **ដំណោះស្រាយ**
  - សិក្សាពីរូបធាតុផ្សំ និងផលប៉ះពាល់នៃជីគីមី
  - ប្រើប្រាស់ជីគីមីក្នុងបរិមាណសមល្មម
  - ប្រើប្រាស់ជីធម្មជាតិ (ជីកំប៉ុស)
  - បញ្ឈប់នូវការប្រើជីគីមីដែលស្ថិតក្នុងចំណាត់ថ្នាក់ហាមឃាត់
  - បញ្ឈប់រាល់សកម្មភាពនៃការបង្ហូរទឹកកខ្វក់
  - បញ្ឈប់រាល់សកម្មភាពនៃការចាក់ចោលសំរាម ឬសំណល់រឹងទៅលើដី
  - រៀបចំឱ្យមានកន្លែងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ
  - ជំរុញឱ្យប្រើប្រាស់របស់ដែលអាចកែច្នៃឡើងវិញបាន
  - កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក ដប ឬកំប៉ុងជ័រ
  - អប់រំដល់ប្រជាជនអំពីផលប៉ះពាល់នៃបរិស្ថាន ផលវិបត្តិនៃការបំពុលដីដែលអាចប៉ះពាល់ដល់សុខភាព និងជីវិតរបស់សត្វ រួមទាំងបរិស្ថានទាំងស្រុង
  - ចាត់វិធានការច្បាប់ឱ្យតឹងរឹងបំផុតចំពោះជនដែលល្មើសដោយទទួលនូវការដាក់ពិន័យ ឬផ្តន្ទាទោសតាមច្បាប់កំណត់។

---

[72] គេហទំព័រ http://livelearn.org/assets/media/docs/resources/GoodPeople_GoodEnv_flipchart_khm.pdf ដកស្រង់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២

### ២.២.៣. ការបំពុលខ្យល់

ខ្យល់ត្រូវបានបំពុលនៅពេលវាប៉ះពាល់ទៅនឹងភាពកខ្វក់នៃឧស្ម័នពុល និងភាគល្អិតតូចៗដែលនឹងត្រូវបញ្ចេញដោយរោងចក្រឧស្សាហកម្ម មធ្យោបាយដឹកជញ្ជូនទៅក្នុងបរិយាកាសខាងក្រៅ។[73] ជាទូទៅការបំពុលខ្យល់មានសភាពធ្ងន់ធ្ងរនៅក្នុងទីក្រុង តំបន់ឧស្សាហកម្ម តំបន់ទំនាប ឬតំបន់ដែលឡោមព័ទ្ធដោយភ្នំ និងកន្លែងមានខ្យល់បក់មិនល្អ មិនបរិសុទ្ធ និងការបំពុលខ្យល់អាចកើតចេញពីកត្តាជាច្រើនដូចជា ៖

- ការដុតឥន្ទនៈហ្វូស៊ីល (ប្រេង ធ្យូង ម៉ាស៊ូត សាំង)
- ការផ្ទុះភ្នំភ្លើង
- ចំហេះចេញពីគ្រឿងចក្រចាស់ៗ រថយន្ត ម៉ូតូ រថភ្លើង ម៉ាស៊ីនត្រជាក់
- ផ្សែងពុលចេញពីរោងចក្រឧស្សាហកម្មធំៗ សហគ្រាស
- ឧស្ម័នផ្ទះកញ្ចក់
- ផ្សែងពុលចេញពីឈាបនដ្ឋាន
- ការបំពុលដោយធូលី
- ការបម្រែបម្រួលអាកាសធាតុ
- ភ្លៀងអាស៊ីត។

ការបំពុលខ្យល់មិនត្រឹមតែធ្វើការបំផ្លាញទៅលើអាកាសធាតុបរិស្ថានទេ ជាពិសេសគឺបំផ្លាញយ៉ាងខ្លាំងដល់សុខភាពមនុស្ស សត្វ ពីព្រោះថាជីវិតមនុស្សត្រូវការខ្យល់ដើម្បីដកដង្ហើម និងបំលាស់ប្តូរឧស្ម័ននៅក្នុងខ្លួន តែបើយើងរស់នៅជាមួយបរិស្ថានដែលពោរពេញទៅដោយការបំពុលគ្រប់បែបយ៉ាង និងស្រូបដោយខ្យល់ពុលជាច្រើនជារៀងរាល់ថ្ងៃនោះវាអាចបណ្តាលឱ្យយើងប្រឈមនឹងជំងឺដូចជា ជំងឺមហារីក រលាកសួតធ្ងន់ធ្ងរ ការគាំងបេះដូង ការដាច់សរសៃឈាមខួរក្បាល មហារីកសួត និងជំងឺទាក់ទងនឹងប្រព័ន្ធផ្លូវដង្ហើមជាច្រើនទៀត។[74] ដូច្នេះហើយទើបយើងត្រូវមានចំណាត់ការទៅលើបញ្ហាបំពុលខ្យល់ឱ្យបានឆាប់រហ័សបំផុត។

- **ដំណោះស្រាយ**
  - កាត់បន្ថយការប្រើប្រាស់គ្រឿងចក្រចាស់ៗដោយរាជរដ្ឋាភិបាលត្រូវជំរុញប្រជាជនឱ្យប្រើប្រាស់មធ្យោបាយសាធារណៈ ដូចជារថយន្តក្រុងថ្មីៗ ឬប្រើប្រាស់ឧបករណ៍ដើរដោយអាគុយ ឬថាមពលពន្លឺព្រះអាទិត្យ ។

[73] គេហទំព័រ https://km.hesperian.org/hhg/A_Community_Guide_to_Environmental_Health:ការបំពុលខ្យល់ ដកស្រង់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២

[74] គេហទំព័រ https://km.eferrit.com/និយមន័យននការបំពុលខ្យល់/ ដកស្រង់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២

- កាត់បន្ថយការនាំចូលយានយន្តចាស់ៗ និងបន្ថយពន្ធនាំចូលយានយន្តថ្មីៗ
- រឹតបន្តឹងច្បាប់ចំពោះការដ្ឋាន និងឡានដឹកដីខ្សាច់ដែលខុសទៅនឹងបំរាម
- បញ្ឈប់ឱ្យមានការបូជាសពនៅក្នុងទីក្រុង
- បង្កើតឱ្យមានប្រព័ន្ធបន្សុទ្ធខ្យល់
- កាត់បន្ថយការដុតសំណល់ដូចជាសំណល់កសិកម្ម និងការដុតឈើ ដើម្បីកាត់បន្ថយនូវកម្រិតផ្សែង និងកាបូនឌីអុកស៊ីតនៅក្នុងខ្យល់
- ពន្យល់ប្រជាជនពីផលប៉ះពាល់នៃការបំពុលខ្យល់
- ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុពុលទៅក្នុងបរិយាកាស
- ហាមឃាត់ដាច់ខាតនូវការនាំចូល និងផលិតនូវសារធាតុឆេះដែលមានជាតិស្ពាន់ធ័រ
- ការបង្ករ ឬការធ្វើឱ្យលេចធ្លាយនូវសារធាតុឆេះ ប្រេងឥន្ធនៈ
- ហាមឃាត់ការបញ្ចេញវិទ្យុសកម្ម ឬសារធាតុគីមីទៅក្នុងបរិយាកាស។
- ចាត់វិធានការច្បាប់ឱ្យតឹងរឹងបំផុតចំពោះជនដែលល្មើសដោយទទួលការផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់កំណត់។[75]

### ២.២.៤. ការបំពុលដោយសំណល់រឹង រាវ

ប្រទេសកម្ពុជាក៏ដូចជាប្រទេសកំពុងអភិវឌ្ឍដទៃទៀត បញ្ហាបរិស្ថានជាបញ្ហាចោទដ៏ធំមួយដែលពិបាកគេច ក្នុងនោះការចោល និងការគ្រប់គ្រងសំណល់ក៏ជាបញ្ហាចម្បងក្នុងចំណោមបញ្ហាដែលបំពុលដល់បរិស្ថាន។ សំណល់ ឬសំរាមប្រភេទណាក៏ដោយក៏ជាប្រភព និងជម្រកនៃមេរោគដែរ សំណល់មិនថារឹង ឬរាវទេ សុទ្ធតែកើតចេញពីការរៀបចំទុកដាក់របស់មនុស្សទាំងអស់ តែបើខ្វះខាតការអនុវត្តការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវទេនោះ វានៅតែជាបញ្ហាចោទ និងជាសម្ពាធដ៏ធំសម្រាប់បរិស្ថានដដែល។[76]

➢ **ការបំពុលដោយសំណល់រឹង**

សំណល់រឹង គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់របរកំទិចកំទីដែលលែងត្រូវការ ឬប្រើប្រាស់ ហើយត្រូវបានគេបោះបង់ចោលមានបំណងនឹងបោះបង់ចោល ឬតម្រូវឱ្យបោះបង់ចោល។

ដើម្បីជាភាពងាយស្រួលក្នុងការប្រមូល ដឹកជញ្ជូន ចាត់ចែង និងគ្រប់គ្រងសំណល់រឹងឱ្យបានល្អ គេបានធ្វើការបែងចែកប្រភេទនៃសំណល់រឹងទៅតាមប្រភពដែលបង្កើតវា ដោយចែកចេញជាច្រើនប្រភេទផ្សេងៗដូចជា៖

[75] មាត្រា១០ មាត្រា១១ និងមាត្រា១២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ចុះនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០

[76] គេហទំព័រ https://opendevelopmentcambodia.net/km/topics/pollution-and-waste/ ដកស្រង់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២

សំណល់លំនៅដ្ឋាន ឧស្សាហកម្ម មន្ទីរពេទ្យ ពាណិជ្ជកម្ម និងសំណល់កសិកម្ម។ មិនត្រឹមតែបែងចែកជាប្រភេទប៉ុណ្ណោះទេ គេថែមទាំងចែកចំណាត់ថ្នាក់ជា២ គឺសំណល់ប្រកបដោយគ្រោះថ្នាក់ និងសំណល់មិនគ្រោះថ្នាក់ ឬសំណល់ធម្មតា។ សំណល់ប្រកបដោយគ្រោះថ្នាក់គឺ សំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កឱ្យមានជំងឺមហារីក ធ្វើឱ្យរលាក ធ្វើឱ្យឆេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀតដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ សំណល់ប្រកបដោយគ្រោះថ្នាក់ភាគច្រើនមានប្រភពចេញពីលំនៅដ្ឋាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្មអាជីវកម្មរ៉ែ។[77] សំណល់គ្រោះថ្នាក់ភាគច្រើនមានប្រភពពីឧស្សាហកម្មដូចជា រោងចក្រធ្វើអាគុយ រោងចក្រធ្វើសង្កសី រោងចក្រផលិតថ្នាំសំលាប់សត្វល្អិត ឧស្សាហកម្មថ្នាំពេទ្យ ឧស្សាហកម្មថ្នាំលាប ឬឧស្សាហកម្ម សហគ្រាសដែលប្រើប្រាស់សារធាតុគីមីច្រើន និងសារធាតុប្រកបដោយគ្រោះថ្នាក់ខ្ពស់។

ចំណែកឯសំណល់នៅតាមលំនៅដ្ឋាន ក៏អាចមានសារធាតុប្រកបដោយគ្រោះថ្នាក់ដែលតែមានកម្រិតតិចតួច ចំណែកវិស័យកសិកម្មវិញ ដោយសារតែបច្ចេកទេសរបស់យើងនៅមានកម្រិតទាប កសិករភាគច្រើនប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលមានសារជាតិពុលខ្លាំង និងប្រើប្រាស់ជាតិគីមីច្រើនដើម្បីបង្កើនទិន្នផលដំណាំ ដូច្នេះសារធាតុប្រកបដោយគ្រោះថ្នាក់មួយចំនួនក៏ត្រូវបានកើតឡើងតាមរយៈវិស័យនេះផងដែរ។ សំណល់រឹងជាប្រភព និងទីជម្រកនៃពពួកមេរោគឆ្លងព្រមទាំងសត្វល្អិតចង្រៃជាច្រើន។ តែយ៉ាងណាក៏ដោយសំណល់រឹងមួយចំនួនដែលមិនបង្ក គ្រោះថ្នាក់ដូចជាសំណល់ផ្ទះបាយ ក្រដាសកាតុង ក្រណាត់ កៅស៊ូ ផ្លាស្ទិកជាដើម នៅពេលដែលមិនទទួលបានការទុកដាក់បានត្រឹមត្រូវ ឬត្រូវបានបោះចោលសំណល់រាយប៉ាយ គ្រាន់អាចបង្កឱ្យមានក្លិនស្អុយ ឬកកស្ទះ ប្រព័ន្ធលូ តាមរយៈការហូរនាំដោយទឹកភ្លៀងដែលអាចធ្វើឱ្យមានការប៉ះពាល់ដល់សោភ័ណភាព និងសណ្តាប់ធ្នាប់សាធារណៈតែប៉ុណ្ណោះ។ ប៉ុន្តែចំពោះសំណល់រឹងប្រកបដោយគ្រោះថ្នាក់ដែលមានផ្ទុកនូវសារធាតុពុលវិញអាចជះឥទ្ធិពលអាក្រក់ដល់សុខភាពប្រជាជនដូចជា មានបញ្ហាខាងផ្លូវដង្ហើម ជំងឺសើស្បែក និងបណ្តាលឱ្យកើតមានជំងឺរ៉ាំរ៉ៃផ្សេងៗ។ មិនតែប៉ុណ្ណោះចំពោះអ្នករើសអេតចាយ ឬអ្នករស់នៅជុំវិញទីលានចាក់សំណល់រឹង គឺងាយនឹងរងគ្រោះថ្នាក់ដោយការមុត ឬប៉ះពាល់សំណល់ដោយផ្ទាល់ ខណៈដែលការយល់ដឹងពីបញ្ហាអនាម័យ និងសុខភាពរបស់ពួកគាត់មានកម្រិតទាប។[78]

[77] មាត្រា៣ នៃអនុក្រឹត្យ លេខ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៦

[78] គេហទំព័រ http://mekonginfo.org/assets/midocs/0002192-environment-solid-waste-managementtraining-material.pdf ដកស្រង់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២

- **ការបំពុលដោយសំណល់រាវ**

សំណល់រាវ គឺសំដៅដល់ទឹកសំណល់មានផ្ទុកនូវសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។[79] សំណល់រាវដែលត្រូវបានបញ្ចេញពីគ្រប់ប្រភពដូចជា លំនៅដ្ឋាន ឧស្សាហកម្ម មន្ទីរពេទ្យ ឬអាចជាសំណល់សល់ពីការធ្វើពាណិជ្ជកម្ម គឺសុទ្ធតែជាហេតុបង្កឱ្យមាន ការបំពុលដល់បរិស្ថាន។ សំណល់រាវអាចមានដូចជា សំណល់ពីការបន្ទោរបង់ ការបោកខោអាវ ការលាងបន្លែ ផ្លែឈើ ត្រីសាច់ សំណល់រាវចេញពីរោងចក្រ សំណល់ដែលសល់ពីឧស្សាហកម្មគីមីមាន ឧស្សាហកម្មប្រេង ឧស្សាហកម្មតម្បាញ ឧស្សាហកម្មលោហធាតុ និងសំណល់វេជ្ជសាស្ត្រដូចជា ឈាម ទឹករំអិលជាដើម។ ដូចនេះ ប្រសិនបើមិនមានការគ្រប់គ្រងឱ្យបានល្អទេនោះធ្វើឱ្យមានការបំពុលក៏ដូចជាផលប៉ះពាល់ជាច្រើនអាចកើតមាន ឡើងចំពោះសោភ័ណភាព បរិស្ថាន សុខភាពមនុស្ស សត្វ និងរុក្ខជាតិ។ សំណល់រាវដែលមានសារធាតុគីមីធ្វើឱ្យ ប៉ះពាល់ដល់សោភ័ណភាព បង្កឱ្យប្រភពទឹកសាធារណៈមានក្លិនមិនល្អ។ល។ សារធាតុគីមីពុលប្រកបភាព គ្រោះថ្នាក់ដូចជា ផូស្វ័រ ស៊ីលីស្យូម អាម៉ូញ៉ាក់ នីទ្រីត អាចធ្វើឱ្យដី និងទឹកខូចគុណភាពព្រមទាំងបង្កគ្រោះថ្នាក់ ដល់សុខភាពមនុស្ស សត្វ និងជីវៈចម្រុះ។[80] ចំពោះមនុស្សអាចបង្កភាពប៉ះពាល់ខ្លាំង ជាពិសេសទៅលើបញ្ហា សុខភាពដូចជា ជំងឺគ្រុនពោះវៀន គ្រុនចាញ់ និងរាគរូសជាដើម។ មនុស្សអាចឆ្លងជំងឺតាមរយៈការបរិភោគ ប្រើប្រាស់ទឹកដែលមានសារធាតុពុល ឬអាចមកពីភ្នាក់ងារចម្លងដូចជា សត្វរុយ សត្វជ្រូក ឆ្មា និងសត្វពាហនៈ ដែលដើរលុកលុយក្នុងគំនរសំរាម។ ដូចនេះចំពោះបញ្ហាបំពុលដោយសំរាម ឬកាកសំណល់មិនថារឹង ឬរាវ សុទ្ធតែបង្កឱ្យមានភាពមហន្តរាយដល់ជីវិតមនុស្ស សត្វ រុក្ខជាតិ និងជីវៈចម្រុះ មិនតែប៉ុណ្ណោះធ្វើឱ្យបរិស្ថាន និងសោភ័ណភាពមិនមានភាពស្រស់បំព្រងទៀត។

- **ការគ្រប់គ្រងសំណល់រឹង រាវ**
  - ណែនាំទៅដល់ប្រជាជនឱ្យមានការយល់ដឹងអំពីការបែងចែកសំណល់ទៅតាមប្រភេទដូចជា ត្រូវវេច ខ្ចប់ទុកដាក់សំរាម សំណល់រឹង ដែលអាចបង្កគ្រោះថ្នាក់ដូចជា អំបែងកែវ អំបែងដប និងវត្ថុដែលបង្ក គ្រោះថ្នាក់ផ្សេងទៀតចូលទៅក្នុងថង់ពណ៌ក្រហម ឬធ្វើជាសញ្ញាសម្គាល់ដើម្បីបញ្ជាក់ប្រាប់កម្មករ ប្រមូលសំរាមឱ្យមានការប្រុងប្រយ័ត្ន។[81]

---

[79] មាត្រា៤ នៃអនុក្រឹត្យ លេខ២៣៨ អនក្រ.បក ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកង្វក់ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧

[80] ការវាយតម្លៃបឋមលេខយោង ០០០០១៨/system no.36 ប្រកាសស្តីពីការគ្រប់គ្រងសំណល់រាវដែលមានសារធាតុគីមីពុល កាល បរិច្ឆេទថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣

[81] សេចក្តីណែនាំ លេខ០០៩/១៩ សណន.ស ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាមឱ្យ បានត្រឹមត្រូវតាមកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម

- ការញែកសំណល់មាន២គឺ ការញែកសំណល់នៅតាមលំនៅដ្ឋាន និងការញែកសំណល់នៅតាមទីសាធារណៈដូចជា រោងចក្រ សហគ្រាស និងអគារពាណិជ្ជកម្ម។ ការញែកសំណល់នៅតាមលំនៅដ្ឋានរួមមាន៖ សំណល់ទាំងឡាយដែលប្រកបដោយគ្រោះថ្នាក់ (ថ្មពិលអាគុយ កំប៉ុងថ្នាំសម្លាប់សត្វ និងកំប៉ុងដែលមានសារធាតុគីមី។ល។) និងការញែកសំណល់សម្រាប់ កែច្នៃ (ក្រដាសអំបែង ដប ឬកែវ និងសារធាតុប្លាស្ទិក)។ ចំពោះការបែងចែកសំណល់នៅតាមទីសាធារណៈដូចជា រោងចក្រ សហគ្រាស និងអគារពាណិជ្ជកម្មមានលក្ខណៈស្មុគស្មាញជាងតាមលំនៅដ្ឋាន។ ដូចនេះ គេក៏បានប្រើប្រាស់ធុងទៅតាមប្រភេទ និងទៅតាមពណ៌ដើម្បីជាភាពងាយស្រួលក្នុងការប្រមូលដឹកជញ្ជូន និងគ្រប់គ្រង។
- ការប្រើប្រាស់ធុងសំរាមទៅតាមពណ៌ និងប្រភេទនៅតាមទីសាធារណៈដូចជា៖ សំណល់ផ្ទះបាយ (តំណាងឱ្យធុងពណ៌បៃតង) សំណល់ប្លាស្ទិក (តំណាងឱ្យធុងពណ៌លឿង) និងសំណល់ គ្រោះថ្នាក់ (តំណាងឱ្យធុងពណ៌ក្រហម)។ ក្រៅពីដាក់ពណ៌ធុងហើយ ក្រសួងបានបន្ថែមLogo ឬរូបដើម្បីបង្កជាភាពងាយស្រួលដល់ប្រជាជនក្នុងការបោះសំរាម។

ជាក់ស្តែងរដ្ឋបាលក្រុងបាត់ដំបងបានចុះកិច្ចសន្យាថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការធ្វើសេវាអនាម័យ សម្អាត ប្រមូលដឹកជញ្ជូន និងកែច្នៃសំរាម សំណល់រឹងទីប្រជុំជនដែលនៅក្នុងក្រុងបាត់ដំបងជាមួយក្រុមហ៊ុនស៊ីន ទ្រី (ខេម បូឌា) ចំកាត់ ប៉ុន្តែនៅតែមិនអាចដោះស្រាយស្ថានភាពនៃការស្ទះសំរាម និងការប្រមូលសំរាមមិនអាចទាន់ពេលវេលាបាននៅឡើយ ដោយសារខ្វះនូវរថយន្ត កម្មករ និងផ្លូវចូលទីលានចាក់សំរាម។ ដូចនេះរដ្ឋបាលក្រុងបានចេញសេចក្តីណែនាំយោងតាមកិច្ចសន្យានេះដែលមានដូចតទៅ៖

- ត្រូវបន្ថែមរថយន្ត (ចំណុះ១០តោន) ចំនួន១០គ្រឿង
- ត្រូវបន្ថែមកម្មករ២០នាក់
- ត្រូវកែលម្អផ្លូវចូលទីលានចាក់សំរាមឱ្យបានល្អប្រសើរ។

ក្នុងករណីក្រុមហ៊ុនពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាកម្មប្រមូលដឹកជញ្ជូនសំរាមឱ្យបានទាន់ពេលវេលាបន្តទៀតដែលនឹងធ្វើឱ្យមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងសោភ័ណភាពក្រុងផ្ទាល់ ជាពិសេសការសាយភាយនូវក្លិនមិនល្អនឹងមានផលរំខានដល់សុខភាពប្រជាពលរដ្ឋ មិនតែប៉ុណ្ណោះមានការប៉ះពាល់យ៉ាងខ្លាំងដល់ការអភិវឌ្ឍនៅក្នុងក្រុងផងដែរ។ រដ្ឋបាលក្រុងបានបន្តទៀតថានឹងសហការជាមួយមន្ទីរអង្គភាពជំនាញពិនិត្យ និងបញ្ចប់កិច្ចសន្យាតាមការកំណត់។[82]

[82] សេចក្តីណែនាំ ស្តីពីការអនុវត្តកាតព្វកិច្ច និងពង្រឹងប្រសិទ្ធិភាពក្នុងការប្រមូលដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន នៅក្នុងសង្កាត់ទាំង០៨ នៃក្រុងបាត់ដំបង ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២

➢ **ដំណោះស្រាយ**

- ការបោះចោលសំរាមទៅតាមការវេចខ្ចប់ និងទុកដាក់ក្នុងធុងទៅតាមប្រភេទឱ្យបានត្រឹមត្រូវ
- ការកែច្នៃឡើងវិញនូវសារធាតុដែលអាចកែច្នៃបាន កែច្នៃនូវសំណល់ផ្ទះបាយ ឬសំណល់សរីរាង្គ ដោយបំលែងជាជីកំប៉ុស
- ចំពោះសំណល់វេជ្ជសាស្ត្រ ឬសំណល់ប្រកបគ្រោះថ្នាក់មួយចំនួន យកទៅដុតតាមបច្ចេកវិទ្យាដុតសំណល់
- កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកជំនួសវិញដោយការប្រើប្រាស់ស្លឹកឈូក ឬថង់ក្រដាសវិញ
- លើកទឹកចិត្តដល់ប្រជាជនក្នុងការប្រើប្រាស់នូវសម្ភារៈទាំងឡាយដែលបានកែច្នៃឡើងវិញជាពិសេស ជំរុញឱ្យមានការផលិតនូវសម្ភារៈដែលមិនប៉ះពាល់ដល់បរិស្ថាន
- បង្រៀនប្រជាជនឱ្យយល់ដឹងអំពីការសំអាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសំអាត
- ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន
- អប់រំ និងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងនៅតាមទីប្រជុំជន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសំអាតប្រមូល ដឹកជញ្ជូន សេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់នានា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។[83]

### ២.២.៥. ការបំពុលដោយសំឡេង

ការបំពុលដោយសំឡេង ឬសំឡេង រំខានខ្លាំងៗដែលជះឥទ្ធិពលដល់បទដ្ឋាន នៃទីកន្លែងជាក់លាក់មួយ។ បើទោះបីសំឡេងរំខានមិនសូវបង្កជាផលប៉ះពាល់ ដូចការបំពុលផ្សេងៗក៏ដោយ ប៉ុន្តែពិតទៅវាអាចបង្កអន្តរាយដល់អាយុជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់គ្នា។ ការបំពុលសំឡេងបានផ្តល់ផលប៉ះពាល់ទាំងសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់មនុស្សដូចជា អាចបណ្តាលឱ្យមានការថប់អារម្មណ៍ តានតឹង ដែលអាចបង្កឱ្យជាជំងឺផ្លូវចិត្តធ្ងន់ធ្ងរ បង្កឱ្យមានបញ្ហាបេះដូង អាចគាំង ឬដាច់សរសៃឈាមបេះដូង លើសសម្ពាធឈាម បំផ្លាញការចងចាំ ជាពិសេសគឺបញ្ហាហឹងត្រចៀក ដែលអាចធ្វើឱ្យបាត់បង់នូវលទ្ធភាពនៃការស្តាប់។ **ការបំពុលដោយប្រភពចល័ត** សំដៅលើប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ ពោលគឺមិនឈប់ស្ងៀមនៅមួយកន្លែង ឬជាការបំពុលនោះអាចចេញពីយន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំឡេងគ្រប់ប្រភេទ។

[83] អនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន

**ការបំពុលដោយប្រភពអចល័ត** សំដៅលើប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាក់លាក់ដែលការបំពុលនោះអាចចេញពីរោងចក្រ សហគ្រាស ឃ្លាំងស្តុកសម្ភារៈការដ្ឋានសំណង់ ឡដុតសំរាម សិប្បកម្ម គ្រឿងបំពងសំឡេងចេញពីកន្លែងកំសាន្ត ឬក្លឹបកំសាន្ត និងកសិដ្ឋានគ្រប់ប្រភេទ។

➢ **ដំណោះស្រាយ**

- ជៀសវាងការប្រើប្រាស់នូវសំឡេងដែលមិនចាំបាច់មិនថាទាំងនៅក្នុងផ្ទះ ឬនៅកន្លែងធ្វើការជាដើម អ្នកជិតខាងត្រូវគោរពម៉ោងសម្រាកឱ្យគ្នាទៅវិញទៅមក ជាពិសេសប្រសិនបើពួកគេរស់នៅក្នុងអគារ ឬប្លុក និងជៀសវាងការស្តាប់តន្ត្រី និងទូរទស្សន៍ក្នុងកម្រិតសំឡេងខ្ពស់ ព្រោះវាអាចធ្វើឱ្យខូចត្រចៀករបស់សមាជិកគ្រួសារ។
- មិនបំពងសំឡេងលឺៗដូចជា ប្រើប្រាស់កាំជ្រួច ផាវ និងឧបករណ៍ផ្សេងៗដែលខុសពីច្បាប់កំណត់ មិនឱ្យមានការប្រើប្រាស់ខុសពេលខុសវេលា។[84]
- កម្រិតនៃការកំណត់ស្តង់ដារនៃការបញ្ចេញសំឡេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំណត់សំឡេងអតិបរិមាសម្រាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន។
- ហាមឃាត់ដាច់ខាតនូវការបង្កឱ្យមានជាសំឡេង ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដាដាក់វិធានការច្បាប់ចំពោះជនណាដែលប្រព្រឹត្តល្មើសទៅនឹងបញ្ញាត្តិច្បាប់ប្រទេសកម្ពុជា។[85]

[84] គេហទំព័រ https://km.warbletoncouncil.org/tipos-contamination-acustica-16274 ដកស្រង់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២

[85] មាត្រា៣ មាត្រា៧ និងមាត្រា៩ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើអត្ថបទនេះរួចមកហើយ យើងបានយល់ឃើញថាការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពក្រុង គឺជាផ្នែកមួយដែលមានចាំបាច់បំផុតក្នុងការជំរុញ និងសម្រេចបាននូវទិសដៅនៃភាពជោគជ័យ ដើម្បីផ្លាស់ប្ដូរនូវទីក្រុងមួយឱ្យក្លាយជាទីក្រុងដែលមានលក្ខណៈស្ដង់ដា។ យ៉ាងណាមិញយើងបានសង្កេតឃើញថា សកម្មភាពរបស់ក្រុងបាត់ដំបងដំណើរការបានយ៉ាងល្អ ដោយសកម្មភាពមួយនោះមានការសហការជាមួយប្រជាពលរដ្ឋ និងមន្ត្រីគ្រប់ជាន់ថ្នាក់ ដើម្បីដំណើរការកសាងអភិវឌ្ឍនៅក្នុងក្រុងមួយនេះផងដែរ។ ទោះបីជាក្រុងបានរៀបចំ ធ្វើការអភិវឌ្ឍបានយ៉ាងច្រើនស្ទើរគ្រប់វិស័យក៏ពិតមែនក៏ប៉ុន្តែយើងឃើញថា ការអភិវឌ្ឍរបស់ក្រុងនៅតែមិនទាន់ទទួលបានលទ្ធផលដូចនឹងការរំពឹងទុករបស់ផែនការអភិវឌ្ឍរបស់ក្រុងនៅឡើយ។ ជាក់ស្ដែងបញ្ហាសណ្ដាប់ធ្នាប់ និងសោភ័ណភាព គឺជាបញ្ហាចម្បងមួយ ដែលក្រុងកំពុងតែយកចិត្តទុកដាក់នៅក្នុងកែប្រែ និងរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែម ព្រមទាំងយកចិត្តទុកដាក់ទៅលើការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពដើម្បីឱ្យក្រុងមានការអភិវឌ្ឍជឿនលឿនជាងនេះទៅទៀត។ លើសពីនេះយើងក៏បានដឹងហើយថានៅក្នុងក្រុងនៅតែមានការជួបប្រទះទៅលើបញ្ហាប្រព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធបង្ហូរលូទឹកស្អុយមិនទាន់មានភាពត្រឹមត្រូវ ដែលវាបង្កមកពីការកកស្ទះសំរាម ការកសាង ឬជួសជុលប្រព័ន្ធផ្លូវថ្នល់មិនទាន់ត្រឹមត្រូវទៅតាមស្តង់ដានៅឡើយដែលជាហេតុនាំឱ្យខូចខាតលិចលង់ ជាពិសេសទៅទៀតនោះនៅមានភាពខ្វះខាតទៅលើការៀបចំប្រព័ន្ធលូនៅតាមស្រុកនីមួយៗជូនប្រជាពលរដ្ឋនៅឡើយ ដែលជាហេតុនាំឱ្យមានការលំបាកដល់ប្រជាពលរដ្ឋនៅក្នុងការរស់នៅ និងប្រកបអាជីវកម្មផងដែរ។

ក្រៅពីការស្វែងយល់ទៅលើហេដ្ឋារចនាសម្ព័ន្ធ និងបញ្ហាបរិស្ថាននៅក្នុងតំបន់ក៏ជាកត្តាសំខាន់ដែលសម្រាប់ក្នុងការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពឱ្យកាន់តែមានប្រសិទ្ធិភាព គុណភាពសម្រាប់ការរស់នៅរបស់ប្រជាជននៅក្នុងតំបន់ទាំងមូល។ ដូចនេះហើយទើបរដ្ឋបាលក្រុងបន្ថែមការយកចិត្តទុកដាក់ទៅលើបញ្ហាដែលអាចបណ្ដាលឱ្យមានការបំពុលដល់បរិស្ថានដូចជា បញ្ហាបំពុលទឹក បញ្ហាបំពុលដី បញ្ហាបំពុលខ្យល់ បញ្ហាបំពុលដោយសំណល់រឹង-រាវ និងបញ្ហាបំពុលដោយសំឡេងផងដែរ។ បញ្ហាទាំងនោះសុទ្ធសឹងតែជាបញ្ហាដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន សុខុមាលភាពរបស់ប្រជាជន ជាពិសេសសោភ័ណភាពនៅក្នុងក្រុងអាចមានការធ្លាក់ចុះ ប្រសិនបើមិនមានការដោះស្រាយឱ្យបានឆាប់រហ័សបំផុតទេនោះ។

យ៉ាងណាមិញ នៅក្នុងការសិក្សា និងស្រាវជ្រាវទៅលើប្រធានបទសារណា "ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពក្នុងក្រុងបាត់ដំបង" បានធ្វើឱ្យមានការយល់កាន់តែច្បាស់លាស់អំពីបុព្វហេតុដែលនាំឱ្យមានការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពរបស់ក្រុងបាត់ដំបង ព្រមទាំងបានយល់ដឹងពីសារៈសំខាន់ផ្សេងៗនៃការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពផងដែរ។ ការរៀបចំនោះមិនត្រឹមតែធ្វើឱ្យក្រុងមានរបៀបរៀបរយ

និងមានសោភ័ណភាពស្រស់ស្អាតប៉ុណ្ណោះទេគឺថែមទាំងធ្វើឱ្យក្រុងកាន់តែមានភាពទាក់ទាញមួយកម្រិតទៀត។ លើសពីនេះទៅទៀត ការរៀបចំនូវសណ្តាប់ធ្នាប់បានធ្វើឱ្យក្រុងទាំងមូលមានការអភិវឌ្ឍស្មើរគ្រប់វិស័យទាំងអស់នៅក្នុងក្រុង ព្រមទាំងផ្តល់នូវទំនុកចិត្តដល់ប្រជាពលរដ្ឋឱ្យរស់នៅប្រកបដោយភាពសុខដុមរមនា ទាំងផ្លូវកាយ និងផ្លូវចិត្តពោរពេញទៅដោយភាពស៊ីវិល័យ និងទាន់សម័យទៅតាមសម័យកាលនាពេលបច្ចុប្បន្ន។

# អនុសាសន៍

# អនុសាសន៍

ដោយយោងតាមការសិក្សាស្រាវជ្រាវ និងពិនិត្យមើលតាមស្ថានភាពជាក់ស្តែងនៅក្នុងក្រុងបាត់ដំបង គឺសង្កេតឃើញថាមានការអភិវឌ្ឍ និងរីកចម្រើនដែលយើងនឹងអាចកត់សម្គាល់រួមមានៈ ការអភិវឌ្ឍលំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងវិស័យសំខាន់ៗជាច្រើនដែលមិនធ្លាប់មានពីមុនមក។ ទោះជាយ៉ាងណាក្តីក៏នៅមានបញ្ហាមួយចំនួនទៀតដែលអាជ្ញាធរក្រុងបាននឹងកំពុងអនុវត្ត ប៉ុន្តែហាក់បីដូចជាពុំសូវទទួលបានប្រសិទ្ធភាព និងទទួលបានផលល្អប្រសើរនៅឡើយក្នុងការទប់ស្កាត់នៅបញ្ហាដែលកើតឡើងមានជាយូរហើយនោះ។ ដើម្បីចូលរួមដោះស្រាយបញ្ហាខាងក្រោម នាងខ្ញុំសូមសេចក្តីអនុញ្ញាតបញ្ចេញមតិដូចតទៅៈ

- ជួយរកវិធីសាស្ត្រដោះស្រាយធ្វើយ៉ាងណាឱ្យយកជនអនាថា និងបញ្ហាសតិ (វិកលចរិក) រកកន្លែងមួយសម្រាប់ពួកគាត់រស់នៅដើម្បីរៀបចំទីសាធារណៈឱ្យបានល្អប្រសើរ ព្រោះកន្លងមកធ្លាប់យកពួកគាត់ទៅដាក់នៅតាមវត្តដែរ ប៉ុន្តែពួកគាត់តែងតែបំផ្លាញរបស់របរទ្រព្យសម្បត្តិផ្សេងៗ ដើរតាមទីសាធារណៈមានទាំងដើរសុំលុយ ដើរអាក្រាតកាយ ដើរស្រែកដែលនាំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ទីក្រុង និងអារម្មណ៍ភ្ញៀវទេសចរទៀតផង
- បញ្ហាសន្តិសុខ អំពើចោរកម្ម ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន ស្នើសុំឱ្យអាជ្ញាធរពាក់ព័ន្ធក្នុងក្រុងបាត់ដំបងមេត្តាពង្រឹងច្បាប់ និងផ្សព្វផ្សាយ ព្រមទាំងអនុវត្តនូវគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពឱ្យបានតឹងរឹងជាទីបំផុត ដើម្បីធានាដល់សុខសុវត្ថិភាពជូនប្រជាពលរដ្ឋ
- ស្នើសុំអាជ្ញាធរពាក់ព័ន្ធចុះផ្សព្វផ្សាយជូនប្រជាពលរដ្ឋអំពីការវេចខ្ចប់ទុកដាក់សំណល់រឹងរាវ និងរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវ ដើម្បីចៀសវាងការភាយក្លិនមិនល្អ និងកកស្ទះប្រព័ន្ធលូ
- ស្នើសុំឱ្យអាជ្ញាធរធ្វើការកែសម្រួលទៅលើបញ្ហាការរំលោភលើចិញ្ចើមថ្នល់ ដីចំណីផ្លូវ ជាពិសេសការលក់ដូរគ្មានសណ្តាប់ធ្នាប់តាមដងផ្លូវ អសន្តិសុខ និងភាពអនាធិបតេយ្យដែលអាចធ្វើឱ្យមានការប៉ះពាល់ទៅលើសោភ័ណភាព
- ស្នើសុំឱ្យអាជ្ញារធរមានការយកចិត្តទុកដាក់ទៅលើបញ្ហាបរិស្ថាននៅក្នុងក្រុងដូចជា បញ្ហាការគ្រប់គ្រងកាកសំណល់ ការប្រមូល ការដឹកជញ្ជូន និងការស្តុកសំរាមទុក
- ស្នើសុំឱ្យអាជ្ញាធរដែលពាក់ព័ន្ធបម្រើសេវាការងារជូនប្រជាពលរដ្ឋដោយភាពសប្បាយរីករាយ ស្មោះត្រង់ មិនគិតពីប្រយោជន៍ពីប្រជាពលរដ្ឋ
- ស្នើទៅដល់ប្រជាពលរដ្ឋរស់នៅក្នុងសង្កាត់ទាំងអស់ចូលរួម ថែរក្សា ការពារ យកចិត្តទុកដាក់ និងបើកចិត្តទទួលយកការអប់រំពីថ្នាក់ដឹកនាំនៅក្នុងក្រុងនិងគោរពទៅតាមសេចក្តីប្រកាស ការណែនាំ ព្រមទាំងអនុវត្តឱ្យបានខ្ជាប់ខ្ជួន។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុក្រឹត្យលេខ១៨២អនក្រ.បក បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- អនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង
- អនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកង្វក់
- អនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការគ្រប់គ្រងសំណល់រឹង
- អនុក្រឹត្យលេខ១១៣ អនក្រ.បន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន
- អនុក្រឹត្យលេខ១៨២អនក្រ.បក ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- ប្រកាសស្តីពីការគ្រប់គ្រងសំណល់រាវដែលមានសារធាតុគីមីពុល
- ប្រកាសលេខ៣៤៨ ស្តីពីតួនាទីភារកិច្ច របៀបរបបការងារ របស់ក្រសួងមហាផ្ទៃ
- សេចក្តីសម្រេចលេខ២២សសរ ស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលក្រុងបាត់ដំបង
- សេចក្តីជូនដំណឹង ស្តីពីការកែលម្អ និងការរៀបចំសណ្តាប់ធ្នាប់ សោភ័ណភាពនៅក្នុងតំបន់អគារអភិរក្សក្រុងបាត់ដំបង
- សេចក្តីជូនដំណឹង ស្តីពីការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈតាមបណ្តោយផ្លូវលេខ២ ចាប់ពីវត្តដំរីសរហូតដល់ផ្លូវជាតិលេខ៥
- របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងបាត់ដំបងប្រចាំឆ្នាំ២០២១
- សេចក្តីណែនាំលេខ០០៩/១៩ សណន.ស ស្តីពីការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាមឱ្យបានត្រឹមត្រូវតាមកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម

- សេចក្តីណែនាំស្តីពីការអនុវត្តកាតព្វកិច្ច និងពង្រឹងប្រសិទ្ធិភាពក្នុងការប្រមូលដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន នៅក្នុងសង្កាត់ទាំង០៨ នៃក្រុងបាត់ដំបង ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២

## ២. សៀវភៅ

- សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) ក្រុងបាត់ដំបង ខេត្តបាត់ដំបង
- តារាងសូចនាករតាមឃុំ-សង្កាត់ក្នុងក្រុងបាត់ដំបង ឆ្នាំ២០២១
- សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ (២០១៩-២០២០)
- សៀវភៅផែនការអភិវឌ្ឍក្រុង៥ឆ្នាំ ក្រុងបាត់ដំបង (២០២០-២០២៤)

## ៣. គេហទំព័រ

- គេហទំព័រ https://www.pdibattambang.info/plant-flowers/
- គេហទំព័រ https://sbm.news/articles/622757d2e0e4eed3032078e3
- គេហទំព័រ https://km.warbletoncouncil.org/causas-consecuencias-contaminacion-agua-11450#menu-3
- គេហទំព័រhttps://km.warbletoncouncil.org/contaminaction-del-suelo-3188
- គេហទំព័រ http://moinews.gov.kh/news/1408
- គេហទំព័រ https://km.eferrit.com/និយមន័យននការបំពុលខ្យល់/
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/pollution-and-waste/
- គេហទំព័រhttp://mekonginfo.org/assets/midocs/0002192-environment-solid-waste-managementtraining-material.pdf
- គេហទំព័រ https//www.cpp.org.kh/details/23808
- គេហទំព័រ https://km.warbletoncouncil.org/tipos-contamination-acustica-16274
- គេហទំព័រ http://phumsas.blogspot.com/2020/05/blog-post_23.html
- គេហទំព័រ http://www.interior.gov.kh/news/detail/2225
- គេហទំព័រ https://www.rasmeinews.com/archives/405553
- គេហទំព័រ http://www.cvea.org.kh/en / real-estate-news-2/1973-2018-05-24-07-05-09.html
- គេហទំព័រ https://vymaps.com/KH/522423511260314/
- គេហទំព័រ https://fb.watch/ejCP7Ujq9u/

- គេហទំព័រ https://www.realestate.com.kh/km/boreys/borey-reaksmey-battambang/
- គេហទំព័រ https://vymaps.com/KH/-170207/
- គេហទំព័រ https://www.postkhmer.com/national/2022-02-27-1830-232441.html
- គេហទំព័រ https://www.battambang.gov.kh/detail/11246
- គេហទំព័រ https://www.pdibattambang.info/mall-in-city/
- គេហទំព័រ https://www.popular.com.kh/social/356941.html/
- គេហទំព័រ http://moinews.gov.kh/news/1408
- គេហទំព័រhttps://www.khmertimeskh.com//501113540/ខតតបតដបងនងរបច
- គេហទំព័រ http://www.cambodiapropertyreport.com/article/6504
- គេហទំព័រhttps://construction-property.com/km/study-complete-for-new-72-kilometer-road-connecting-battambang-siem-reap/
- គេហទំព័រ http://www.cambodiapropertyreport.com/article/6504

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធរូបភាព

- ឧបសម្ព័ន្ធទី១៖ ផែនទីក្រុងបាត់ដំបង
- ឧបសម្ព័ន្ធទី២៖ ទិដ្ឋភាពទូទៅក្រុងបាត់ដំបង
- ឧបសម្ព័ន្ធទី៣៖ សំណង់អគារក្នុងក្រុងបាត់ដំបង
- ឧបសម្ព័ន្ធទី៤៖ រោងចក្រផលិតទឹកស្អាត វត្តលៀប
- ឧបសម្ព័ន្ធទី៥៖ ការបំពាក់ភ្លើងចម្រុះពណ៌តាមសួនច្បារ
- ឧបសម្ព័ន្ធទី៦៖ សោភ័ណភាពទីកន្លែងសាធារណៈ
- ឧបសម្ព័ន្ធទី៧៖ សំណង់បេតិកភណ្ឌមិនទាន់រុះរើស្លាកឃីហោ
- ឧបសម្ព័ន្ធទី៨៖ អភិបាលខេត្តចុះពិនិត្យ និងណែនាំទៅប្រជាពលរដ្ឋម្ចាស់លំនៅឋាន សំណង់បេតិកភណ្ឌ
- ឧបសម្ព័ន្ធទី៩៖ ស្ពានថ្មថ្មី ស្ពាន ១៣មករា ដែលសាងសង់ទន្ទឹមគ្នានឹងស្ពានបុរាណអាយុកាលជាង ១០០ ឆ្នាំ នៅក្រុងបាត់ដំបងបានបញ្ចប់ការសាងសង់ជាស្ថាពរ
- ឧបសម្ព័ន្ធទី១០៖ ពានរង្វាន់ផ្ការំដួល៣ទង (២០១៥-២០១៨) និង(២០១៨-២០២១) និង ពានរង្វាន់ទីក្រុងស្អាតអាស៊ាន (២០១៨-២០២០)
- ឧបសម្ព័ន្ធទី១១៖ អភិបាលខេត្ត អភិបាលក្រុងបាត់ដំបង អញ្ជើញចុះពិនិត្យមើលស្ថានភាពសណ្តាប់ធ្នាប់ក្រុងបាត់ដំបង
- ឧបសម្ព័ន្ធទី១២៖ អភិបាលក្រុង បាត់ដំបង និង ក្រុមការងារបានចុះពិនិត្យមើលការដាក់លូ និងរៀបចំចាក់ផ្លូវបេតុងចន្លោះផ្លូវជាតិលេខ៥ ទៅទល់នឹងផ្លូវលេខ១០១ នៅភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
- ឧបសម្ព័ន្ធទី១៣៖ ប្រារព្ធទិវាអនាម័យបរិស្ថានជាតិ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ នៅសួននាគសន្តិភាព ក្រុងបាត់ដំបងស្ថិតក្រោមប្រធានបទភូមិឋានស្អាត សុខភាពល្អ ជីវិតរីករាយ
- ឧបសម្ព័ន្ធទី១៤៖ សកម្មភាពកម្លាំងក្រុមអន្តរាគមន៍ បង្ការ បង្ក្រាប នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង
- ឧបសម្ព័ន្ធទី១៥៖ បញ្ហាសំរាមនៅលើមុខផ្ទះប្រជាពលរដ្ឋ
- ឧបសម្ព័ន្ធទី១៦៖ បញ្ហាចិញ្ចើមផ្លូវ

- ឧបសម្ព័ន្ធទី១៧៖ ការចតយានយន្តគ្មានសណ្តាប់ធ្នាប់
- ឧបសម្ព័ន្ធទី១៨៖ ភ្លៀងធ្លាក់មួយមេធំធ្វើឱ្យលិចផ្លូវខ្លះក្នុងក្រុងបាត់ដំបង

## ២. ឧបសម្ព័ន្ធគតិយុត្ត

- ឧបសម្ព័ន្ធទី១៖ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពីវិសោធកម្មមាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- ឧបសម្ព័ន្ធទី៤៖ អនុក្រឹត្យ លេខ២៣៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកង្វក់
- ឧបសម្ព័ន្ធទី៥៖ អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង
- ឧបសម្ព័ន្ធទី៦៖ អនុក្រឹត្យ លេខ១១៣ អនក្រ.បន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន
- ឧបសម្ព័ន្ធទី៧៖ អនុក្រឹត្យ លេខ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការគ្រប់គ្រងសំណល់រឹង
- ឧបសម្ព័ន្ធទី៨៖ អនុក្រឹត្យ លេខ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក

# ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** ផែនទីក្រុងបាត់ដំបង



# ឧបសម្ព័ន្ធទី២៖ ទិដ្ឋភាពទូទៅក្រុងបាត់ដំបង



រង្វង់មូលលោកតាដំបងក្រញូង



ទេសភាពដើមឈើនៅតាមដងផ្លូវ



វត្តកណ្ដាលនៅក្នុងក្រុងបាត់ដំបង

# ឧបសម្ព័ន្ធទី៣៖ សំណង់អគារក្នុងក្រុងបាត់ដំបង



សំណង់អគារនៅតាមដងស្ទឹងសង្កែ



សាលាខេត្តបាត់ដំបង



ផ្ទះប្រជាពលរដ្ឋ

# ឧបសម្ព័ន្ធទី៤៖ រោងចក្រផលិតទឹកស្អាត វត្តលៀប






# ឧបសម្ព័ន្ធទី៥៖ ការបំពាក់ភ្លើងចម្រុះពណ៌តាមសួនច្បារ












## ឧបសម្ព័ន្ធទី៦៖ សោភ័ណភាពទីកន្លែងសាធារណៈ




ការដាក់បង្គោល វ៉ាយ ហ្វាយនេះនៅសួនច្បារសម្តេចក្រឡាហោម ស ខេង  ដើម្បីឱ្យប្រើប្រាស់ វ៉ាយហ្វាយ ដោយឥតគិតថ្លៃ, ជួយបំភ្លឺ និងសោភ័ណសាធារណៈព្រមទាំងអាចបំពាក់សារអប់រំផងដែរ






សកម្មភាពតំឡើងភ្លើងសញ្ញាចរាចរណ៍ក្នុងក្រុងបាត់ដំបង

# ឧបសម្ព័ន្ធទី៧៖ សំណង់បេតិកភណ្ឌមិនទាន់រុះរើស្លាកយីហោ








# ឧបសម្ព័ន្ធទី៨៖ អភិបាលខេត្តចុះពិនិត្យ និងណែនាំទៅប្រជាពលរដ្ឋម្ចាស់លំនៅឋាន សំណង់បេតិកភណ្ឌ






## ឧបសម្ព័ន្ធទី៩៖ ស្ពានថ្មថ្មី ស្ពាន ១៣មករា ដែលសាងសង់ទន្ទឹមគ្នានឹងស្ពានបុរាណអាយុកាលជាង ១០០ ឆ្នាំ នៅក្រុងបាត់ដំបងបញ្ចប់ការសាងសង់ជាស្ថាពរ









## ឧបសម្ព័ន្ធទី១០៖ ពានរង្វាន់ផ្ការំដួល៣ទង (២០១៥-២០១៨) និង(២០១៨-២០២១) និង ពានរង្វាន់ទីក្រុងស្អាតអាស៊ាន (២០១៨-២០២០)







អភិបាលខេត្តបាត់ដំបង ឯកឧត្តម សុខ លូ មកទទួលពានរង្វាន់ទីក្រុងស្អាតអាស៊ាន
(២០២២-២០២៤)

## ឧបសម្ព័ន្ធទី១១៖ អភិបាលខេត្ត អភិបាលក្រុងបាត់ដំបង អញ្ជើញចុះពិនិត្យមើលស្ថានភាពសណ្ដាប់ធ្នាប់ក្រុងបាត់ដំបង



អភិបាលខេត្ត អភិបាលក្រុងបាត់ដំបង អញ្ជើញចុះពិនិត្យមើលស្ថានភាពសណ្ដាប់ធ្នាប់ជុំវិញផ្សារណាត់ ក្នុងក្រុងបាត់ដំបង




អភិបាលខេត្តបាត់ដំបង ចុះអន្តរាគមន៍រំដោះទឹកភ្លៀង ដែលជន់លិចផ្លូវមួយចំនួនចេញពីក្រុងបាត់ដំបង នៅប៉ែកខាងលិចស្ទឹងសង្កែ

ឧបសម្ព័ន្ធទី១២៖ អភិបាលក្រុង បាត់ដំបង និង ក្រុមការងារបានចុះពិនិត្យមើលការដាក់លូ និងរៀបចំចាក់ផ្លូវ បេតុងចន្លោះផ្លូវជាតិលេខ៥ ទៅទល់នឹងផ្លូវលេខ១០១ នៅភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង





**ឧបសម្ព័ន្ធទី១៣៖ ប្រារព្ធទិវាអនាម័យបរិស្ថានជាតិ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ នៅសួនមាគសន្តិភាព ក្រុងបាត់ដំបង ស្ថិតក្រោមប្រធានបទ ភូមិឋានស្អាត សុខភាពល្អ ជីវិតរីករាយ**













## ឧបសម្ព័ន្ធទី១៤៖ សកម្មភាពកម្លាំងក្រុមអន្តរាគមន៍ បង្ការ បង្ក្រាប នៃស្នងការដ្ឋាន នគរបាលខេត្តបាត់ដំបង








# ឧបសម្ព័ន្ធទី១៥៖ បញ្ហាសំរាមនៅលើមុខផ្ទះប្រជាពលរដ្ឋ





# ឧបសម្ព័ន្ធទី១៦៖ បញ្ហាចិញ្ចើមផ្លូវ



ការយកថ្នល់ធ្វើជាកន្លែងដាក់លក់ទំនិញនៅផ្សារណាត់



លក់លើចិញ្ចើមផ្លូវធ្វើឱ្យអ្នកដំណើរគ្មានផ្លូវថ្មើរជើង

# ឧបសម្ព័ន្ធទី១៧៖ ការចតយានយន្តគ្មានសណ្តាប់ធ្នាប់









## ឧបសម្ព័ន្ធទី១៨៖ ភ្លៀងធ្លាក់មួយមេធំធ្វើឱ្យលិចផ្លូវខ្លះក្នុងក្រុងបាត់ដំបង





# ឧបសម្ព័ន្ធគតិយុត្ត

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ រ្តីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នា សម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបាន ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ៖

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរដ្ឋបាល

# រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ១៣៩.-**

គណៈអភិបាលរួមមាន ប្រធានមួយរូប ដែលហៅថា អភិបាល និងអភិបាលរងមួយចំនួន ។

**មាត្រា ១៤០.-**

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប ។

គណៈអភិបាលខេត្តមានចំនួនពីបី(០៣)រូប ទៅប្រាំពីរ(០៧)រូប ។

គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប ។

ចំនួនជាក់ស្តែងនៃគណៈអភិបាល សម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤១.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤២.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានឋានន្តរសក្តិឧត្តមមន្ត្រី

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧)ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

ROYAUME du CAMBODGE • LE MINISTRE du PALAIS ROYAL

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៨៥.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.–**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៨.

នស/រកម.០៥០៥.៥៩៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ: ៥៥៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

ព្រះរាជក្រម

នស/រកម/០៦២២/០០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ១០៥
ថ្ងៃ: ៣០ ខែ ៥ ឆ្នាំ២០២២
ម៉ោង: ១៤:១៥

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ២១៧/០០២/២០២២ កបធ.ច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



Scanned with CamScanner

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពី
# ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
# ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ
# នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨



Scanned with CamScanner

**មាត្រាមួយ.-**

មាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា១៤០.- ថ្មី**

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើន១១(ដប់មួយ)រូប។

គណៈអភិបាលខេត្តមានចំនួនពី៧(ប្រាំពីរ)រូប ទៅ១១(ដប់មួយ)រូប។

គណៈអភិបាលក្រុង ស្រុក ខណ្ឌ មានចំនួនពី៥(ប្រាំ)រូប ទៅ៧(ប្រាំពីរ)រូប។

ចំនួនជាក់ស្តែងនៃគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សុក្រ ៤កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០២២

នស.រកម.០៦២២.០០៩

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**



Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ១៨៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅថ្នាក់ក្រុង។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីមុខងារ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលក្រុង។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរដ្ឋបាលក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## មុខងាររបស់រដ្ឋបាលក្រុង

**មាត្រា ៤.-**

រដ្ឋបាលក្រុងត្រូវបំពេញមុខងារតាមការកំណត់នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមុខងារដែលបានផ្ទេរពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

មុខងារពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងវិស័យនីមួយៗត្រូវបានប្រគល់ និងប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុងដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ លើកលែងតែមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលក្រុងនៃខេត្តបាត់ដំបងមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យនេះ។

## ផ្នែកទី២

## តួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលក្រុង

**មាត្រា ១៥.-**

**ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងាររដ្ឋបាល និងហិរញ្ញវត្ថុ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ព័ត៌មាន ពិធីការ ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- ការងារអត្រានុកូលដ្ឋាន
- ការគ្រប់គ្រង និងការថែរក្សាត្រា ឯកសារ លិខិតបទដ្ឋាននានារបស់រដ្ឋបាលក្រុង
- ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង
- ការរៀបចំនីតិវិធីរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុសម្រាប់អង្គភាពរបស់រដ្ឋបាលក្រុង ផ្អែកតាមគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន
- ការងារហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង
- ការងាររបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ១៦.-**

**អង្គភាពលទ្ធកម្ម**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារលទ្ធកម្មសាធារណៈ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ការផ្ដល់ឯកសារដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើដេញថ្លៃ ការរៀបចំទីកន្លែង និងការរៀបចំបើកសំណើដេញថ្លៃ
- ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្ដីពីការបើកសំណើដេញថ្លៃ
- ការរៀបចំ និងការសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា
- ការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
- ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្ដីពីការអនុវត្តកិច្ចលទ្ធកម្ម
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ១៧.-**

**ការិយាល័យគ្រប់គ្រងធនធានមនុស្ស**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារ

គ្រប់គ្រងធនធានមនុស្ស និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់រដ្ឋបាលក្រុង
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលក្រុង
- ការគ្រប់គ្រងបុគ្គលិកផ្សេងទៀតតាមការផ្ទេរសិទ្ធិអំណាចពីរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ១៨.-**

**ការិយាល័យផែនការ និងគាំទ្រសង្កាត់**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារផែនការ និងគាំទ្រសង្កាត់ក្នុងក្រុង និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលក្រុង
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលក្រុង
- ការងារស្ថិតិប្រជាជន
- ការគាំទ្រ ការសម្របសម្រួល និងការតាមដាន ត្រួតពិនិត្យ វាយតម្លៃរដ្ឋបាលសង្កាត់ក្នុងក្រុងលើការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល និងគម្រោងនានារបស់រដ្ឋបាលសង្កាត់ក្នុងក្រុង
- ការណែនាំ និងការជំរុញការប្រមូលទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ក្រុងតាមការកំណត់
- ការគ្រប់គ្រង និងការស្វែងរកការគាំទ្រការកែច្នៃទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ក្រុង
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងក្រុមប្រឹក្សាសង្កាត់តាមតម្រូវការចាំបាច់
- ការគាំទ្របច្ចេកទេសលើការងាររដ្ឋបាល និងហិរញ្ញវត្ថុដល់រដ្ឋបាលសង្កាត់
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់រដ្ឋបាលសង្កាត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ១៩.-**

**ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការត្រួតពិនិត្យការបំពេញការងាររបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលក្រុង និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការត្រួតពិនិត្យលើការអនុវត្តតាមច្បាប់ ដីកា លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវានានាដែលបានកំណត់ជាធរមាន
- ការត្រួតពិនិត្យលើការងាររដ្ឋបាល ការងារបុគ្គលិក ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង

- ការត្រួតពិនិត្យការអនុវត្តវិន័យ បទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ និងម៉ោងបំពេញការងាររបស់បុគ្គលិករដ្ឋបាលក្រុង
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ២០.-**

**ការិយាល័យលេខាធិការក្រុមប្រឹក្សា**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារលេខាធិការដ្ឋានជូនក្រុមប្រឹក្សាក្រុង និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា
- ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា
- ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នានារបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង ការថែរក្សា និងការទុកដាក់ឯកសារនានារបស់ក្រុមប្រឹក្សា
- ការបិទផ្សាយ និងការផ្សព្វផ្សាយនូវសេចក្ដីសម្រេច និងឯកសារនានារបស់ក្រុមប្រឹក្សា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង។

**មាត្រា ២១.-**

**ការិយាល័យអប់រំ យុវជន និងកីឡា**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារអប់រំ យុវជន និងកីឡា និងមានភារកិច្ចគ្រប់គ្រង គាំទ្រ សម្របសម្រួល និងតាមដាន ត្រួតពិនិត្យ វាយតម្លៃលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការអប់រំកុមារតូច
- ការអប់រំបឋមសិក្សា
- ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ការអប់រំក្រៅប្រព័ន្ធ
- ការអភិវឌ្ឍយុវជន
- ការអប់រំកាយ និងកីឡា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ២២.-**

**ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងាររៀបចំដែនដី និងនគរូបនីយកម្ម
- ការងារភូមិបាល
- ការងារសំណង់
- ការងារលំនៅឋាន

- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ២៣.-**

**ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន**មានតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារនីតិកម្ម និងការសម្រុះសម្រួលវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការ និងមានភារកិច្ចចាត់ចែងលើការងារមួយចំនួនដូចខាងក្រោម៖

- ការសិក្សាស្រាវជ្រាវ ការរៀបចំ និងការផ្តល់យោបល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលក្រុង
- ការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដល់មន្ត្រី បុគ្គលិក និងប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង
- ការផ្តល់ប្រឹក្សាយោបល់ផ្លូវច្បាប់ដល់ប្រជាពលរដ្ឋ
- ការរៀបចំការបណ្តុះបណ្តាលជំនាញសម្រុះសម្រួល និងច្បាប់ដល់រដ្ឋបាលសង្កាត់ក្នុងក្រុង
- ការទទួលពាក្យបណ្តឹង និងការសម្រុះសម្រួលវិវាទនៅមូលដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុងស្របតាមច្បាប់កំណត់
- ការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចនានារបស់រដ្ឋបាលសង្កាត់ក្នុងក្រុងតាមគោលការណ៍កំណត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ២៤.-**

**ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារសាធារណការ និងដឹកជញ្ជូន
- ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ការគ្រប់គ្រងផ្សែង សម្លេង ក្លិន និងការបំពុលបរិយាកាស
- ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ
- ការដាំ ការគ្រប់គ្រង និងការថែទាំដើមឈើ និងសួនច្បារសាធារណៈ
- ការគ្រប់គ្រងភ្លើងបំភ្លឺទីសាធារណៈ
- ការគ្រប់គ្រងចំណតយានយន្តសាធារណៈ
- ការងារសណ្តាប់ធ្នាប់សាធារណៈ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ២៥.-**

**ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុង លើការអភិវឌ្ឍសេដ្ឋកិច្ច ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសហគមន៍ និងមានភារកិច្ចចាត់ចែង លើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារឧស្សាហកម្ម និងសិប្បកម្ម
- ការងាររ៉ែ និងថាមពល
- ការងារទេសចរណ៍
- ការងារធនធានទឹក
- ការងារអភិវឌ្ឍន៍ជនបទ
- ការងារពាណិជ្ជកម្ម
- ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការងារប្រៃសណីយ៍ និងទូរគមនាគមន៍
- ការងារអភិវឌ្ឍន៍សហគមន៍
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ២៦.-**

**ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុង លើការងារសង្គមកិច្ច និងសុខុមាលភាពសង្គម និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាង ក្រោម៖

- ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ការងារសុខាភិបាល
- ការងារកិច្ចការនារី
- ការងារធម្មការ និងសាសនា
- ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការងារវប្បធម៌ និងវិចិត្រសិល្បៈ
- ការងារគ្រោះមហន្តរាយ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ២៧.-**

**ការិយាល័យច្រកចេញចូលតែមួយ**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារផ្តល់ សេវារដ្ឋបាលនានា និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការទទួល និងការផ្តល់សេវារដ្ឋបាលនានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង
- ការប្រមូល និងការបង់កម្រៃសេវារដ្ឋបាលតាមគោលការណ៍ និងនីតិវិធីកំណត់

- ការផ្តល់ព័ត៌មាននានា និងការផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល
- ការទុកដាក់ ការថែរក្សា និងការគ្រប់គ្រងឯកសារនានាពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ២៨.-**

មុខងាររង ឬសកម្មភាពជាក់លាក់នៃមុខងារនីមួយៗរបស់រដ្ឋបាលក្រុងពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានតាមវិស័យនានាមានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ផ្នែកទី៣

## របៀបរបបការងាររបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលក្រុង

**មាត្រា ២៩.-**

ការិយាល័យ និងអង្គភាពនីមួយៗត្រូវបំពេញមុខងារស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

រដ្ឋបាលក្រុងត្រូវរៀបចំឱ្យមានលក្ខខណ្ឌការងារជាក់លាក់សម្រាប់បុគ្គលិកម្នាក់ៗ ដោយផ្អែកតាមតួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពនីមួយៗ និងគោលការណ៍ណែនាំជាធរមាន។

បុគ្គលិកម្នាក់ៗនៃការិយាល័យ និងអង្គភាពនីមួយៗត្រូវបំពេញតួនាទី ភារកិច្ចរបស់ខ្លួនស្របតាមលក្ខខណ្ឌការងារដែលបានកំណត់។

ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃដោយសហការជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងស្ថាប័នពាក់ព័ន្ធអាចផ្តល់ការណែនាំបន្ថែមអំពីការរៀបចំលក្ខខណ្ឌការងារខាងលើនេះ។

**មាត្រា ៣០.-**

រដ្ឋបាលក្រុងអាចរៀបចំឱ្យមានភ្នាក់ងារតាមការិយាល័យ និងអង្គភាពនីមួយៗសម្រាប់ទទួលបន្ទុកតាមកិច្ចការ ឬវិស័យជាក់លាក់ណាមួយ ឬមួយចំនួនតាមស្ថានភាពនៃក្រុងនីមួយៗ។

ការរៀបចំភ្នាក់ងារទទួលបន្ទុកតាមកិច្ចការ ឬវិស័យជាក់លាក់ណាមួយ ឬមួយចំនួនត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋបាលក្រុង។

**មាត្រា ៣១.-**

ការិយាល័យ និងអង្គភាពនីមួយៗត្រូវរៀបចំផែនការសកម្មភាព និងរបាយការណ៍ជាទៀងទាត់តាមគោលការណ៍កំណត់ ព្រមទាំងត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់ ដើម្បីត្រួតពិនិត្យលើការងារដែលបានអនុវត្ត កំណត់បញ្ហាប្រឈមនានាដែលត្រូវដោះស្រាយ និងកំណត់ទិសដៅដែលត្រូវអនុវត្តបន្ត។

**មាត្រា ៣២.-**

ប្រធានការិយាល័យ និងអង្គភាពនីមួយៗត្រូវធានាថាបុគ្គលិកក្នុងការិយាល័យ និងអង្គភាពរបស់ខ្លួនមកបំពេញការងារជាទៀងទាត់ អនុវត្តតួនាទី ភារកិច្ចតាមលក្ខខណ្ឌការងារ គោរពតាមបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌វិជ្ជាជីវៈដែលបានកំណត់។

**មាត្រា ៦២.-**

គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈត្រូវដឹកនាំដោយនាយកមួយ(០១)រូប និងមាននាយករងយ៉ាងច្រើនចំនួនបី(០៣)រូបជាជំនួយការ។

ការតែងតាំង និងការបញ្ចប់មុខតំណែងនាយក នាយករងនៃគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងនាយក នាយករងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈត្រូវអនុវត្តតាមតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន។

**មាត្រា ៦៣.-**

មជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវគ្រប់គ្រងដោយគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលត្រូវតែងតាំង និងផ្លាស់ប្តូរតាមគោលការណ៍ នីតិវិធី និងបែបបទជាធរមាន។

**មាត្រា ៦៤.-**

គ្រឹះស្ថានបឋមសិក្សាសាធារណៈមានតួនាទីគ្រប់គ្រង និងផ្តល់សេវាអប់រំកម្រិតបឋមសិក្សា និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន
- គ្រប់គ្រង និងប្រើប្រាស់បុគ្គលិកអប់រំបឋមសិក្សា
- គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលារៀន
- គ្រប់គ្រង ចាត់ចែង និងថែទាំសៀវភៅសិក្សាគោល
- គ្រប់គ្រងសំណង់អគារ សាងសង់ និងជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀន
- គ្រប់គ្រងសិស្សសាលាបឋមសិក្សា
- គ្រប់គ្រងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន
- គ្រប់គ្រងកម្មវិធីគាំទ្រការអប់រំបឋមសិក្សា
- ការងារអប់រំកាយ និងកីឡា
- អភិវឌ្ឍវិស័យអប់រំដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍនានា
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីអភិបាលក្រុង។

**មាត្រា ៦៥.-**

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈមានតួនាទីគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងផ្តល់សេវាអប់រំកម្រិតមត្តេយ្យសិក្សា និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន
- គ្រប់គ្រង និងប្រើប្រាស់បុគ្គលិកអប់រំមត្តេយ្យសិក្សា
- ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលាមត្តេយ្យសិក្សា

- គ្រប់គ្រងសំណង់អគារ សាងសង់ និងជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀន
- គ្រប់គ្រងសិស្សមត្តេយ្យសិក្សា
- គ្រប់គ្រងកម្មវិធីគាំទ្រការអប់រំកុមារតូច
- អភិវឌ្ឍវិស័យអប់រំដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍនានា
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីអភិបាលក្រុង។

**មាត្រា ៦៦.-**

ការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ត្រូវអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍នានាដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

គ្រឹះស្ថានសិក្សាសាធារណៈមានស្វ័យភាពក្នុងការគ្រប់គ្រងការរៀន និងការបង្រៀន ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ការវាយតម្លៃប្រសិទ្ធភាពបុគ្គលិកអប់រំ និងការងារគ្រប់គ្រងរដ្ឋបាល។

**មាត្រា ៦៧.-**

ការបង្កើត ការគ្រប់គ្រង និងតួនាទី ភារកិច្ចរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៦៨.-**

គ.ជ.អ.ប. ត្រូវដឹកនាំសម្របសម្រួលលើការសិក្សា និងការវាយតម្លៃទៅលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុងនៃខេត្តបាត់ដំបង ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលក្នុងការសម្រេចប្រគល់មុខងារទាំងនេះទៅឱ្យរដ្ឋបាលក្រុងនៃខេត្តដទៃទៀត។

## ជំពូកទី៨

## អន្តរប្បញ្ញត្តិ

**មាត្រា ៦៩.-**

ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមានរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ រដ្ឋបាលក្រុង និងការិយាល័យ អង្គភាពជំនាញនានានៅថ្នាក់ក្រុងត្រូវបន្តអនុវត្តតាមរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនាពេលបច្ចុប្បន្ន។

**មាត្រា ៧០.-**

គ.ជ.អ.ប. ត្រូវដឹកនាំ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំនូវកិច្ចការនានាពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ បុគ្គលិក ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងកិច្ចការចាំបាច់ផ្សេងទៀត ដើម្បីធានាឱ្យរដ្ឋបាលក្រុងអាចចាប់ផ្តើមអនុវត្តនូវមុខងារ និងតួនាទី ភារកិច្ចរបស់ខ្លួនតាមរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងដែលបានកំណត់ក្នុងអនុក្រឹត្យនេះចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០តទៅ។

**មាត្រា ៧៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ចន្ទ...៦...កើត...ខែ...មិគសិរ... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......២......ខែ......ធ្នូ......ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសុវត្ថិភាព សុខភាពសាធារណៈ និងការអភិរក្សជីវចម្រុះ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- រៀបចំ កែសម្រួល និងពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ប្រគល់មុខងារប្រតិបត្តិការ និងថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ
- កំណត់នូវវិធានការចាំបាច់នានាដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ អំពីការប្រើប្រាស់សេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ជំរុញឱ្យមានការចូលរួមពីដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន ក្នុងការអភិវឌ្ឍន៍ ឬវិនិយោគសាងសង់ ប្រតិបត្តិការនិងថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងទីប្រជុំជនរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះ ពុំមានវិសាលភាពអនុវត្តលើការគ្រប់គ្រងសំណល់រាវឧស្សាហកម្មឡើយ។

**មាត្រា៤.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- ទឹកកខ្វក់ សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់ រួចមានដូចជា ទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោម និងលាមកដែលបញ្ចេញពីលំនៅដ្ឋាន បុរីលំនៅដ្ឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និង តំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត
- សំណល់រាវ សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម
- ប្រព័ន្ធលូ សំដៅដល់បណ្ដាញប្រមូល និងបង្ហូរទឹកកខ្វក់រួមមាន៖ តំណភ្ជាប់ អណ្ដូងលូ និងបណ្ដាញលូ(បណ្ដាញលូរួម បណ្ដាញលូដាច់ដោយឡែក បណ្ដាញលូមេ បណ្ដាញលូមេរង បណ្ដាញលូខ្នែង និងបណ្ដាញលូខ្នែងរង)
- បណ្ដាញលូរួម សំដៅដល់បណ្ដាញលូប្រមូល និងបង្ហូរទឹកកខ្វក់ និងទឹកភ្លៀងជាមួយគ្នា។



kz

- បណ្តាញលូដាច់ដោយឡែក សំដៅដល់បណ្តាញលូប្រមូលនិងបង្ហូរទឹកកខ្វក់ និងទឹកភ្លៀងញែកដាច់ផ្សេងពីគ្នា
- បណ្តាញលូមេ សំដៅដល់បណ្តាញលូដែលភ្ជាប់ទៅនឹងអាងស្តុក ស្ថានីយ៍បូម ឬស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់
- បណ្តាញលូមេរង សំដៅដល់ប្រព័ន្ធលូដែលភ្ជាប់ទៅនឹងបណ្តាញលូមេ និងទទួលទឹកកខ្វក់ពីបណ្តាញលូខ្នែង
- បណ្តាញលូខ្នែង សំដៅដល់បណ្តាញលូដែលភ្ជាប់ទៅនឹងបណ្តាញលូមេ ឬបណ្តាញលូ មេរង។
- បណ្តាញលូខ្នែងរង សំដៅដល់បណ្តាញលូដែលភ្ជាប់ទៅនឹងបណ្តាញលូខ្នែង និងទទួលទឹកកខ្វក់ពីទីតាំង ឬប្រភពបញ្ចេញ
- ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយ៍បូមទឹកលូ ឬទឹកភ្លៀង បណ្តាញលូមេ បណ្តាញលូមេរង ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួមតាមលក្ខណៈបច្ចេកវិទ្យា ឬលក្ខណៈធម្មជាតិ
- អាងស្តុកធម្មជាតិ សំដៅដល់អាងស្តុកទឹក បឹង ប្រឡាយ ឬស្រះសាធារណៈ ដែលបានប្រើប្រាស់សម្រាប់ស្តុក និងសម្អាតទឹកកខ្វក់តាមលក្ខណៈធម្មជាតិ
- ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម សំដៅដល់រោងចក្រសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជនរាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ
- តំបន់ទឹកសាធារណៈ សំដៅដល់ប្រភពទឹកសម្រាប់ប្រើប្រាស់ជាសាធារណៈ ដូចជា ទន្លេ ដៃទន្លេ ស្ទឹង ព្រែក អូរ បឹង ស្រះ ត្រពាំង សមុទ្រ ដៃសមុទ្រ ពាម ប្រព័ន្ធប្រឡាយធារាសាស្ត្រ ទឹកក្រោមដី។ល។
- ទីប្រជុំជន សំដៅដល់ទីប្រជុំជនរាជធានី ទីប្រជុំជនខេត្ត ទីប្រជុំជនក្រុង ទីប្រជុំជនស្រុក និងទីប្រជុំជនខណ្ឌ
- ទីតាំង សំដៅដល់លំនៅដ្ឋាន លំនៅដ្ឋានប្រមូលផ្តុំ បុរីលំនៅដ្ឋាន អគារអាជីវកម្ម និងទីក្រុងរណប
- លំនៅដ្ឋាន សំដៅដល់ផ្ទះស្នាក់នៅជាលក្ខណៈឯកជនផ្ទាល់ខ្លួន
- លំនៅដ្ឋានប្រមូលផ្តុំ សំដៅដល់ផ្ទះស្នាក់នៅដែលទទួលសិទ្ធិកាន់កាប់បន្តពីអាជីវកម្មសាងសង់លំនៅដ្ឋានលក់ តែពុំមានអ្នកទទួលខុសត្រូវរួម
- បុរីលំនៅដ្ឋាន សំដៅដល់តំបន់អភិវឌ្ឍន៍លំនៅដ្ឋានប្រមូលផ្តុំដែលមានម្ចាស់បុរីនៅបន្តទទួលខុសត្រូវរួម
- អគារអាជីវកម្ម សំដៅដល់ផ្ទះសំណាក់ សណ្ឋាគារ ភោជនីយដ្ឋាន ទីផ្សារ ផ្សារទំនើប អគារពាណិជ្ជកម្ម អគារសេវាកម្ម ទីសត្តឃាត អាផាតមែន និងអគារខុនដូ



ㄥ

**មាត្រា៥៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៤ កើត ខែ បុស្ស ឆ្នាំរកា ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ គ.ស ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ** | **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន** | **រដ្ឋមន្ត្រី ក្រសួងបរិស្ថាន** |
|---|---|---|
| **សម្តេចក្រឡាហោម ស ខេង** | **ស៊ុន ចាន់ថុល** | **សាយ សំអាល់** |

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធទី១

## ស្តង់ដារបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់រមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ចូលទៅក្នុងប្រព័ន្ធលូដែលភ្ជាប់ទៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម

| លរ | ប៉ារ៉ាម៉ែត្រ | ឯកតា | កម្រិតកំណត់ស្តង់ដា |
|---|---|---|---|
| | | | កម្រិតសារធាតុបំពុលដែលអនុញ្ញាតឱ្យបញ្ចេញ ចូលទៅក្នុងប្រព័ន្ធលូ |
| ១ | ប៉េហាស់ ( pH ) | - | ៥ - ៩ |
| ២ | សារធាតុរឹងដែលអណ្តែតក្នុងទឹក (TSS) | mg/l | < ១៥០ |
| ៣ | ប្រេង ឬខ្លាញ់ | mg/l | < ២០ |
| ៤ | $BOD_5$ ( 5 days at 20 $^0$C ) | mg/l | < ៨០ |
| ៥ | COD ($Cr_2O_7^{2-}$ ) | mg/l | < ១២០ |
| ៦ | សាប៊ូ (Detergents -LAS) | mg/l | < ១៥ |
| ៧ | អាស៊ូតសរុប (T-N) | mg-N/l | < ១០ |
| ៨ | ផូស្វ័រសរុប (T-P) | mg-P/l | < ១ |
| ៩ | អាម៉ូញ៉ាក់ ( $NH_3$ ) | mg/l | < ៨ |

<u>កំណត់សំគាល់</u>

BOD៖ការវាស់តម្រូវការបរិមាណអុកស៊ីសែនរលាយក្នុងទឹក ដោយពពួកមីក្រូសរីរាង្គត្រូវការខ្យល់សម្រាប់បំបែកសារធាតុសរីរាង្គ ដែលមាននៅក្នុងសំណាកនៃទឹក។

COD៖ការវាស់តម្រូវការបរិមាណអុកស៊ីសែន សម្រាប់ប្រតិកម្មអុកស៊ីតកម្មបំបែកសារធាតុសរីរាង្គក្នុងទម្រង់រលាយ ឬជាគ្រាប់ ដែលមានក្នុងទឹក។

## តារាងឧបសម្ព័ន្ធទី២
## ស្តង់ដារបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប
## និងតំបន់រមណីយដ្ឋាន ឬមណ្ឌលកំសាន្ត
## ចូលទៅក្នុងតំបន់ទឹកសាធារណៈដោយផ្ទាល់ ឬឆ្លងកាត់តាមប្រព័ន្ធលូ

| ល.រ | ប៉ារ៉ាម៉ែត្រ | ឯកតា | កម្រិតកំណត់ស្តង់ដា<br>កម្រិតសារធាតុបំពុលដែលអនុញ្ញាតឱ្យបញ្ចេញ ចូលទៅក្នុងប្រភពទឹកសាធារណៈ |
|---|---|---|---|
| ១ | ប៉េហាស់(pH) | - | ៦ - ៨ |
| ២ | សារធាតុរឹងដែលអណ្តែតក្នុងទឹក(TSS) | mg/l | < ៨០ |
| ៣ | ប្រេង ឬខ្លាញ់ | mg/l | < ៥ |
| ៤ | $BOD_5$ ( 5 days at 20 °C ) | mg/l | < ៣០ |
| ៥ | COD ( $Cr_2O_7^{2-}$) | mg/l | < ៥០ |
| ៦ | សាប៊ូ ( Detergents -LAS ) | mg/l | < ៧ |
| ៧ | អាសូតសរុប (T-N) | mg-N/l | < ៦ |
| ៨ | ផូស្វ័រសរុប (T-P) | mg-P/l | < ០,៥ |
| ៩ | អាម៉ូញ៉ាក់($NH_3$) | mg/l | < ៥ |
| ១០ | កូលីហ្វម (Coliform) | MPN/100 ml | ៥០០ - ២៥០០ |

កំណត់សំគាល់

BOD៖ការវាស់តម្រូវការបរិមាណអុកស៊ីសែនរលាយក្នុងទឹក ដោយពពួកមីក្រូសរីរាង្គត្រូវការខ្យល់សម្រាប់បំបែក សារធាតុសរីរាង្គ ដែលមាននៅក្នុងសំណាកនៃទឹក។

COD៖ការវាស់តម្រូវការបរិមាណអុកស៊ីសែន សម្រាប់ប្រតិកម្មអុកស៊ីតកម្មបំបែកសារធាតុសរីរាង្គក្នុងទម្រង់រលាយ ឬជាគ្រាប់ ដែលមានក្នុងទឹក។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ...៧៥....អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១**.-

ត្រូវបានបង្កើត **គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** ដែលសរសេរជាអក្សរកាត់ថា «**គ.គ.ស.**» ដើម្បីដោះស្រាយជាខ្សែច្រវាក់ពីដើមខ្សែរហូតដល់ចុងខ្សែក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន សំដៅសម្រេចបាននូវការកែច្នៃសំរាម សំណល់រឹងក្នុងស្រុកផលិតជាថាមពលអគ្គិសនី ។

**មាត្រា ២.-**

**គ.គ.ស.** មានភារកិច្ចដូចតទៅ៖

កម្រិតទី១៖ គោលនយោបាយ

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងយន្តការតាមដានការអនុវត្ត
- កសាងក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- គិតគូរអំពីយន្តការលើកទឹកចិត្តនានាដល់ការវិនិយោគលើវិស័យកែច្នៃសំរាម សំណល់រឹងផលិតជាថាមពលអគ្គិសនី (តាមទម្រង់ណាមួយដែលសមស្រប និងប្រកបដោយប្រសិទ្ធភាព) និង
- គិតគូរអំពីយន្តការលើកទឹកចិត្តនានា ឱ្យមានការប្រើប្រាស់ផលិតផលដែលមានផលប៉ះពាល់តិច ឬគ្មានដើម្បីកាត់បន្ថយការប្រើប្រាស់ផលិតផលណាដែលនាំឱ្យមានផលប៉ះពាល់ខ្លាំងដល់បរិស្ថាន ។

កម្រិតទី២៖ ប្រតិបត្តិការ

- សិក្សាបទពិសោធន៍របស់បណ្តាប្រទេសនានាក្នុងតំបន់ ឬប្រទេសអភិវឌ្ឍន៍ដទៃទៀតដែលមានឧត្តមានុវត្តន៍ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង រួមទាំងការកែច្នៃសំណល់រឹង និងការបំប្លែងទៅជាថាមពលអគ្គិសនី
- លើកអនុសាសន៍ជាវិធានការ និងដឹកនាំ សម្របសម្រួល ព្រមទាំងតាមដានការអនុវត្តការកែទម្រង់របៀបនៃការគ្រប់គ្រងក្រុមហ៊ុនប្រមូលសំរាម សំណល់រឹងនាពេលបច្ចុប្បន្ន ព្រមទាំងយន្តការបង់ថ្លៃទូទាត់សេវា និងកំណត់នីតិវិធីដោះស្រាយបញ្ហាឱ្យបានច្បាស់លាស់ជាស្ថាពរ និង
- ធ្វើយុទ្ធនាការអប់រំ និងផ្សព្វផ្សាយទ្រង់ទ្រាយធំទូទាំងប្រទេស សំដៅកែប្រែឥរិយាបថរបស់ប្រជាពលរដ្ឋ ។

## ជំពូកទី២
## សមាសភាព និងរចនាសម្ព័ន្ធ

**មាត្រា ៣.-**

**គ.គ.ស.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២. រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | អនុប្រធាន |
| ៣. រដ្ឋលេខាធិការ /អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៥. រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៦. រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |

**មាត្រា ១២.-**

ប្រធាន **គ.គ.ស.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ អង្គារ ៥ កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច**
**និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់

# និងការរំខានដោយសំលេង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ  :** ៤២ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់

# និងការរំខានដោយសំលេង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៩ ខែ  មិថុនា ឆ្នាំ ២០០០។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័តនិងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក -"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ភេទ ។

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណង់ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ទនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសាធារបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងឧបសម្ព័ន្ធ ២ ។

ឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៨.-**

អនុក្រឹត្យនេះចូលជាធរមានគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ១

## កំរិតកំណត់ស្តង់ដារគុណភាពខ្យល់

| ល.រ | ប៉ារ៉ាម៉ែត្រ | រយៈពេល១ម៉ោង ជាមធ្យម mg/m3 | រយៈពេល៨ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល២៤ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល ១ឆ្នាំ ជាមធ្យម$mg/m^3$ |
|---|---|---|---|---|---|
| 1 | កាបូនឌីអុកស៊ីត CO | 40 | 20 | | |
| 2 | អាសូតឌីអុកស៊ីត$NO_2$ | 0,3 | | 0,10 | |
| 3 | ស្ពាន់ធ័រឌីអុកស៊ីត$SO_2$ | 0,5 | | 0,30 | 0,10 |
| 4 | អូសូន $0_3$ | 0,2 | | | |
| 5 | សំណ Pb | | | 0,005 | |
| 6 | សារធាតុរឹងអណ្តែត ក្នុងខ្យល់ TSP | | | 0,33 | 0,10 |

**កំណត់សំគាល់**

-កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ធ្វើការវាយតំលៃគុណភាពខ្យល់ទូទៅ និងអង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់ ។

-វិធីសាស្ត្រនៃការវិភាគគុណភាពខ្យល់នឹងត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន

-TSP Total Suspended Particulate

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ  ២

## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់

| ល.រ | ឈ្មោះសារធាតុគីមី | រូបមន្តគីមី | កំរិតអតិបរមា (mg/$m^3$) |
|---|---|---|---|
| 1 | អានីលីន | $C_6H_5NH_2$ | 0,03 |
| 2 | អាម៉ូញាក់ | $NH_3$ | 0,2 |
| 3 | អាស៊ីត អាសេទិច | $CH_3COOH$ | 0,2 |
| 4 | អាស៊ីតស៊ុលផួរិច | $H_2SO_4$ | 0,3 |
| 5 | អាស៊ីតនីទ្រិច | $HNO_3$ | 0,4 |
| 6 | បង់សែន | $C_6H_6$ | 1 |
| 7 | បង់ស៊ីឌីន | $NH_2C_6H_4C_6H_4NH_2$ | គ្មាន |
| 8 | កាបូនឌីស៊ុលហ្វិត | $CS_2$ | 0,02 |
| 9 | ក្លរ៉ូហ្វម | $CHCL_3$ | 0,01 |
| 10 | កាបូនតេត្រាក្លរិត | $CCL_4$ | 3 |
| 11 | ភាគល្អិតដែលមាន asbestor | | គ្មាន |
| 12 | ដេ ដេ តេ | $C_8H_{11}CL$ | 0,5 |
| 13 | ហ្វម៉ល់ដេអ៊ីត | HCOH | 0,012 |
| 14 | អ៊ីដ្រូសែន អាសេនិច | $AsH_3$ | 0,002 |
| 15 | អ៊ីដ្រូសែន ស៊ីអានីត | HCN | 0,01 |
| 16 | អ៊ីដ្រូសែន ភ្លុយអរិច | HF | 0,002 |
| 17 | អ៊ីដ្រូសែនស៊ុលហ្វិត | $H_2S$ | 0,001 |
| 18 | ផេណុល | $C_6H_5OH$ | 0,01 |
| 19 | ស៊ីរេន | $C_6H_5CHCH_2$ | 0,003 |
| 20 | តេត្រាក្លរូអេទីឡែន | $C_2Cl_4$ | 0,1 |
| 21 | សំណតេត្រាអេទិល | $Pb(C_2H_5)_4$ | 0,005 |
| 22 | ទ្រីក្លរូអេទីឡែន | $CLCHCCL_2$ | 0,2 |
| 23 | តូលុយអេន | $C_9H_5CH_3$ | 0,4 |
| 24 | វិនិក្លរួ | $CLCHCH_2$ | 0,05 |

| | | | |
|---|---|---|---|
| 25 | អាសេទិច (សមាសធាតុអសរីរាង្គ) | As | 0,00001 |
| 26 | កាត់ម្ញូម(សមាសធាតុលោហៈ និងអុកស៊ីត) | Cd | 0,003 |
| 27 | ក្រូម(លោហៈ និងសមាសធាតុ) | Cr | 0,0015 |
| 28 | នីកែល (លោហៈ និងសមាសធាតុ) | Ni | 0,0001 |
| 29 | បារត(លោហៈ និងសមាសធាតុ) | Hg | 0,0001 |
| 30 | ប្រេងសាំង | | 5 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់ ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៣

## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញ

## ពីប្រភពអចល័ត ចូលទៅក្នុងបរិយាកាស

| ល.រ | ប៉ារ៉ាម៉ែត | កំរិតអតិបរមានៃការបញ្ចេញ |
|---|---|---|
| 1 | ភាគល្អិតនៅក្នុងផ្សែង បញ្ចេញពីប្រភព : | |
| | -ឡដុត | 400 mg/$m^3$ |
| | -រោងចក្រផលិតលោហធាតុ | 400 mg/$m^3$ |
| | -រោងចក្រស៊ីម៉ង់ត៍ កំបោរ និងថ្មស្អុយ | 400 mg/$m^3$ |
| | -រោងចក្របេតុងអាស្ពាល់ | 500 mg/$m^3$ |
| 2 | ធូលី ដែលមានភ្ជាប់ : | |
| | -សារធាតុ ស៊ីលីកាត $Si0_2$ | 100 mg/$m^3$ |
| | -សារធាតុ Asbetos | 27 µg/$m_3$ |
| | -សារធាតុគីមីអសរីរាង្គ : | |
| 3 | អាលុយមីញ៉ូម AL | (ធូលី) ៣00 mg/$m^3$ ⁚(Al) 50 mg/$m^3$ |
| 4 | អាម៉ូញាក់ $NH_3$ | 100 mg/$m^3$ |
| 5 | អាង់ទីម៉ូន Sb | 25 mg/$m^3$ |
| 6 | អាសេទិច As | 20 mg/$m_3$ |
| 7 | បេរីល្យ៉ូម Be | 10 µg/$m_3$ |
| 8 | ក្លរ CL | 20 mg/$m_3$ |
| 9 | អ៊ីដ្រូសែនក្លរីត HCL | 200 mg/$m_3$ |
| 10 | អ៊ីដ្រូសែនភ្លុយអរីត HF | 10 mg/$m_3$ |
| 11 | អ៊ីដ្រូសែនស៊ុលភីត $H_2F$ | 2 mg/$m_3$ |
| 12 | កាត់ម្យ៉ូម Cd | 1 mg/$m_3$ |
| 13 | ទង់ដែង Cu | (ធូលី) ៣00mg/$m_3$ (Cu) 20 mg/$m_3$ |
| 14 | សំណ Pb | (ធូលី) ១00 mg/$m_3$ (Pb) 30 mg/$m_3$ |
| 15 | ស័ង្កសី Zn | 30 mg/$m_3$ |
| 16 | បារត Hg | 0,1 mg/$m_3$ |
| 17 | កាបូនម៉ូណូអុកស៊ីត Co | 1000 mg/$m_3$ |

| | | |
|---|---|---|
| 18 | ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | 500 $mg/m^3$ |
| 19 | អាសូតអុកស៊ីត( គ្រប់ប្រភេទ) NOx | 1000 $mg/m^3$ |
| 20 | អាសូតអុកស៊ីត( ចេញពីការផលិតអាស៊ីត)NOx | 2000 $mg/m^3$ |
| 21 | អាស៊ីតស៊ុលផួរិច $H_2SO_4$ | 35 $mg/m^3$ |
| 22 | អាស៊ីតនីទ្រិច $HNO_3$ | 70 $mg/m^3$ |
| 23 | ស្ពាន់ធ័រទ្រីអុកស៊ីត ($SO_3$) | 35 $mg/m^3$ |
| 24 | អាស៊ីតផូស្វរិច ($H_3PO_4$) | 3 $mg/m^3$ |
| | សារធាតុគីមីសរីរាង្គ : | |
| 25 | អាសេទីឡែនតេត្រាប្រូមីត $CHBr_2CHBr_2$ | 14 $mg/m^3$ |
| 26 | អាក្រូឡេអ៊ិន $CH_2CHCHO$ | 1,2 $mg/m^3$ |
| 27 | អានីលីន $C_6H_5NH_2$ | 19 $mg/m^3$ |
| 28 | បង់ស៊ីឌីន $NH_2C_6H_4C_6H_4NH_2$ | None |
| 29 | បង់សែន $C_6H_6$ | 80 $mg/m^3$ |
| 30 | ក្លរបង់ស៊ីល $C_6H_5CH_2Cl$ | 5 $mg/m^3$ |
| 31 | ប៊ុយទីលឡាមីន $CH_3(CH_2)_2CH_2NH_2$ | 15 $mg/m^3$ |
| 32 | ក្រេសូល (O-,m-,P-) $CH_3C_6H_4OH$ | 22 $mg/m^3$ |
| 33 | ក្លរបង់សែន $C_6H_5Cl$ | 350 $mg/m^3$ |
| 34 | ក្លរហ្វម $CHCl_3$ | 240 $mg/m^3$ |
| 35 | ក្លរពីគ្រីន $CCl_3NO_2$ | 0,7 $mg/m^3$ |
| 36 | O-ឌីក្លរបង់សែន $C_6H_4Cl_2$ | 300 $mg/m^3$ |
| 37 | 1.1-ឌីក្លរអេតាន $CHCl_2CH_3$ | 400 $mg/m^3$ |
| 38 | ឌីមេទីលស៊ុលហ្វាត $(CH_3)_2SO_4$ | 0,5 $mg/m^3$ |
| 39 | ឌីមេទីលអ៊ីដ្រាហ្ស៊ីន $(NH_3)_2NNH_2$ | 1 $mg/m^3$ |
| 40 | ឌីនីត្រូបង់សែន (O-,m-,P-) $C_6H_4(NO_2)_2$ | 1 $mg/m^3$ |
| 41 | អេទីឡែនឌីអាមីន $NH_2CH_2$-$CH_2NH_2$ | 30 $mg/m^3$ |
| 42 | អេទីឡែន ក្លរអ៊ីឌ្រីន $CH_2ClCH_2OH$ | 16 $mg/m^3$ |
| 43 | អេទីឡែន អុកស៊ីត $CH_2OCH_2$ | 20 $mg/m^3$ |
| 44 | ហ្វ័រម៉ាល់ដេអ៊ីដ HCHO | 6 $mg/m^3$ |
| 45 | មេទីលអាគ្រីឡាត $CH_2CHCOOCH_3$ | 35 $mg/m^3$ |
| 46 | មេតាណុល $CH_3OH$ | 260 $mg/m^3$ |
| 47 | មេទីលប្រូមីត $CH_3Br$ | 80 $mg/m^3$ |

| | | |
|---|---|---|
| 48 | ម៉ូណូមេទីលអានីលីន $C_6H_5NHCH_3$ | 9 mg/m$^3$ |
| 49 | នីត្រូបង់សែន $C_6H_5NO_2$ | 5 mg/m$^3$ |
| 50 | នីត្រូគ្លីសេរីន $C_3H_5(NO_2)_3$ | 5 mg/m$^3$ |
| 51 | នីត្រូតូលូអែន $NO_2C_6H_4CH_3$ | 30 mg/m$^3$ |
| 52 | ផេណុល $C_6H_5OH$ | 19 mg/m$^3$ |
| 53 | ផេនីលអ៊ីដ្រាហ្ស៊ីន $C_6H_5NHNH_2$ | 22 mg/m$^3$ |
| 54 | ពីរីនឌីន $C_5H_5N$ | 30 mg/m$^3$ |
| 55 | ពីរ៉ែន $C_{16}H_{10}$ | 15 mg/m$^3$ |
| 56 | គ្វីណូន $C_6H_4O_2$ | 0,4 mg/m$^3$ |
| 57 | ស្ទីរ៉ែន $C_6H_5CHCH_2$ | 420 mg/m$^3$ |
| 58 | 1,1,2,2-តេត្រាក្លរូអេតាន $Cl_2HCCHCl_2$ | 35 mg/m$^3$ |
| 59 | តេត្រាក្លរូមេតាន $CCl_4$ | 65 mg/m$^3$ |
| 60 | តូលូអែន $C_6H_5CH_3$ | 750 mg/m$^3$ |
| 61 | តេត្រានីត្រូមេតាន $C(NO_2)_4$ | 8 mg/m$^3$ |
| 62 | តូលូអ៊ីឌីន $CH_3C_6H_4NH_2$ | 22 mg/m$^3$ |
| 63 | តូលូអែន 2.4- ឌីអ៊ីសូស៊ីអាណាត $CH_3C_6H_3(NCO)_2$ | 0,7 mg/m$^3$ |
| 64 | ទ្រីក្លរូអេទីឡែន $ClCHCCl_2$ | 110 mg/m$^3$ |
| 65 | ស៊ីលីឌីន $(CH_3)_2C_6H_3NH_2$ | 50 mg/m$^3$ |
| 66 | វីនីលក្លរីត $CH_2CHCl$ | 150 mg/m$^3$ |

**កំណត់សំគាល់**

ករិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៤

## កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត

| ល.រ | ប្រភេទយានយន្ត | ប្រភេទប្រេងឥន្ធនៈ | កំរិតនៃការបញ្ចេញ | | | | |
|---|---|---|---|---|---|---|---|
| | | | CO (%) | | HC(ppm) | | ផ្សែងខ្មៅ % |
| | | | ក | ខ | ក | ខ | |
| 1 | ទោចក្រយានយន្តដែលមានចំហេះ២វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 3000 | |
| 2 | ទោចក្រយានយន្តដែលមានចំហេះ៤វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 2400 | |
| 3 | យានយន្តគ្រប់ប្រភេទ | ប្រេងសាំង | 4,5 | 4 | 1200 | 800 | |
| 4 | យានយន្តគ្រប់ប្រភេទ | ប្រេងម៉ាស៊ូត | | | | | ៥០ |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញឧស្ម័នពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

ក-គឺសំដៅលើយានយន្តគ្រប់ប្រភេទដែលប្រើប្រាស់ហួសរយៈពេល ៥ឆ្នាំ គិតពីឆ្នាំដែលផលិត ។

ខ-គឺសំដៅទៅលើយានយន្តគ្រប់ប្រភេទដែលបាននាំចូលថ្មីក្នុងរយៈពេល ប្រាំឆ្នាំដំបូងគិតចាប់ពីឆ្នាំដែលផលិត ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៥

# កំរិតកំណត់ស្តង់ដារអតិបរមា ដែលអនុញ្ញាតបញ្ចេញសំលេងនៅលើផ្លូវសាធារណៈ ពីប្រភពយានយន្ត

| ល.រ | ប្រភេទយានយន្ត | កំរិតអតិបរមា (dB (A)) |
|---|---|---|
| 1 | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)< 125 $Cm^3$ | 85 |
| 2 | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)≥ 125 $Cm^3$ | 90 |
| 3 | **ត្រីចក្រយានយន្ត** | 90 |
| 4 | រថយន្តធុនតូច រថយន្តដឹកអ្នកដំណើរ ១២ នាក់ | 80 |
| 5 | រថយន្តដឹកអ្នកដំណើរ ≥ ១២ នាក់ | 85 |
| 6 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ < 3,5 តោន | 85 |
| 7 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ > 3,5 តោន | 88 |
| 8 | រថយន្តដឹកទំនិញដែលមានកំលាំង ≥ 150 kw | 89 |
| 9 | គ្រឿងយន្តផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ | 91 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតបញ្ចេញសំលេងពីប្រភពយានយន្តគ្រប់ប្រភេទ ដែលកំពុងធ្វើចរាចរលើផ្លូវសាធារណៈ ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៦

## កំរិតកំណត់ស្តង់ដារសំលេងអតិបរមា ដែលអនុញ្ញាតនៅតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន (dB(A))

| ល.រ | ទីតាំង | អំឡុងពេល | | |
|---|---|---|---|---|
| | | ពីម៉ោង ៦ព្រឹកដល់ម៉ោង ១៨ល្ងាច | ពីម៉ោង ១៨ល្ងាចដល់ម៉ោង ២២យប់ | ពីម៉ោង២២យប់ដល់ម៉ោង ៦ព្រឹក |
| 1 | តំបន់ស្ងប់ស្ងៀម<br>-មន្ទីរពេទ្យ<br>-បណ្ណាល័យ<br>សាលារៀន<br>មតេយ្យសាលា | 45 | 40 | 35 |
| 2 | តំបន់លំនៅដ្ឋាន<br>-សណ្ឋាគារ ទីកន្លែង រដ្ឋបាល<br>-ភូមិគ្រឹះ ផ្ទះល្វែង | 60 | 50 | 45 |
| 3 | តំបន់ពាណិជ្ជកម្ម សេវាកម្ម និងចំរុះ | 70 | 65 | 50 |
| 4 | ឧស្សាហកម្មធុនស្រាល លាយចំរុះនៅក្នុងតំបន់លំនៅដ្ឋាន | 75 | 70 | 50 |

### កំណត់សំគាល់

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងពីប្រភព ឬសកម្មភាពណាមួយ ដែលបញ្ចេញសំលេងចូលក្នុងតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៧

## កំរិតកំណត់ស្តង់ដារសំរាប់ត្រួតពិនិត្យសំលេង

## ក្នុងទីតាំង រោងជាង រោងចក្រឧស្សាហកម្ម

| កំរិតសំលេង (dB(A)) | រយៈពេលអតិបរមា (ម៉ោង) | កំណត់បង្ហាញ |
|---|---|---|
| 75 | 32 | ត្រូវផ្តល់ឧបករណ៍ការពារត្រចៀកដល់អ្នកបំរើការដែលធ្វើការនៅកន្លែងមានសំលេងលើសពី 80dB (A) |
| 80 | 16 | |
| 85 | 8 | |
| 90 | 4 | |
| 95 | 2 | |
| 100 | 1 | |
| 105 | 0,5 | |
| 110 | 0,25 | |
| 115 | 0,125 | |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងនៅក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៧

# កំរិតកំណត់ស្តង់ដារ ជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាប៊ួប្រហើរ ដែលអនុញ្ញាតឱ្យមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម

| ល.រ | សារធាតុចំហេះ | ស្ពាន់ធ័រ(S) | សណ(Pb) | បង់សែន | អ៊ីដ្រូកាប៊ួប្រហើរ |
|---|---|---|---|---|---|
| 1 | ប្រេងខ្មៅ | 1,0% | | | |
| 2 | ប្រេងម៉ាស៊ូត | 0,2% | | | |
| 3 | ប្រេងសាំង | | 0,15 ក្រាម/លីត្រ | 3,5% | 50% |
| 4 | ធ្យូងថ្ម | 1,5% | | | |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ត្រួតពិនិត្យជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាប៊ួប្រហើរ ដែលអនុញ្ញាតអោយមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ** : ៣៦ អ.ន.ក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងសំណល់រឹង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៩ ។

# សំរេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.**–

អនុក្រឹត្យនេះមានគោលដៅកំនត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២.**–

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចោញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ៣.**–

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ :

ក-"**សំណល់រឹង**" គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទីដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតំរូវឱ្យបោះបង់ចោល ។

ខ-"**សំរាម**" គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចោញពីលំនៅស្ថាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ល។

គ-"**សំណល់ប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កអោយមានជំងឺមហារីក ចំលងជំងឺ ធ្វើអោយរលាក ធ្វើអោយច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្មអាជីវកម្មរ៉ែ ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## ការគ្រប់គ្រងសំរាម

**មាត្រា ៤.**–

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី គោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត-ក្រុង របស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេល

មធ្យម និងរយៈពេលវែង ។

**មាត្រា ៥.-**

ការអនុវត្តន៍ក្នុងការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី ១ នៃមាត្រា៥ នេះត្រូវអនុលោមទៅតាមគោលការណ៍ណែនាំលើការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ដែលមានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦.-**

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ក្នុងការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ។

**មាត្រា ៧.-**

ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៨.-**

ការវិនិយោគក្នុងស្រុកលើការសាងសង់កន្លែងចាក់ចោល ដុត ស្តុក ឬកែច្នៃសំរាម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ៩.-**

ការនាំចេញសំរាមពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបានល្គឹកណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្មព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

**មាត្រា ១០.-**

ហាមឃាត់ជាដាច់ខាត ការនាំសំរាមពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣

## ការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

**មាត្រា ១១.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពីគោលការណ៍ណែនាំ លើការគ្រប់គ្រងសំណល់ ប្រកបដោយគ្រោះថ្នាក់ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាព ។

**មាត្រា ១២.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី កំរិតស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ នៅក្នុងសំណល់ប្រ

កបដោយគ្រោះថ្នាក់ ដែលអាចអនុញ្ញាតអោយបោះបង់ចោល ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស ការការពារគុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ១៣.-**

ម្ចាស់សំណល់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្របនឹងមានសុវត្ថិភាព ។

**មាត្រា ១៤.-**

ម្ចាស់សំណល់ ត្រូវធ្វើ និងផ្ញើរបាយការណ៍រាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទង និងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន :

ក-ប្រភេទ និងបរិមាណសំណល់

ខ-វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ-វិធីសាស្ត្រក្នុងការសំអាតសំណល់ ឬបំបាត់សំណល់ ។

**មាត្រា ១៥.-**

ការទុកដាក់ ស្តុក ដឹកជញ្ជូន និងការបោះចោល ឬចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុវត្តដាច់ដោយឡែកពីសំរាមធម្មតា ដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

ហាមឃាត់ជាដាច់ខាត ការបោះចោល ឬការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភព ឬបណ្តាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ ។

**មាត្រា ១៦.-**

ការប្រមូល ដឹកជញ្ជូន ស្តុក និងការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ តាមលំនៅស្ថាន ទីផ្សារ គ្លីនិក សម្ភព មន្ទីរពេទ្យ សណ្ឋាគារ ភោជនីយដ្ឋាន និងអាគារសាធារណៈ គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តនៃវាក្យខ័ណ្ឌទី១ នៃមាត្រា១៦ នេះ ត្រូវអនុលោមទៅតាមប្រកាសរបស់ក្រសួងបរិស្ថាន ស្តីពី គោលការណ៍ណែនាំលើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ១៧.-**

ការដឹកជញ្ជូន ឬសាងសង់ទីកន្លែងចាក់ ឬទីកន្លែងស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ដែលមានប្រភពពីរោងចក្រ សហគ្រាស និងមូលដ្ឋានផលិតកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ១៨.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងចាក់ ឬស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវធ្វើ និងផ្ញើរបាយការណ៍រាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងទៅនឹងសំណល់ ដែលបានដឹកយកមកចាក់ចោល ឬស្តុកនៅកន្លែងរបស់ខ្លួន រួមមាន :

ក-ប្រភេទ និងបរិមាណសំណល់

ខ-ប្រភពដើមរបស់សំណល់

គ-ការដឹកជញ្ជូនរបស់សំណល់ និងមធ្យោបាយវេចខ្ចប់

ឃ-ដំណើរការ និងការគ្រប់គ្រងសំណល់នៅក្នុងទីកន្លែងរបស់ខ្លួន ។

**មាត្រា ១៩.-**

ការវិនិយោគលើការធ្វើប្រព្រឹត្តកម្មសំអាត ឬដុតសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវមានការឯកភាពពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ២០.-**

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបាន លុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍នៃអនុសញ្ញាអន្តរជាតិបាសែល ស្តីពីការត្រួតពិនិត្យការដឹកជញ្ជូនអន្តរជាតិ និងការបោះបង់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ឆ្នាំ ១៩៨៩ ដែលចូលជាធរមាននៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩២ ។

**មាត្រា ២១.-**

ហាមឃាត់ជាដាច់ខាត ការនាំចូលសំណល់ប្រកបដោយគ្រោះថ្នាក់ពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៤
## ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច
## លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

**មាត្រា ២២.-**

ការត្រួតពិនិត្យលើការវេចខ្ចប់ ទុកដាក់ ស្តុក ដឹកជញ្ជូន កែច្នៃ ដុត ធ្វើប្រព្រឹត្តកម្មសំអាតជាតិពុល និងការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ២៣.-**

ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ នៅគ្រប់គោលដៅដែលមានចែងក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រា២៣ នេះត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២៤.-**

ការវិភាគគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ ក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចត្រូវយកទៅធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា២៣ នៃអនុក្រឹត្យនេះ អាចសុំធ្វើការវិភាគគំរូតាងសំណល់របស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តនូវវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា២៣ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃវិភាគសំណល់របស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំណូលនេះ ត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៥.-**

ក្នុងករណីដែលរកឃើញថា មានការលួចចាក់ចោល ឬបោះចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតិពីស្ថាប័នមានសមត្ថកិច្ច ក្រសួងបរិស្ថាន សហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រូវចុះធ្វើអធិការកិច្ចដល់ទីកន្លែងនោះ ដោយអនុវត្តន៍តាមនីតិវិធី ដែលមានចែងខាងក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬទីកន្លែងនោះ ដើម្បីធ្វើអធិការកិច្ច និងយកគំរូតាង ។

ខ-ត្រូវធ្វើនៅនឹងកន្លែង នូវកំណត់ហេតុ និងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ-ត្រូវសាកសួរ និងតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ ឬកំណត់ហេតុ និងសំរាប់ជាវត្ថុតាង ។

ឃ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ។

**មាត្រា ២៦.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា មានស្តុកទុក ឬការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់បណ្តាលអោយប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលបរិស្ថាន ក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ ហើយត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ២៧.-**

ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោសដោយយោងទៅតាម មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ២៨.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមសមគំនិត នឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនោះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

**មាត្រា ២៩.-**

កំណត់ហេតុ និងការធ្វើបណ្តឹង ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។

## ជំពូកទី ៦

## អវសានបញ្ញត្តិ

**មាត្រា ៣០.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា ៣២.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣១

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

# តារាងឧបសម្ព័ន្ធ

## ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

១-សំណល់សរសៃអំបោះ និងកំទេចក្រណាត់ដែលមានពណ៌ ( ក្នុងករណីយកទៅដុត ) ។

២-សំណល់កំទេចក្រដាស ដែលសល់ពីការផលិតម្សៅក្រដាស ។

៣-សំណល់ភក់ ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តកម្មសំអាតសំណល់រាវ និងទឹកល្អូ ។

៤-សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡឧស្សាហកម្ម ។

៥-សំណល់ប្លាស្ទិច "ប៉ូលីវីនីក្លរួ" ។

៦-សំណល់សារធាតុជ័រប៉ូលីក្លរីណេតទីតប៊ីផេនីល (PCB) នៃម៉ាស៊ីនត្រជាក់ ទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ។ល ។

៧-សំណល់ជ័រ និងកៅស៊ូដែលមានសារធាតុប៉ូលីម៉ែប៊ុយទីលីន

៨-សំណល់ប្រេងឥន្ទនៈ និងប្រេងម៉ាស៊ីន

៩-សំណល់ដែលមានផ្ទុកជាតិអាស៊ីត

១០-សំណល់ដែលមានផ្ទុកជាតិបាស

១១-សំណល់លោហៈ និងសមាសធាតុរបស់វារួមមាន :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម(Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរិយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |
| បារត (Hg) | កាត់ម្យូម (Cd) | ដែក (Fe) | |

១២-លំអងផ្សែង និងធូលីដែលកើតមានក្នុងករណីសំអាតផ្សែងបញ្ចេញពីមូលដ្ឋានផលិតកម្ម

១៣-សំណល់អំពូលអគ្គិសនី និងបន្ទះប្រព័ន្ធគ្រឿងអេឡិចត្រូនិចអគ្គិសនី

១៤-សំណល់អាគុយ និងថ្មពិល

១៥-សំណល់ថ្នាំលាប និងថ្នាំជ្រលក់ពណ៌ និងសំភារៈវេចខ្ចប់ថ្នាំពណ៌

១៦-សំណល់បានមកពីការផលិត និងការប្រើប្រាស់ទឹកខ្មៅបោះពុម្ព

១៧-សំណល់គ្រឿងផ្ទុះ

១៨-សំណល់ដែលនាំអោយមានការចំលងមេរោគ ឬជំងឺ

១៩-សំណល់ដែលសល់ពីការផលិតថ្នាំពុលកសិកម្ម និងសំភារៈវេចខ្ចប់

២០-សំណល់ផេះនៃឡដុតសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់

២១-ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់

២២-សំណល់ហ្វីល ដូចជាហ្វីលភាពយន្ត វីដេអូ ហ្វីលកាសែតចំរៀង ហ្វីលថតរូប និងហ្វីលថតសរីរាង្គមនុស្សតាមមន្ទីរពេទ្យ

២៣-សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសំអាតដីកខ្វក់ ឬដីខូចគុណភាព

២៤-សំណល់ដែលបានមកពីការផលិតឱសថ និងឱសថដែលខូចគុណភាព

២៥-សំណល់ដែលជាសមាសធាតុសរីរាង្គក្លរយអរីន

២៦-សំណល់ដែលជាសមាសធាតុស៊ីអានីត

២៧-សំណល់ដែលជាសមាសធាតុអាសបេតូស

២៨-សំណល់ដែលជាសមាសធាតុផេណុល ($C_6H_5OH$)

២៩-សំណល់ដែលជាសមាសធាតុអេទែ ($R\text{-}COO\text{-}R_1$)

៣០-សំណល់ដែលជាសារធាតុសរីរាង្គរំលាយដែលមានអាឡូសែន និងគ្មានអាឡូសែន

៣១-សំណល់ដែលជាសមាសធាតុឌីអុកស៊ីន និងហ្វូរ៉ាន

៣២-សំណល់ធាតុវិទ្យុសកម្ម

៣៣-សារធាតុដែលជាផលិតផលបានមកពីការធ្វើប្រព្រឹត្តកម្មសំអាតសំណល់ ដែលមានចែងពីចំនុចទី១ ដល់ទី៣២

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ** :  ២៧ អ.ន.ក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការត្រួតពិនិត្យការបំពុលទឹក

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ និងការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៩ ។

ជ-"**បរិមាណសារធាតុបំពុល**" គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ-"**សារធាតុប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមានគ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលអោយប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## បញ្ញត្តិលើការបញ្ចេញសំណល់
## និងសារធាតុប្រកបដោយគ្រោះថ្នាក់

**មាត្រា ៤.-**

ក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

ក្នុងករណីចាំបាច់ និងតំរូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្សជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក សំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

ក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦.-**

ហាមឃាត់ដាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំក៏រិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតឱ្យបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និង ការអភិរក្សជីវៈចំរុះ ។

ក៏រិតស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៨.-**

ហាមឃាត់ដាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹក

សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ហាមឃាត់ជាដាច់ខាតនូវការទុកដាក់ ឬការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលនាំឱ្យមានការបំពុលទឹកតំបន់ទឹកសាធារណៈ ។

**មាត្រា ៩.-**

ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសំអាតនានា ។

## ជំពូកទី ៣

## ការសុំអនុញ្ញាតបញ្ចេញសំណល់រាវ

**មាត្រា ១០.-**

ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១១.-**

ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ហើយដែលចែកចេញជាពីរប្រភេទ ដូចតទៅ :

ក-ប្រភពបំពុលប្រភេទថ្នាក់ទី១ តំរូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង ១០ ម៉ែត្រគូបក្នុងមួយថ្ងៃដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សំរាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ ។

ខ-ប្រភពបំពុលប្រភេទថ្នាក់ទី២ ចាំបាច់តំរូវអោយមានការសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ។

**មាត្រា ១២.-**

ការសុំអនុញ្ញាតលើការបញ្ចេញចោល ឬការដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុល ទាំងគំរោងថ្មី និងទាំងគំរោងកំពុងដំណើរការ លើកលែងតែគំរោងប្រភពបំពុលថ្មី ដែលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោងនោះត្រូវបានអនុម័ត នឹងត្រូវបានរួចផុតពីការតំរូវឱ្យសុំការអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ។

**មាត្រា ១៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកាន់កន្លែងដទៃ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

-អោយបានមុន ៤០ថ្ងៃសំរាប់គំរោងនៅភ្នំពេញ និង ៦០ថ្ងៃ សំរាប់គំរោងនៅតាមខេត្ត ក្រុងនៃការចាប់ផ្តើម

## ជំពូកទី ៨
## អវសានបញ្ញត្តិ

**មាត្រា ៣៧.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៩.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣៨

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

## តារាងឧបសម្ព័ន្ធ ១

## ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់

១-សមាសធាតុសរីរាង្គអាឡូសែន និងសារធាតុដែលអាចបង្កើតបានជាសមាសធាតុសរីរាង្គអាឡូសែនទាំងនោះនៅក្នុងបរិស្ថានទឹក

២-សមាសធាតុសរីរាង្គផូស្វរ

៣-សមាសធាតុសរីរាង្គទីន

៤-សារធាតុដែលបង្កអោយមានជំងឺមហារីក

៥-បារត និងសមាសធាតុរបស់វា

៦-កាត់ម្ញូម និងសមាសធាតុរបស់វា

៧-សមាសធាតុប្រេងអសរីរាង្គដែលមិនបំបែកធាតុ និងពពួកអ៊ីដ្រូកាបួនៃសមាសធាតុប្រេងឆៅ

៨-សមាសធាតុសំយោគដែលមិនបំបែកធាតុ ដែលអាចអណ្តែតនៅលើផ្ទៃទឹក រឺលិចក្នុងទឹកហើយដែលអាចជ្រាបចូលទៅក្នុងការប្រើប្រាស់ទឹក

៩-សារធាតុវិទ្យុសកម្ម

១០-លោហៈ និងសមាធាតុ របស់វាដូចជា :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម(Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរិយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |

១១-សមាសធាតុសរីរាង្គពុលមិនបំបែកធាតុស៊ីលីស្យូម

១២-សមាសធាតុអសរីរាង្គផូស្វរ

១៣-សមាសធាតុប្រេងជាអសរីរាង្គបំបែកធាតុ និងពពួកអ៊ីដ្រូកាបួនៃសមាសធាតុប្រេងឆៅ

១៤-សមាសធាតុស៊ីអានីត និងភ្លុយអរ

១៥-សារធាតុដែលមានឥទ្ធិពលលើអុកស៊ីសែន ដូចជា អាម៉ូញ៉ាក់ នីទ្រីត ។ល។

## តារាងឧបសម្ព័ន្ធ ២

កំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ពីប្រភពបំពុលចូលទៅ

ក្នុងតំបន់ទឹកសាធារណៈ ឬទៅក្នុងប្រព័ន្ធបណ្តាញលូ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | បរិមាណសារធាតុបំពុលដែលអាចអនុញ្ញាតឱ្យបញ្ចេញ | |
|---|---|---|---|---|
| | | | តំបន់ទឹកសាធារណៈដែលត្រូវបានការពារ | តំបន់ទឹកសាធារណៈនិងលូ |
| 1 | សីតុណ្ហភាព | $^0C$ | <45 | <45 |
| 2 | pH | | 6-9 | 5-9 |
| 3 | $BOD_5$ | mg/l | <30 | <80 |
| 4 | COD | mg/l | <50 | <100 |
| 5 | សារធាតុរឹងអណ្តែតក្នុងទឹក | mg/l | <60 | <120 |
| 6 | សារធាតុរឹងដែលរលាយក្នុងទឹក | mg/l | <1000 | <2000 |
| 7 | ប្រេង ឬខ្លាញ់ | mg/l | <5.0 | <15 |
| 8 | សាប៊ូ | mg/l | <5.0 | <15 |
| 9 | ផេណុល | mg/l | <0.1 | <1.2 |
| 10 | នីត្រាត | mg/l | <10 | <20 |
| 11 | ក្លរក្នុងទំរង់សេរី | mg/l | <1.0 | <2.0 |
| 12 | ក្លរជាអ៊ីយ៉ុង | mg/l | <500 | <700 |
| 13 | ស៊ុលផាត | mg/l | <300 | <500 |
| 14 | ស៊ុលហ្វីត | mg/l | <0.2 | <1.0 |
| 15 | ផូស្វាត | mg/l | <0.3 | <6.0 |
| 16 | ស៊ីអានីត ($CN^{-1}$) | mg/l | <0.2 | <1.5 |
| 17 | បារ្យ៉ូម (Ba) | mg/l | <4.0 | <7.0 |
| 18 | អាសេនិច (As) | mg/l | <0.10 | <1.0 |
| 19 | សំណប៉ាហាំង(Sn) | mg/l | <2.0 | <8.0 |
| 20 | ដែក (Fe) | mg/l | <1.0 | <20 |
| 21 | បរ(B) | mg/l | <1.0 | <5.0 |
| 22 | ម៉ង់កាណែស(Mn) | mg/l | <1.0 | <5.0 |
| 23 | កាត់ម្ញូម(Cd) | mg/l | <0.1 | <0.5 |

| | | | | |
|---|---|---|---|---|
| 24 | ក្រូម(Cr)$^{+3}$ | mg/l | <0.2 | <1.0 |
| 25 | ក្រូម(Cr)$^{+6}$ | mg/l | <0.05 | <0.5 |
| 26 | ទង់ដែង(Cu) | mg/l | <0.2 | <1.0 |
| 27 | សំណ(Pb) | mg/l | <0.1 | <1.0 |
| 28 | បារត(Hg) | mg/l | <0.002 | <0.05 |
| 29 | នីកែល(Ni) | mg/l | <0.2 | <1.0 |
| 30 | សេលេញ៉ូម(Se) | mg/l | <0.05 | <0.5 |
| 31 | ប្រាក់(Ag) | mg/l | <0.1 | <0.5 |
| 32 | ស័ង្កសី(Zn) | mg/l | <1.0 | <3.0 |
| 33 | ប៉ូលីបដែន(Mo) | mg/l | <0.1 | <1.0 |
| 34 | អាម៉ូញាក់($NH_3$) | mg/l | <5.0 | <7.0 |
| 35 | អុកស៊ីសែនដែលរលាយក្នុងទឹក | mg/l | >2.0 | >.1.0 |
| 36 | ប៉ូលីក្លរ៉ូ បីផេនីល(PCB) | mg/l | <0.003 | <0.003 |
| 37 | កាល់ស្យូម(Ca) | mg/l | <150 | <200 |
| 38 | ម៉ាញ៉េស្យូម(Mg) | mg/l | <150 | <200 |
| 39 | កាបូនតេត្រាក្លរូ | mg/l | <3 | <3 |
| 40 | អ៊ិចសាក្លូរបង់សែន | mg/l | <2 | <2 |
| 41 | ដេដេតេ | mg/l | <1,3 | <1,3 |
| 42 | អង់ឌ្រីន | mg/l | <0,01 | <0,01 |
| 43 | ឌីអលឌ្រីន | mg/l | <0,01 | <0,01 |
| 44 | អេនឌ្រីន | mg/l | <0,01 | <0,01 |
| 45 | អ៊ីសូឌ្រីន | mg/l | <0,01 | <0,01 |
| 46 | ពែក្លរអេទីឡែន | mg/l | <2,5 | <2,5 |
| 47 | អ៊ិចសាក្លូរប៊ុយតាឌីអែន | mg/l | <3 | <3 |
| 48 | ក្លូរហ្វម | mg/l | <1 | <1 |
| 49 | 1,2 ឌីក្លរអេទីឡែន | mg/l | <2,5 | <2,5 |
| 50 | ទ្រីក្លរអេទីឡែន | mg/l | <1 | <1 |
| 51 | ទ្រីក្លរបង់សែន | mg/l | <2 | <2 |
| 52 | អ៊ិចសាក្លូរស៊ីក្លូអ៊ិចសែន | mg/l | <2 | <2 |

***កំណត់សំគាល់*** : ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការរៀបចំក៏រិតកំណត់ស្តង់ដារថ្នាំពុលកសិកម្ម ដែលបញ្ចេញពីប្រភពបំពុល ។

# តារាងឧបសម្ព័ន្ធ ៣

ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយមានការសុំអនុញ្ញាតិពីក្រសួងបរិស្ថាន

មុននឹងបញ្ចេញចោលនូវសំណល់រាវរបស់ខ្លួន ឬដឹកទៅទីដទៃ

| ល.រ | ប្រភេទប្រភពបំពុល | កំរិតថ្នាក់ប្រភេទ |
|---|---|---|
| 1 | -ទីតាំងផលិតអាហារ និងសាច់កំប៉ុង | ទី១ |
| 2 | -ទីតាំងផលិតបន្លែ និងផ្លែឈើកំប៉ុង | ទី១ |
| 3 | -ទីតាំងកែច្នៃផលនេសាទ | ទី១ |
| 4 | -ទីតាំងក្លាសេ និងបង្កក | ទី១ |
| 5 | -ទីតាំងផលិតម្សៅមី | ទី១ |
| 6 | -ទីតាំងផលិតស្ករស | ទី១ |
| 7 | -ទីតាំងផលិតទឹកស្អាត | ទី១ |
| 8 | -ទីតាំងផលិតស្នូនរបស់ប្រើប្រាស់ពីដី | ទី១ |
| 9 | -ទីតាំងផលិតភេសជ្ជៈ និងស្រាបៀរ | ទី១ |
| 10 | -ទីតាំងផលិតអាល់កុល និងស្រា | ទី១ |
| 11 | -ទីតាំងផលិតចំណីសត្វ | ទី១ |
| 12 | -ទីតាំងផលិតប្រេង និងខ្លាញ់ | ទី១ |
| 13 | -ទីតាំងផលិតដំបែ និងមេស្រា | ទី១ |
| 14 | -ទីតាំងផលិតនំ និងស្ករគ្រាប់ | ទី១ |
| 15 | -ទីតាំងផលិតបារី | ទី១ |
| 16 | -ទីតាំងកាត់ដេរគ្មានក្រឡុកបោក | ទី១ |
| 17 | -សណ្ឋាគារ | ទី១ |
| 18 | -ភោជនីយដ្ឋាន | ទី១ |
| 19 | -ទីតាំងកសិដ្ឋានចិញ្ចឹមសត្វ | ទី១ |
| 20 | -ទីតាំងសត្តឃាត | ទី១ |
| 21 | -ទីតាំងយានដ្ឋាន និងកន្លែងលាងរថយន្ត | ទី១ |
| 22 | -ទីតាំងមជ្ឈមណ្ឌលលក់ដុំ និងទីផ្សារ | ទី១ |
| 23 | -ទីតាំងមន្ទីរពេទ្យ និងសម្ភព | ទី១ |
| 24 | -ទីតាំងផលិតរបស់ផ្លាស្ទិក-កៅស៊ូកង់ | ទី១ |
| 25 | -ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវលំនៅស្ថាន | ទី១ |
| 26 | -ទីតាំងផលិតជ័រកាវ | ទី១ |
| 27 | -ទីតាំងបង្អក និងកែច្នៃជ័រក្រៃប | ទី១ |

| | | |
|---|---|---|
| 28 | -ទីតាំងផលិតកែវ-ដប | ទី១ |
| 29 | -ទីតាំងផលិតស៊ីម៉ងត៍ | ទី១ |
| 30 | -ការដ្ឋានយកថ្ម | ទី១ |
| 31 | -ការដ្ឋានយកគ្រួស | ទី១ |
| 32 | -ទីតាំងផលិតក្តារបន្ទះ | ទី១ |
| 33 | -ទីតាំងផលិត ឬកែច្នៃជីគីមីកសិកម្ម | ទី១ |
| 34 | -ទីតាំងលាយបេតុង និងផលិតសំភារៈសំណង់ជាបេតុង | ទី១ |
| 35 | -នាំវាដឹកសារធាតុភាវ | ទី២ |
| 36 | -ទីតាំងផលិតអាសេទីឡែន | ទី២ |
| 37 | -ទីតាំងសំលាប់ស្បែក | ទី២ |
| 38 | -ទីតាំងផលិតសាប៊ូ និងផលិតមេសាប៊ូ | ទី២ |
| 39 | -ទីតាំងស្ថានីយ៍ និងឃ្លាំងស្តុកប្រេងឥន្ធនៈ | ទី២ |
| 40 | -ទីតាំងកប់ ឬចាក់ចោលសំណល់រឹង | ទី២ |
| 41 | -ទីតាំងតំបាញ ឬជ្រលក់ពណ៌ | ទី២ |
| 42 | -ទីតាំងកាត់ដេរមានក្រឡុកបោក | ទី២ |
| 43 | -ទីតាំងផលិតក្រដាស និងម្សៅក្រដាស | ទី២ |
| 44 | -ទីតាំងបោះពុម្ពទស្សនាវដ្តី និងឯកសារផ្សេងៗ | ទី២ |
| 45 | -ទីតាំងលាងសំអាតត្បូងថ្ម និងរ៉ែ | ទី២ |
| 46 | -ទីតាំងផលិតថ្មពិល —អាគុយ | ទី២ |
| 47 | -ទីតាំងផលិតថ្នាំពណ៌អសរីរាង្គ | ទី២ |
| 48 | -ទីតាំងផលិត និងតំឡើងគ្រឿងអេឡិចត្រូនិច | ទី២ |
| 49 | -ទីតាំងផលិតជ័រក្រាលថ្ន | ទី២ |
| 50 | -ទីតាំងផលិតហ្វីលថត និងថ្នាំលាងហ្វីល | ទី២ |
| 51 | -ទីតាំងផលិតសារធាតុគីមីសរីរាង្គ | ទី២ |
| 52 | -ទីតាំងផលិតឱសថ | ទី២ |
| 53 | -ទីតាំងផលិតសារធាតុសរីរាង្គប្រើសំរាប់លាង | ទី២ |
| 54 | -ទីតាំងផលិត និងលាយថ្នាំពុលកសិកម្ម | ទី២ |
| 55 | -ទីតាំងផលិត ចំរាញ់ប្រេងកាត | ទី២ |
| 56 | -ទីតាំងផលិតដែក និងដែកថែប | ទី២ |
| 57 | -ទីតាំងផលិតលោហៈធាតុដែលមិនមែនដែក | ទី២ |
| 58 | -ទីតាំងផលិតរបស់របរលោហៈ | ទី២ |

| | | |
|---|---|---|
| 59 | -ទីតាំងក្រូម៉េរបស់លោហៈធាតុដែលមិនមែនដែក | ទី២ |
| 60 | -ទីតាំងដុត រឺកែច្នៃសំណល់រឹង | ទី២ |
| 61 | -ទីតាំងប្រព្រឹត្តកម្មសំអាតដី | ទី២ |
| 62 | -ទីតាំងកែច្នៃសំណល់ប្រេង | ទី២ |
| 63 | -ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវឧស្សាហកម្ម | ទី២ |
| 64 | -មន្ទីរពិសោធន៍ និងមជ្ឈមណ្ឌលស្រាវជ្រាវ | ទី២ |
| 65 | -រោងចក្រអគ្គិសនី | ទី២ |
| 66 | -ទីតាំងកែច្នៃឈើ | ទី២ |
| 67 | -ការដ្ឋានស្រែបង្គា | ទី២ |

# តារាងឧបសម្ព័ន្ធ ៤

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ

សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹក

## ១.សំរាប់ទន្លេ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | $BOD_5$ | mg/l | 1-10 |
| 3 | សារធាតុរឹងអណ្តែតលើទឹក(SS) | mg/l | 25-100 |
| 4 | កំរិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម(Coliform) | MPN/100ml | <5000 |

## ២.សំរាប់បឹង និងអាងស្តុកទឹក

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | COD | mg/l | 1-8 |
| 3 | សារធាតុរឹងអណ្តែតលើទឹក(SS) | mg/l | 1-15 |
| 4 | កំរិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម(Coliform) | MPN/100ml | <1000 |
| 6 | អាសូតសរុប(Total Nitrogen) | mg/l | 0,1-0,6 |
| 7 | ផូស្វរសរុប(Total Phosphorus) | mg/l | 0,005-0,05 |

## ៣.សំរាប់ទឹកសមុទ្រ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 7,0-8,3 |
| 2 | COD | mg/l | 2-8 |
| 3 | កំរិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 4 | កូលីហ្វម(Coliform) | MPN/100ml | <1000 |
| 5 | សមាសធាតុប្រេង(Oil content) | mg/l | 0 |
| 6 | អាសូតសរុប (Total Nitrogen) | mg/l | 0,2-1,0 |
| 7 | ផូស្វរសរុប (Total Phosphorus) | mg/l | 0,02-0,09 |

## តារាងឧបសម្ព័ន្ធ ៥

ក៏រិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ

សំរាប់ការពារសុខភាពសាធារណៈ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | ក៏រិតស្តង់ដារ |
|---|---|---|---|
| 1 | កាបូនតេត្រាក្លរួ | μg/l | <12 |
| 2 | អ៊ិចសាក្លរបង់សែន | μg/l | <0,03 |
| 3 | ដេដេតេ | μg/l | <10 |
| 4 | អង់ឌ្រីន | μg/l | <0,01 |
| 5 | ឌីអលឌ្រីន | μg/l | <0,01 |
| 6 | អេនឌ្រីន | μg/l | <0,005 |
| 7 | អ៊ីសូឌ្រីន | μg/l | <0,005 |
| 8 | ពែក្លរួអេទីឡែន | μg/l | <10 |
| 9 | អ៊ិចសាក្លរប៊ុយតាឌីអែន | μg/l | <0,1 |
| 10 | ក្លរហ្វម | μg/l | <12 |
| 11 | 1,2ឌីក្លរអេទីឡែន | μg/l | <10 |
| 12 | ទ្រីក្លរអេទីឡែន | μg/l | <10 |
| 13 | ទ្រីក្លរបង់សែន | μg/l | <0,4 |
| 14 | អ៊ិចសាក្លរស៊ីក្លូអ៊ិចសែន | μg/l | <0,05 |
| 15 | បង់សែន | μg/l | <10 |
| 16 | តេត្រាក្លរអេទីឡែន | μg/l | <10 |
| 17 | កាត់ម្ញូម | μg/l | <1 |
| 18 | បារតសរុប | μg/l | <0,5 |
| 19 | បារតសរីរាង្គ | μg/l | 0 |
| 20 | សំណ | μg/l | <10 |
| 21 | ក្រូមវ៉ាឡង់ ៦ | μg/l | <50 |
| 22 | អាសេទិច | μg/l | <10 |
| 23 | សេលេញ៉ូម | μg/l | <10 |
| 24 | ប៉ូលីក្លរ៉ូ ប៊ីផេនីល(PCB) | μg/l | 0 |
| 25 | ស៊ីអានីត ($CN^{+}$) | μg/l | <0,005 |